ជំនួយស្មារតី

# គន្លឹះជោគជ័យសរសេរតែងសេចក្តី





អៀង_ពិសី
បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ



ឧបត្ថម្ភធម្មទានថវិកាបំពេញបញ្ញាបារមីបោះពុម្ពសៀវភៅនេះដោយ : មូលនិធិអៀង

ជំនួយស្មារតី

# គន្លឹះដោតជ័យសរសេរតែងសេចក្ដី


## សាស្ត្រាចារ្យ អៀង-ពិសី

បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ



ព.ស. ២៥៥៨ គ.ស. ២០១៤

# គណៈកម្មការនិពន្ធ

## និពន្ធនាយក

សាស្ត្រាចារ្យ ខូច-គីមស្រ៊ាង

សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ប្រធានសមាគមបទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរសាកលវិទ្យាល័យជាតិគ្រប់គ្រង

## និពន្ធនាយករង

សាស្ត្រាចារ្យ អៀង-ពិសី

ទីប្រឹក្សាសមាគមបទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

សមាជិកសកម្មសមាគមអ្នកនិពន្ធខ្មែរ

គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ

## ជំនួយការនិពន្ធនាយក

លោក អ៊ុន-សុភា

សមាជិកសមាគមបទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

## ឧត្តមទីប្រឹក្សា

ព្រះតេជព្រះគុណ យស-ហ៊ុត ខេមចារោ

ព្រះតេជព្រះគុណ លឹម-ថេង សោភណោ

ឯកឧត្តម នាយឧត្តមសេនីយ៍ តេង-សាវឌ្ឍ

ឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ម-សំ

ឯកឧត្តម ឧត្តមសេនីយ៍ទោ អឿ-សាវ័ន

លោក អៀង-សុធារ៉ា ប្រធានមូលនិធិអៀង

## អ្នកត្រួតពិនិត្យអក្ខរាវិរុទ្ធនិងខ្លឹមសារ

១- ព្រះមហា ទ៊ែន-វិបុល ទីប្រឹក្សាសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

២- សាស្ត្រាចារ្យ គង់-សុខឡេង សមាជិកសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

៣- សាស្ត្រាចារ្យ វ៉ាន់-ផល្លី សមាជិកសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

៤- សាស្ត្រាចារ្យ សុខ-ធម្មតាសី បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រអប់រំ

៥- សាស្ត្រាចារ្យ ហ៊ិន-ស៊ីនី គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ

៦- សាស្ត្រាចារ្យ ម៉ុត-សុផល សមាជិកសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

៧- កញ្ញា ជឹម-គីរម្យ មន្ត្រីនាយកដ្ឋានទំនាក់ទំនងវប្បធម៌និងអាហារូបករណ៍

៨- កញ្ញា ធិញ-ធីណា គ្រូបង្រៀនវិទ្យាស្ថានប៉ែលធីអន្តរជាតិ

៩- កញ្ញា ចាន់-នីតា បរិញ្ញាបត្រប្រវត្តិវិទ្យា

១០- កញ្ញា ដៃ-សារ៉ែម បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ

១១- លោក គោគ-ច័ន្ទវិបុល គ្រូបង្រៀនសាលាត្បូងឃ្មុំ

## អ្នកវាយអត្ថបទ

១- អ្នកស្រី ឃាក់-វណ្ណា គ្រូបង្រៀនសាលាបឋមសិក្សាត្មូមិឫស្សី

**បោះពុម្ពលើកទី១** : ៧កើត ខែមិគសិរ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃសុក្រ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤

រក្សាសិទ្ធិគ្រប់យ៉ាង ©

ISBN-13:978-999-63-879-1.3

“ការថតចម្លងស្នាដៃរៀបរៀងនៃអ្នកនិពន្ធមកធ្វើអាជីវកម្មជាអំពើល្មើសច្បាប់”

# អារម្ភកថា

ប្រទេសកម្ពុជា មានប្រវត្តិជាវៀមច្បងនៅភូមិភាគអាស៊ីអាគ្នេយ៍ និងជាអាណាចក្រដែលសម្បូរដោយសម្បត្តិវប្បធម៌ច្រើនសន្ធឹកសន្ធាប់។ ខ្មែរ ជាជាតិសាសន៍ដែលមានឧត្តមគតិថ្លៃថ្នូរនិងប្រកាន់សច្ចភាពស្គាល់ខុស ស្គាល់ត្រូវ ស្គាល់ល្អ ស្គាល់អាក្រក់ ស្គាល់មិត្ត ស្គាល់សត្រូវ។

អាស្រ័យដោយយើងមានខឿនវប្បធម៌រឹងមាំដូច្នេះហើយ ទើបអ្នកប្រាជ្ញ បណ្ឌិត កវី អ្នកនិពន្ធជាច្រើនជំនាន់មកហើយបានខិតខំចងក្រងជាវណ្ណកម្មបន្សល់ទុកយ៉ាងច្រើនដល់អ្នកសិក្សាជំនាន់ក្រោយ ឱ្យបានសិក្សាស្រាវជ្រាវរិះរកប្រភពចំណេះដឹងមិនចេះរីងស្ងួតនេះ។

សៀវភៅមួយក្បាល ដែលមិត្តអ្នកសិក្សាកំពុងកាន់នៅដៃនេះ គឺជាកូនសោយ៉ាងពិសេសមួយ សម្រាប់ជួយអ្នកឱ្យទទួលបានជោគជ័យនៅក្នុងការសរសេរតែងសេចក្ដីខ្មែរឱ្យបានល្អថែមមួយកម្រិតទៀត។

ជាទីបញ្ចប់ យើងខ្ញុំជាអ្នករៀបរៀងសៀវភៅមួយក្បាលនេះ សូមគោរពជូនពរមិត្តអ្នកសិក្សាគ្រប់ៗគ្នាឱ្យមានសុខភាពល្អ និងទទួលជោគជ័យក្នុងការសិក្សាអក្សរសាស្ត្រជាតិយើង ឱ្យបានលេចចេញជាផ្លែផ្កាដើម្បីអភិវឌ្ឍសង្គមជាតិតទៅ។

រាជធានីភ្នំពេញ ៧កើត ខែមិគសិរ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃសុក្រ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤

**អៀង-ពិសី**

# គោលបំណង

ដោយយល់ឃើញបច្ចុប្បន្នភាពនេះ ចំនួនសិស្សចេះសរសេរតែងសេចក្តីបានល្អនិងត្រឹមត្រូវតាមក្បួននោះ គឺមានចំនួនតិចតួចណាស់ ហើយភាគច្រើន គឺមិនសូវជាដឹងពីប្រភេទតែងសេចក្តីខ្មែរអស់ដែរ ទើបការសិក្សាស្រាវជ្រាវមួយនេះបានធ្វើឡើង ដើម្បីជាប្រយោជន៍រួមដល់ខេមរបុត្រធីតាទាំងអស់គ្នា។ ឯកសារទាំងនេះទុកបម្រើដល់ការសិក្សានៅសាលាចំណេះទូទៅទាំងបឋមសិក្សានិងមធ្យមសិក្សា។

គោលបំណងក្នុងការរៀបរៀងសៀវភៅនេះឡើង គឺចង់ឱ្យសិស្សានុសិស្ស បន្ថែមការយកចិត្តទុកដាក់ទៅលើការសិក្សាមុខវិជ្ជាអក្សរសាស្ត្រខ្មែរដែលជាអត្តសញ្ញាណជាតិដ៏ខ្ពង់ខ្ពស់ និងបង្កើបបង្ហាញគន្លឹះពិសេសនៃការសរសេរតែងសេចក្តីឱ្យបានល្អនិងជោគជ័យ។

ទស្សនៈមួយលើកឡើងថា “ប្រហែលជាគ្មានបុគ្គលណាម្នាក់ដែលស្រលាញ់អក្សរសាស្ត្រជាតិយើងនិងឱ្យតម្លៃខ្ពង់ខ្ពស់ ជាងខ្លួនយើងស្រលាញ់និងឱ្យតម្លៃដោយខ្លួនឯងនោះឡើយ”។

សូមឱ្យប្រយោជន៍មួយនេះ បានដល់ដៃមិត្តអ្នកសិក្សាទាំងអស់ និងបានជាគំនិតមួយដ៏ប្រសើរ សម្រាប់បម្រើបច្ចេកទេសនៃការសរសេរតែងសេចក្តីឱ្យមានតម្លៃនិងមានភាពច្បាស់លាស់។

រាជធានីភ្នំពេញ ៧កើត ខែមិគសិរ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃសុក្រ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤

**អៀង-ពិសី**

# សេចក្ដីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណជាអតិបរមាចំពោះឧត្ដមភរិយា ហាក់-វណ្ណា និងក្រុមគ្រួសារដែលបានយោគយល់ ចែករំលែកពេលវេលាដើម្បីឱ្យខ្ញុំអាចមានឱកាសសិក្សាស្រាវជ្រាវប្រកបដោយជោគជ័យ។

ជាពិសេស សូមគោរពសម្ដែងការដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះលោក **អៀង-សុធារ៉ា** ប្រធានមូលនិធិអៀង ដែលមានសន្ដានចិត្តសប្បុរិសធម៌ឧបត្ថម្ភធម្មទានថវិកាបំពេញបញ្ញាបារមីបោះពុម្ពសៀវភៅ **គន្លឹះជោគជ័យសរសេរតែងសេចក្ដី** ក្នុងគោលដៅសំខាន់ផ្សព្វផ្សាយសំណេរតែងសេចក្ដីខ្មែរយើងឱ្យអ្នកសិក្សាទូទៅ បានយល់ដឹងពីផលប្រយោជន៍នៃគុណតម្លៃអក្សរសាស្ត្រខ្មែរ ព្រមទាំងដើម្បីឱ្យដំណើរការ សមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ។

សូមថ្លែងអំណរគុណឯកឧត្ដម លោកជំទាវ សប្បុរសជន និងលោកអ្នកអាន ដែលបានជួយលើកស្ទួយគុណតម្លៃរៀបរៀងសៀវភៅរបស់ខ្ញុំ និងសូមមេត្តាអធ្យាស្រ័យកំហុសឆ្គងដោយប្រការផ្សេងៗ។ ខ្ញុំនឹងរីករាយទទួលយកការកែលម្អកំហុសខ្លឹមសារ អក្ខរាវិរុទ្ធ ដើម្បីឱ្យខ្ញុំបានបម្រើអស់លោកអ្នកអានកាន់តែប្រសើរជាងមុនថែមទៀត។

រាជធានីភ្នំពេញ ៧កើត ខែមិគសិរ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃសុក្រ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤

**អៀង-ពិសី**

# មាតិកា

| ល.រ. | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|


អារម្ភកថា........................................................ក

គោលបំណង........................................................ខ

សេចក្តីថ្លែងអំណរគុណ........................................................គ

១- គន្លឹះជោគជ័យសរសេរតែងសេចក្តី........................................................១

២- និយមន័យតែងសេចក្តី........................................................៤

៣- ការស្រាវជ្រាវឯកសារសម្រាប់សរសេរឱ្យបានល្អ........................................................៦

៤- ប្រធានពណ៌នា........................................................១៦

៥- ប្រធានពណ៌នាអំពីមនុស្ស........................................................១៧

៦- ប្រធានពណ៌នាអំពីសត្វ........................................................២០

៧- ប្រធានពណ៌នាអំពីវត្ថុ........................................................២៤

៨- ប្រធានពណ៌នាអំពីរុក្ខជាតិ........................................................២៧

៩- ប្រធានពណ៌នាអំពីសកម្មភាព........................................................៣០

១០- ប្រធានពណ៌នាអំពីទេសភាព........................................................៣៤

១១- ប្រធានពណ៌នាអំពីក្របខណ្ឌអត្ថបទអក្សរសិល្ប៍........................................................៣៨

១២- ប្រធានពណ៌នាអំពីរឿង........................................................៤១

១៣- ប្រធានពណ៌នារឿងទូទៅតាមឯកទានវិធី........................................................៤៦

១៤- ប្រធានពណ៌នារឿងបែបរំឭកអនុស្សាវរីយ៍........................................................៥០

១៤- ប្រធាននិទានរឿង..........................................................៥៤

១៤- ប្រធានសរសេរសំបុត្រ......................................................៥៨

១៥- សំបុត្រឯកជនសួរសុខទុក្ខធម្មតា.....................................៥៩

១៦- សំបុត្រសួរសុខទុក្ខបែបពណ៌នា.......................................៦៣

១៧- ប្រធានពន្យល់...................................................................៦៧

១៨- ប្រធានពន្យល់បែបសុភាសិត.............................................៧៤

១៩- ប្រធានពន្យល់បែបពាក្យស្លោកឬឧស្សាហ៍នះទូទៅ....................៨៧

២០- ប្រធានពន្យល់ប្រៀបធៀប...................................................៩១

២១- ប្រធានពន្យល់លក្ខណៈចោទជាសំណួរ.............................១០០

២២- ប្រធានពិភាក្សា...............................................................១០៦

២៣- ប្រធានពិភាក្សាសុទ្ធឬពិភាក្សាមួយមតិ............................១០៨

២៤- ប្រធានពិភាក្សាប្រៀបធៀបឬពិភាក្សាពីរមតិ.....................១១៧

២៥- ប្រធាននិទស្សន៍...............................................................១២៥

# គន្លឹះជោគជ័យសរសេរតែងសេចក្ដី

សេចក្ដីផ្ដើម

ការសរសេរតែងសេចក្ដីបានល្អ គឺទាមទារជាចាំបាច់នូវការបញ្ចេញបញ្ចូលទស្សនៈដ៏ប៉ិនប្រសប់ ដែលជាសិល្បវិធីរបស់អ្នកសរសេរ ដើម្បីអន្ទងចិត្តអ្នកអានឱ្យចាប់អារម្មណ៍ទៅលើការបកស្រាយនោះហាក់បីដូចបានឃើញព្រឹត្តិការណ៍នៃរឿង ដែលកំពុងរៀបរាប់នៅនឹងភ្នែករបស់គេអ៊ីចឹង។ ការសរសេរល្អមិនមែនសរសេរដោយលើកត្រង់នេះបន្ដិចត្រង់នោះបន្ដិចមិនច្បាស់លាស់ ហើយពុំមានជាប់ទាក់ទងនឹងប្រធានបទឬសរសេរជារឿងកំប្លែង ដើម្បីពន្លូតសេចក្ដីអធិប្បាយរបស់ខ្លួនឱ្យវែងឆ្ងាយនោះទេ ហើយក៏មិនមែនលើកយកព្រឹត្តិការណ៍តែមួយមកនិយាយសាចុះសាឡើងដដែលៗនោះដែរ អ្វីដែលសំខាន់សម្រាប់លើកយកមកសរសេរប្រាប់អ្នកអាន ជាព្រឹត្តិការណ៍ជាប់ទាក់ទងនឹងប្រធានបទ ហើយមានពិតនៅក្នុងសង្គមឬស្នាដៃអក្សរសិល្ប៍ណាមួយ ពោលគឺមិនមែនជាការប្រឌិតចេញពីមនោគតិ (គំនិតស្រមើស្រមៃ) ផ្ទាល់ខ្លួននោះឡើយ។

អ្នកសរសេរតែងសេចក្តីត្រូវគិតថា ប្រធានបទមួយដែលយើងកំពុងសរសេរជាចំណុចគោល ដែលត្រូវការឱ្យអ្នកអធិប្បាយឆ្លុះបញ្ចាំង និងមានភស្តុតាងគាំទ្រទៅលើប្រធានបទនោះ។

ឧទាហរណ៍ : ប្រធានបទមួយតម្រូវឱ្យយើងសរសេរពណ៌នាអំពីសត្វគោមួយក្បាល។ ដូច្នេះអ្នកសរសេរត្រូវពណ៌នាពីរូបរាងខាងក្រៅរហូតដល់គុណសម្បត្តិនិងគុណវិបត្តិរបស់វា ហើយក៏មិនត្រូវយកសត្វគោទៅប្រៀបធៀបជាមួយនឹងអ្វីផ្សេងដែរ។ គំនិតរបស់យើងនៅក្នុងការសរសេរតែងសេចក្តី គឺខុសដោយឡែកៗពីគ្នារវាងមនុស្សម្នាក់ និងមនុស្សម្នាក់ទៀត ប៉ុន្តែអ្នកសរសេរត្រូវគោរពប្រធានបទតែមួយ។ ការសរសេរនេះទៀតសោត មនុស្សម្នាក់ៗអាចមានគំនិតខុសគ្នាដែរក្នុងពេលដោយឡែកពីគ្នាទៅតាមការយល់ឃើញរបស់ខ្លួន។

តើតែងសេចក្តីទាមទារឱ្យសរសេរវែងអន្លាយឬទេ?

បញ្ហានេះពុំទាន់មានអ្នកណាកំណត់អំពីខ្នាតនោះទេ គឺអាស្រ័យទៅលើគំនិតអ្នកសរសេរប៉ុណ្ណោះ ថាតើអ្វីដែលគេសរសេររៀបរាប់នោះវាអស់ទៅលើគម្រោងព្រាងរបស់គេហើយឬនៅ? បើកាលណាអស់ហើយ សេចក្តីអធិប្បាយក៏នឹងបញ្ចប់ដែរ។ មានអ្នកសរសេរខ្លះទៀតអូសបន្លាយរហូតដល់៥ទៅ៦ទំព័រ តែដល់ពេលអានបែរជាគ្មានន័យសោះ។ ប្រសិនបើនៅក្នុងសំណេរឥតមានខ្លឹមសារ ហើយប្រាសចាកពីគោលការណ៍របស់ប្រធានបទនោះ ចំណុចនេះធ្វើឱ្យការបកស្រាយរបស់គេត្រូវទទួលបរាជ័យទាំងស្រុង។

ធម្មតាការអធិប្បាយលើតែងសេចក្ដីមួយ គួរឱ្យបានយ៉ាងហោច ណាស់ពី២ទៅ៣ទំព័រជាការសមរម្យ បើវែងគឺពី៤ទៅ៥ទំព័រជាកំណត់។ ពេលត្រូវសរសេរបកស្រាយយើងកុំខ្ជះខ្ជាយអារម្មណ៍ និងពេលវេលា ពោលគឺអារម្មណ៍របស់យើងត្រូវដិតជាប់នឹងប្រធានបទ ដើម្បីរៀបជា ប្លង់គោលនៅក្នុងខួរក្បាល។ អ្នកកុំរវល់ងាកឆ្វេង ងាកស្ដាំ ជជែកគ្នា អ៊ូអែដែលជាហេតុធ្វើឱ្យគម្រោងបានរៀបចំរួច ត្រូវរលត់ទៅវិញដោយ មិនបានសរសេរអ្វីបន្តិចនោះ។

សិស្សសាលាជាច្រើន តែងត្អូញត្អែរពីផលវិបាករបស់ខ្លួនក្នុង ការចាប់សរសេរតែងសេចក្ដីឱ្យបានល្អ។ ទាំងនេះក៏ព្រោះនៅក្នុងសេចក្ដី អធិប្បាយទាំងមូលរបស់គេចូលចិត្តប្រើពាក្យដដែលៗ សាចុះសាឡើង ដែលធ្វើឱ្យគំនិតនោះសម្លឹងទៅមានភាពស្មុគស្មាញពិបាកយល់។

ឧទាហរណ៍ : គេប្រើពាក្យ *ពោល* ឃើញថា នៅប្រយោគណាក៏ ឃើញមានពាក្យនេះរហូតដល់ចប់ នេះជាបញ្ហាដែលប្រឈម។ ឯមួយ ទៀត គឺការសរសេរខ្លីពេកពុំអស់ន័យសេចក្ដីដែលត្រូវនិយាយក៏ស្រាប់ តែបញ្ចប់ទៅវិញ។ មានខ្លះទៀតការលើកឧទាហរណ៍មកបញ្ជាក់ គឺគ្មាន ឃ្លាភ្ជាប់សេចក្ដីឬសរសេរច្រាសទៅច្រាសមក ត្រលប់ទៅមុខត្រលប់ មកក្រោយ។

ការសរសេរតែងសេចក្ដី ពុំទាមទារឱ្យយើងសរសេរវែងអន្លាយ ហួសហេតុទេ តែក៏មិនតម្រូវឱ្យសរសេរតែកន្លះទំព័រហើយឱ្យឈ្មោះថា តែងសេចក្ដីនោះដែរ។ គេត្រូវលៃខ្នាតនៃការសរសេរឱ្យសមល្មមទៅតាម

ពេលវេលាដែលកំណត់និងត្រូវមានគ្រប់ចំណុចតូចៗនៃប្រភេទប្រធាន។

## និយមន័យតែងសេចក្តី

ពាក្យថា តែងសេចក្តី អ្នកសិក្សាតែងបានឮហើយបានសរសេរនៅពេលមានកិច្ចការប្រលងគ្រប់ៗគ្នា។ ដូច្នេះយើងក៏បានដឹងខ្លះៗមកហើយដែរនូវពាក្យថា តែងសេចក្តីៗ

តើអ្វីទៅជាការ តែងសេចក្តី?

តែងសេចក្តីចេញមកពីពាក្យថា "តែង + សេចក្តី"

៱ តែង : តាមន័យក្នុងវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ **ជួន-ណាត** ថា រៀបចំ, ស្អិតស្អាង, តាំងបង្កើត។

មតិខ្លះទៀតនិយាយថា តែង គឺការរចនាអ្វីមួយឱ្យប្លែកឱ្យល្អលើសពីធម្មតា ហើយឱ្យអ្នកដទៃចាប់អារម្មណ៍ដោយការរចនានោះ។ ការតែងមានគោលបំណងឱ្យគេស្រលាញ់ពេញចិត្ត ឱ្យគេមើលហើយចង់មើលទៀត រួចលាន់មាត់សរសើរពីសមិទ្ធផលដែលយើងបានតែងឬស្អិតស្អាងនោះ។ ដូច្នេះដើម្បីតែងឱ្យបានល្អ អ្នកតែងត្រូវចេះរៀបចំលៃយ៉ាងណាពិនិត្យកុំឱ្យមានឆ្គងឬមានមន្ទិល។

ដោយឡែកពាក្យពេចន៍ ប្រើក្នុងការសរសេរអធិប្បាយគឺកុំប្រើពាក្យដែលខ្ពស់ហួសសមត្ថភាពរបស់ខ្លួនឬជាពាក្យវប្បធម៌ជ្រៅពេក។

៱ សេចក្តី តាមន័យក្នុងវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ **ជួន-ណាត** ថា ដំណើរ, ហេតុ, ការណ៍, គតិ, លំអាន, ផ្ទៃរឿង,

គ្មាម, ដំណើរពាក្យ។

មតិខ្លះទៀតនិយាយថា សេចក្តី គឺជាអត្ថបទមួយដ៏វែងអន្លាយ មានខ្លឹមសារស្រួលស្តាប់ប្រកបដោយសោភណភាពនៃអក្សរសាស្ត្រដ៏សមសួន។

សរុបមក តែងសេចក្តី គឺជាកម្រងអត្ថបទដែលសរសេរដោយមានការរៀបចំឃ្លាល្បះឱ្យមានសណ្តាប់ធ្នាប់ហើយស្អាត ដែលគួរជាទីចាប់អារម្មណ៍ពីសំណាក់អ្នកអាន ពោលគឺជាអត្ថបទពេញលក្ខណៈហើយមានន័យគ្រប់គ្រាន់ ដែលអាចស្តាប់បាននិងយល់ពីបំណងអ្នកសរសេរថាចង់បង្ហាញអ្វីមួយដល់អ្នកអាន។

តែងសេចក្តីដែលមានសោភណភាពល្អ តើអ្នកសរសេរត្រូវរៀបចំធ្វើដូចម្តេច?

នេះជាចំណុចមួយដ៏ចាំបាច់ ដែលអ្នកសរសេរតែងសេចក្តីម្នាក់ៗត្រូវចៀសវាងការលុបក្រវេមក្រវាម ដែលធ្វើឱ្យអត្ថបទមើលទៅគ្មានសណ្តាប់ធ្នាប់និងនាំឱ្យបាត់សោភណភាពអស់។ ម្យ៉ាងទៀតគប្បីត្រូវគិតថា ផ្នែកធំៗរបស់តែងសេចក្តី (ផ្តើមសេចក្តី តួសេចក្តី បញ្ចប់សេចក្តី)។

អក្សរត្រូវសរសេរឱ្យច្បាស់ៗ មិនមែនសរសេរធំៗ ហៅថាច្បាស់នោះទេ។ អក្សរដែលច្បាស់ គឺអក្សរដែលកំណត់តួព្យញ្ជនៈ ស្រៈច្បាស់លាស់ មិនសរសេរបន្លំរបៀបស្ទាក់ស្ទើរនោះឡើយ មានន័យថា បើព្យញ្ជនៈ “រ” ត្រូវសរសេរឱ្យច្បាស់ បើស្រៈ “ះ” ត្រូវសរសេរឱ្យច្បាស់។ មុនពេលពន្យល់គេត្រូវចេះរៀបប្លង់ត្រួសៗសិនដើម្បីពន្យល់

តាមប្លង់ដែលបានរៀបនោះ ទើបមិនច្រលំ មិនលើស មិនខ្វះ គឺធ្វើបានគ្រប់ជ្រុងជ្រោយច្បាស់លាស់។ ដោយឡែកប្រធានពន្យល់ ប្រធានពិភាក្សា ប្រធាននិទស្សន៍គប្បីធ្វើប្លង់ត្រួសៗចាប់ពីតួសេចក្តីទៅ ចំណែកសេចក្តីព្រាងដែលត្រូវសរសេរឱ្យចប់ចុងចប់ដើមនោះ ត្រូវធ្វើតែលំនាំបញ្ហាជាការប្រសើរ។

## ការស្រាវជ្រាវឯកសារសម្រាប់សរសេរឱ្យបានល្អ

ឯកសារនានាសុទ្ធតែមានតម្លៃ សម្រាប់សរសេរតែងសេចក្តី ប៉ុន្តែត្រូវការឱ្យមានគំនិតច្នៃប្រឌិត ដើម្បីនឹងបានគុណប្រយោជន៍ដ៏មហាអស្ចារ្យពីឯកសារទាំងនោះ។

អ្នកខ្លះពោលដោយភន្តច្រលំថា បើមានឯកសារកំណែរបស់អ្នកនិពន្ធល្បីៗ តែមួយឬពីរក្បាលសម្រាប់រៀនសរសេរតែងសេចក្តីជាការគ្រប់គ្រាន់ណាស់ទៅហើយ តែតាមការពិតមិនដូច្នោះទេ។ ការសរសេរតែងសេចក្តីមួយបានល្អ ត្រូវទាមទារឱ្យយើងបង្កើតនូវឃ្លាប្រយោគថ្មីៗហើយសាមញ្ញ មានន័យសមរម្យសម្រាប់បង្ហាញខ្លឹមសារនៅក្នុងសំណេរនោះ។ យើងដឹងហើយថា គំនិតក្នុងការសរសេរតែងសេចក្តីមួយបើក្នុងបន្ទប់ប្រលងមានបេក្ខជន២៥នាក់ គំនិតនៃការសរសេរក៏មានរហូតដល់២៥គំនិតដែរ ប៉ុន្តែអ្វីដែលត្រូវដូចគ្នា គឺការគោរពប្រធានបទនិងគោលការណ៍សរសេរប៉ុណ្ណោះ។

ការសរសេរឱ្យបានល្អ គឺត្រូវពឹងលើសមត្ថភាពខ្លួនឯងឱ្យបានច្រើនទើបជាការប្រសើរ។ ការសរសេរតែងសេចក្តីមើលទៅហាក់ដូច

ជាងាយស្រួលណាស់ ព្រោះសរសេរទៅតាមគំនិតផ្ទាល់ខ្លួនដោយគ្រាន់តែបញ្ចេញបញ្ចូលទៅតាមព្រឹត្តិការណ៍ដែលមានស្រាប់ តែវាក៏ជារឿងមួយពិបាកណាស់ដែរសម្រាប់អ្នកដែលមិនយកចិត្តទុកដាក់ ព្រោះគេចូលចិត្តយកពេលវេលាទៅដើរកម្សាន្តជជែកគ្នាលេងដោយអត់ប្រយោជន៍។

ប្រភេទប្រធានតែងសេចក្តីខ្លះ ហាក់បីដូចជាឱ្យយើងរំឭកឡើងវិញពីអនុស្សាវរីយ៍របស់យើងដែលបានកន្លងហួសទៅ ទោះពេលឆាប់ឬពេលយូរ តែអ្វីជាអនុស្សាវរីយ៍របស់យើងនោះគឺយើងមិនសូវចាប់អារម្មណ៍ឡើយ។ នៅពេលសរសេរគេតម្រូវឱ្យយើងសរសេររំឭកឡើងវិញទាំងអស់។ អ្នកដែលចេះចាំរឿងរ៉ាវនោះនឹងសរសេរបានល្អព្រោះការសរសេរនេះ តម្រូវឱ្យចេះបញ្ចូលមនោសញ្ចេតនាឱ្យស្រស់បំព្រងពីរឿងអតីតកាលផងដែរ។

## វិធីដែលឈានទៅរកការចេះសរសេរតែងសេចក្តីបានល្អ

### ១- ត្រូវចេះរបៀបអាន

ឯកសារដែលបានបោះពុម្ពផ្សាយលក់លើទីផ្សារ ឬសរសេរដោយដៃ សុទ្ធតែមានតម្លៃយ៉ាងធំធេងដល់ការបណ្តុះបណ្តាលគំនិតសរសេររបស់យើង ហើយយើងត្រូវអានឱ្យបានច្រើនព្រោះការអាននឹងបណ្តុះគំនិតយើងឱ្យមានជាភាពរហ័ស និងទទួលបានពុទ្ធិថ្មីល្អៗដែលជាប្រយោជន៍យ៉ាងធំធេង ពោលគឺយើងនឹងចេះប្រើពាក្យប្លែកៗទំនើបដែលស្ថិតនៅក្នុងក្របខណ្ឌសីលធម៌មនុស្សជាតិ។

ការអាននេះទៀតសោតត្រូវដឹងថា តើយើងអានដើម្បីអ្វី?

អានដើម្បីតែអានឬអានដើម្បីឱ្យគេកោតសរសើរថា ខ្លួននេះស្រលាញ់ការសិក្សា? យើងត្រូវកំណត់ឱ្យច្បាស់ថា អត្ថបទមួយនេះនឹងមានពាក្យពេចន៍ល្អ ហើយមានប្រយោជន៍សម្រាប់យើងក្នុងពេលសរសេរតែងសេចក្ដីឬសរសេរអត្ថបទផ្សេងទៀត ដូចជាកាសែតវិភាគសង្គម ទស្សនាវដ្ដី ប្រលោមលោក ជាដើម។ អ្នកមានឯកសារច្រើនក៏ពិតមែន តែមិនបានអាននោះ គឺពិតជាអន់ជាងអ្នកមានឯកសារមួយក្បាលតែគេបានអានចប់សព្វគ្រប់ទៅទៀត។ ឧបមាថាមានសៀវភៅមួយក្បាល បើអ្នកមិនបានអានវាឱ្យចប់តាំងពីដើមទំព័រនោះទេ អ្នកមិនសមមានឈ្មោះថា ជាម្ចាស់សៀវភៅមួយក្បាលនោះឡើយ។

តើយើងត្រូវអានឯកសារនានានៅពេលណា?

សម្រាប់សៀវភៅបែបវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ អក្សរសាស្ត្រ ប្រលោមលោក កាសែត ទស្សនាវដ្ដី រឿងព្រេង ជាដើម។ សុទ្ធតែអាចអានបានគ្រប់ពេលវេលាគ្រប់ទីកន្លែងឱ្យតែមានពេលវេលាសមស្រប។

**២- ត្រូវចេះរបៀបស្ដាប់**

បុគ្គលណាក៏មានត្រចៀកសម្រាប់ស្ដាប់ដែរ តែទាស់ត្រង់ថា អ្នកខ្លះស្ដាប់ដើម្បីគ្រាន់តែឮនិងតបតទៅគេវិញមួយគ្រាប៉ុណ្ណោះ។ គេត្រូវចេះច្នៃការស្ដាប់ឱ្យមានប្រយោជន៍ និងស្ដាប់ដើម្បីចេះសរសេរត្រាប់ពីអ្វីដែលគេនិយាយមកជាអត្ថបទមួយវិញ។ ធម្មតាអ្នកនិយាយមិនត្រូវតាមកាលនៃសាច់រឿងទេ តែយើងជាអ្នកស្ដាប់ត្រូវចេះរៀបព្រឹត្តិការណ៍នោះទៅតាមលំដាប់លំដោយនៃសាច់រឿង។

ការសន្ទនារវាងមនុស្សមួយក្រុម ទោះពួកគេមានឋានៈជាអ្វីក៏ដោយក៏ការជជែករបស់ពួកគេ ប្រាកដជាមានពាក្យពេចន៍អក្សរសាស្ត្រណាមួយដែលល្អសម្រាប់យើងយកមកសរសេរពុំខាន។ កុំភ្លេចថាអ្នកទាំងនោះនឹងមានម្នាក់បានក្លាយជាគ្រូនៃគំនិត ដែលលេចចេញពាក្យពីរោះថ្លៃថ្នូរសម្រាប់យើងជាអ្នករៀនបានខ្ពង់ខ្ពស់ ហើយមិននឹកស្មានដល់ថា គាត់អាចនិយាយពាក្យនេះបានឱ្យយើងស្តាប់ឡើយ។

ទស្សនៈមួយបានលើកឡើងថា *"ដើរគ្នាបីនាក់ ប្រាកដជាមានម្នាក់អាចជាគ្រូរបស់យើង"*។ ចំណេះដឹងមានក្នុងគំនិតមិនដូចគ្នាទេ។ មានពេលខ្លះយើងចេះជាងគេ តែពេលខ្លះគេក៏ចេះជាងយើងដែរ។ អ្នកប្រសប់និងអ្នកចេះមានភាពខុសគ្នា។ អ្នកដែលចេះតែទ្រឹស្តីនិងអ្នកចេះអនុវត្តក៏ខុសគ្នាដែរ។ អ្នកមិនចេះអក្សរ អ្នកប្រមឹក អ្នកដែលមានវណ្ណៈតូចទាបក៏គង់អ្នកទាំងនោះអាចបង្រៀនយើងបានដែរ។ ធម្មជាតិឱ្យមនុស្សមានត្រចៀកពីរ មួយសម្រាប់ស្តាប់ខាងឆ្វេង មួយទៀតសម្រាប់ស្តាប់ខាងស្តាំ។ ការស្តាប់នេះនាំឱ្យមានគំនិតច្រើនសម្រាប់សរសេរជាអត្ថបទ។

ពាក្យសម្តីដែលមនុស្សគ្រប់រូបនិយាយចេញមក សុទ្ធតែចេញពីគំនិតពិចារណាយ៉ាងច្បាស់លាស់ទៅតាមការយល់ដឹងរបស់គេ ជួនកាលពាក្យសម្តីនោះនាំឱ្យអ្នកស្តាប់ស្មៀបរមាស់ត្រចៀកបន្តិចមែន តែវាក៏ជារ៉ែមួយដែលត្រូវការយើងយកមកច្នៃ ដើម្បីបានជាពេជ្រនៅថ្ងៃណាមួយដែរ។ វិញ្ញាណរបស់យើងជាដៃគូនិយាយជាមួយនឹងគេឬបាន

ស្តាប់នោះ គឺមិនបានចាំទាំងអស់ឡើយ តែយ៉ាងហោចណាស់ក៏អាចចាំពីមូលន័យដែលគេនិយាយដែរ។ ចូរចាត់ទុកពាក្យសម្តីអ្នកនៅជុំវិញខ្លួនជាញាណអារម្មណ៍របស់យើង ហើយត្រូវចំណាយពេលស្តាប់គេបន្តិចសិនបើអាចធ្វើទៅបាន ហើយយើងក៏មិនត្រូវបង្អាក់ឬគិតថា ពាក្យសម្តីនេះមិនសមដល់យើងនោះឱ្យសោះ។

**៣- ត្រូវចេះរបៀបទស្សនា**

ទស្សនា គឺជាគន្លឹះពិសេសក្នុងការដោះស្រាយបញ្ហានៃការសរសេរហើយទាមទារឱ្យយើងចេះតាមដាន និងសង្កេតអំពីដំណើរដើមចមពីក្បាលដល់កន្ទុយដោយយកចិត្តទុកដាក់។

ការទស្សនានេះមានដូចជា ទស្សនាភាពយន្ត ការសម្តែងនានានៅលើឆាកដោយមានប្រើពាក្យសម្តីផ្តោះផ្តងគ្នា ឬការមើលឃើញពីសកម្មភាពនានានៅក្នុងសង្គមនិងមជ្ឈដ្ឋានរស់នៅជុំវិញខ្លួន។ នៅពេលអ្នកចេះចាប់អារម្មណ៍ពីសកម្មភាពនៅជិតខ្លួន ពេលនោះគឺជាវិធីដ៏ល្អមួយជួយសម្រួលគំនិតយើងឱ្យរឹតតែប្រសើរ និងទទួលបានព័ត៌មានថ្មីសម្រាប់ដុសខាត់គំនិតសរសេរឱ្យមានភាពល្អប្រសើរថែមទៀតដែរ។

អ្នកនិពន្ធម្នាក់ ដើម្បីសរសេរប្រលោមលោកមួយទាក់ទងដល់ខ្សែជីវិតដ៏អភ័ព្វរបស់មនុស្សម្នាក់ទៀត លុះត្រាតែគាត់បានដឹងពីជីវិតរស់នៅរបស់មនុស្សដែលមានខ្សែជីវិតរបៀបនេះឱ្យបានច្រើន និងត្រូវយកសកម្មភាពនោះមកច្របាច់បញ្ចូលគ្នា រើសយកមូលបញ្ហាចម្បងមួយទើបអាចចងក្រងវណ្ណកម្មនោះបាន។

## ៤- ត្រូវចេះរបៀបកត់ត្រា

បន្ថែមទៅពាចំណុចខាងលើ យើងត្រូវកត់ត្រាជាសៀវភៅកំណត់ហេតុមួយទៀតទើបជាការប្រសើរ។ ការកត់ត្រានឹងជួយយើងរំឭកឡើងវិញនូវព្រឹត្តិការណ៍ទាំងឡាយ ដែលកន្លងហួសទៅនោះឱ្យមានការចងចាំឡើងវិញ។

ការសរសេរចូលទៅក្នុងសៀវភៅកំណត់ហេតុ គឺត្រូវមានចុះកាលបរិច្ឆេទច្បាស់លាស់ រួមនឹងប្រភពផ្តល់ព័ត៌មានទើបជាការប្រសើរ។ ប្រសិនបើយើងពុំបានកត់បញ្ចូលកាលបរិច្ឆេទច្បាស់លាស់ រួមនឹងប្រភពព័ត៌មាននោះទេ កំណត់ហេតុយើងនឹងក្លាយទៅជាកំណត់ហេតុគ្មានន័យទាំងអស់ ព្រោះពេលដែលយើងចាប់សរសេរអត្ថបទស្រាវជ្រាវដែលជាប់ទាក់ទងនឹងកំណត់ហេតុនោះ យើងពិបាកដាក់ឯកសារសម្អាងណាស់ ហើយពុំអាចយកជាការបានឡើយពេលមានតម្រូវការចាំបាច់។

ការសរសេរតែងសេចក្តី ពិសេសនៅចំណុចលើកឧទាហរណ៍ក្នុងសង្គម ដែលទាមទារឱ្យយើងលើកពីអ្វីដែលមានពិតក្នុងសង្គមមកបង្ហាញ។ ការសរសេរនេះវាមិនទាមទារឯកសារឱ្យបានច្បាស់លាស់មួយរយភាគរយនោះទេ តែវាទាមទារនូវការពិត។ ការពិតនោះគឺស្រង់យកតថភាពនៃព្រឹត្តិការណ៍ក្នុងសង្គមឬអត្ថបទណា ដែលយើងបានអានបានស្តាប់ឬទស្សនាមកបង្ហាញ។ សៀវភៅកំណត់ហេតុមិនត្រឹមតែមានប្រយោជន៍ចំពោះការសរសេរអត្ថបទស្រាវជ្រាវ និងការសរសេរតែងសេចក្តីរបស់យើងឱ្យបានល្អប៉ុណ្ណោះទេ តែវាក៏ជាសៀវភៅកម្រង

អនុស្សាវរីយ៍មួយសម្រាប់ឱ្យយើងបើកមើល វាជាសេចក្ដីរំឭកពីរឿងរ៉ាវដែលកន្លងផុតទៅកុំឱ្យភ្លេចបាត់បង់ទៀតផង។

គេនិយាយថា "មនុស្សដែលមានសៀវភៅកំណត់ហេតុសម្រាប់កត់ចំណាំពីរឿងផ្ទាល់ខ្លួនឬព្រឹត្តិការណ៍ផ្សេងៗទៀតក្នុងសង្គម ជាមនុស្សដែលមានមនោសញ្ចេតនាជ្រៅជ្រះ និងចូលចិត្តចងចាំរឿងហេតុក្នុងអតីតកាល"។

**៥- ត្រូវចេះរបៀបចងចាំ**

ប្រការដែលតម្រូវឱ្យយើងចងចាំនេះ គឺល្អណាស់ព្រោះវាធ្វើឱ្យមានភាពងាយស្រួលសម្រាប់សរសេរអត្ថបទនានាឱ្យបានល្អ។

អ្នកសិក្សាតោងកុំមានទុដ្ឋិដ្ឋិនិយមថា ខ្លួនមិនចេះ ខ្លួនមិនចាំអ្វីទាំងអស់ឬរៀនមុខភ្លេចក្រោយអី។ យើងត្រូវបង្កើនគុណភាពចងចាំរបស់យើងជាលំដាប់។ នៅពេលណាមួយអ្នកនឹងមានពេលសមស្របសម្រាប់រំឭកវាជាពុំខាន។ មានពេលខ្លះអ្នកកំពុងតែនិយាយគ្នាក៏មានរឿងអ្វីមួយជាប់ទាក់ទងនឹងព្រឹត្តិការណ៍ដែលអ្នកសរសេរ អ្នកពិតជាអាចនិយាយរំឭកភ្ជាប់ព្រឹត្តិការណ៍នោះដែរពុំខាន នេះជាការពិតដែលមនុស្សជាច្រើនធ្លាប់បាននិយាយសារភាពថា ខ្លួនបានធ្វើយ៉ាងនេះជារឿយៗ។ ការធ្វើបែបនេះជាការចងចាំរបស់អ្នក ចូរអ្នករៀនចងចាំអ្វីដែលមានប្រយោជន៍ពីឥឡូវនេះទៅ។

បង្កើនការចងចាំ ប្រៀបដូចជាការពត់ឫស្សីមួយដើមឬប្រៀបដូចជាវិចិត្រករ ដែលកំពុងតែរចនារូបភាពរបស់ខ្លួនយ៉ាងយកចិត្តទុកដាក់

ដូច្នេះដែរ ពោលគឺត្រូវធ្វើដោយសន្សឹមៗ។ នៅពេលមានឱកាសល្អ គួរមានពេលមួយ ដើម្បីធ្វើសមាធិរំឭកឡើងវិញនៃមេរៀនដែលរៀនរួចហើយឬពីអ្វីដែលបានជួបពីអតីតកាល។ អ្នករៀនត្រូវតាំងចិត្តឱ្យសប្បាយកុំសួរខ្វល់ខ្វាយច្រើនពេក។ មានពេលដែលត្រូវកាន់គម្ពីរ មានពេលសម្រាប់ដើរលម្ហែ ឬមានពេលសម្រាប់ធ្វើកិច្ចការផ្សេងៗ ដើម្បីបន្ធូរភាពតានតឹង ពិសេសគឺវាអាចបង្កើនការចងចាំរបស់យើងឱ្យបានល្អថែមទៀតផង។

**៦- ត្រូវចេះរបៀបសរសេរ**

សមិទ្ធផលទាំងឡាយ កើតជារូបរាងឡើងដោយការប្រតិបត្តិហ្វឹកហាត់អនុវត្តជាប្រចាំ បើពុំដូច្នេះទេមនុស្សពុំអាចកសាងអ្វីដែលជាស្នាដៃរបស់ខ្លួនទុកជាមត៌កសម្រាប់មនុស្សជំនាន់ក្រោយបានឡើយ។

និពន្ធសៀវភៅមួយក្បាល មិនមែនសរសេរតែមួយថ្ងៃឬពីរថ្ងៃបានសម្រេចគោលដៅនោះទេ គឺត្រូវចំណាយពេលអស់ច្រើនថ្ងៃខែទើបអាចកសាងស្នាដៃនោះបាន។

ចំពោះអ្នកសិក្សារៀនសូត្រ ដើម្បីក្លាយខ្លួនជាសិស្សពូកែបានលុះត្រាតែសិស្សនោះឯង ខំសិក្សាស្វែងយល់លើគ្រប់មេរៀនជាប្រចាំ។ យ៉ាងណាមិញ ក្នុងការសរសេរតែងសេចក្ដីមិនមែនគ្រាន់តែអានឯកសារឱ្យបានច្រើន ស្ដាប់ឱ្យបានច្រើនជាការស្រេចនោះទេ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺត្រូវហាត់សរសេររៀបជាឃ្លាប្រយោគដោយប្រើប្រាស់ពាក្យពេចន៍ឱ្យបានសមស្របនិងថ្លៃថ្នូរទៀតទើបបាន។

ការសរសេរតែងសេចក្ដី មានភាពងាយស្រួលសម្រាប់យើង ដែលយកចិត្តទុកដាក់សិក្សា តែសម្រាប់អ្នកដែលមិនសូវចាប់អារម្មណ៍ គឺលំបាកខ្លាំងណាស់។ អ្នកត្រូវចងចាំថា ការសរសេរតែងសេចក្ដីគ្រប់ប្រភេទប្រធានសុទ្ធតែមានគម្រោងត្រឹមត្រូវ គឺមិនមែនចេះតែសរសេរឱ្យវែងៗ លើកឧទាហរណ៍ច្រើនៗឱ្យឈ្មោះថា តែងសេចក្ដីដែរនោះទេ។ តែងសេចក្ដីគ្រប់ប្រភេទប្រធានទាំងអស់ សុទ្ធតែមានចំណុច៣ធំៗដោយខានមិនបាននៅក្នុងការសរសេរ, ចំណុចទាំង៣មាន :

*១- សេចក្ដីផ្ដើម*

*២- តួសេចក្ដី*

*៣- សេចក្ដីបញ្ចប់*

ប្រសិនបើយើងសរសេរដោយគ្មានផ្ដើមសេចក្ដីនោះ គេច្រើនប្រៀបប្រដូចទៅនឹងមនុស្សពិការអ៊ីចឹង គឺខ្វះសេចក្ដីផ្ដើម មានន័យថា ខ្វះការទាញអារម្មណ៍អ្នកអានឱ្យចាប់អារម្មណ៍ ទៅសេចក្ដីបកស្រាយនៅផ្នែកតួសេចក្ដី។

សេចក្ដីបញ្ចប់ ជាការបូកសរុបលទ្ធផលយើងបានបកស្រាយកន្លងទៅនៅផ្នែកតួសេចក្ដី។

គេមិនត្រូវបញ្ចប់តែងសេចក្ដីមួយដោយខ្វះចំណុចនេះ ឬខ្វះចំណុចនោះបានឡើយ។ ដូច្នេះការបកស្រាយត្រូវតែចេះរបៀបសរសេររំលេចឱ្យឃើញចំណុចទាំង៣នេះគ្រប់ករណីទាំងអស់។

*ក- សេចក្ដីផ្ដើម* : ជាប្រយោគដែលយើងស្ថាបនាឡើងដើម្បី

នាំអារម្មណ៍អ្នកអានឱ្យតាមដានសេចក្តីពិស្តារនៅតួសេចក្តីទៀត។ ការសរសេរត្រូវរៀបចំគំនិតថ្មីៗ ហើយឱ្យស៊ីជម្រៅទៅលើប្រធានបទ។ នៅសេចក្តីផ្តើមនេះមិនទាមទារឱ្យមានការបរិយាយវែងពេកទេ ព្រោះជាការសរសេរគ្រាន់តែទាក់ទាញអារម្មណ៍អ្នកអានប៉ុណ្ណោះ។ ការសរសេរសេចក្តីផ្តើមយកល្អគួរសរសេរយ៉ាងច្រើនត្រឹម១០បន្ទាត់ ហើយក៏គួរកុំឱ្យខ្លីជាងនេះពេកដែរ។

***ខ- តួសេចក្តី*** : ជាការបកស្រាយឱ្យពិស្តារលម្អិតទៅលើប្រធានដែលបានចោទ។ អ្នកសរសេរត្រូវប្រមូលផ្តុំគំនិតជាមុន រួចសរសេរតាមលំដាប់លំដោយពីព្រឹត្តិការណ៍រឿង ដែលត្រូវបំភ្លឺតាមលេខរៀងរហូតដល់ចប់ តែត្រូវមានហេតុផលជាឧទាហរណ៍ដើម្បីគាំទ្រគំនិតនោះផង។ ការបកស្រាយនៅផ្នែកតួសេចក្តីនេះ ខុសគ្នាដោយឡែកៗទៅតាមប្រភេទប្រធានដែរ។

***គ- សេចក្តីបញ្ចប់*** : ជាផ្នែកចុងក្រោយបំផុតនៃការបកស្រាយតែងសេចក្តី។ វាជាការបូកសរុបធំ ហើយក្តោបរួមទៅលើការបកស្រាយនៅផ្នែកតួសេចក្តី។ សេចក្តីបញ្ចប់ពុំតម្រូវឱ្យអ្នកសរសេរវែងឆ្ងាយដូចតួសេចក្តីឡើយ ហើយត្រូវឱ្យស៊ីចង្វាក់ទៅនឹងប្រធានបទ ដែលបានចោទនិងបកស្រាយកន្លងទៅ។អ្នកសរសេរត្រូវមានវេលាដ៏សមរម្យសម្រាប់សរសេរបញ្ចប់ដោយមិនឱ្យតក់ក្រហល់។

## ប្រធានពណ៌នា

ប្រធានប្រភេទនេះ តម្រូវឱ្យចេះសរសេរបង្ហាញពីរូបរាងភិនភាគរបស់វត្ថុ មនុស្ស សត្វ ទីកន្លែង សកម្មភាព បាតុភូតធម្មជាតិណាមួយដែលបានកើតឡើងជាក់ស្តែង ទៅតាមលំដាប់លំដោយនៃពេលវេលា និងទីកន្លែងដែលបានកើតព្រឹត្តិការណ៍រឿងនោះ។

នៅក្នុងការបកស្រាយប្រធានបែបនេះ តម្រូវឱ្យអ្នកសរសេរចេះសង្កេតទៅលើអ្វីដែលខ្លួនពណ៌នាឱ្យបានច្បាស់លាស់ ហើយត្រូវស្គាល់ឬឆ្លងកាត់ព្រឹត្តិការណ៍នោះថែមទៀត ទើបងាយស្រួលនៅក្នុងការសរសេរទាក់ទាញអារម្មណ៍អ្នកអាន ឱ្យមើលឃើញពីសកម្មភាពឬព្រឹត្តិការណ៍នោះហាក់ដូចជាមាននៅចំពោះមុខរបស់ពួកគេ។ បន្ថែមលើការពណ៌នានេះ អ្នកសរសេរត្រូវបង្ហាញអំពីចិត្តគំនិតឬមនោសញ្ចេតនាទៅលើអ្វីដែលខ្លួនបាននិយាយរៀបរាប់នោះផង ទើបអានទៅមានភាពច្បាស់លាស់ឥតមានស្រពេចស្រពិល។

ពាក្យ "ពណ៌នា" នៅក្នុងវចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជ **ជួន-ណាត** ប្រែថា ពាក្យពោលរៀបរាប់, ពាក្យអធិប្បាយសេចក្តី, អដ្ឋកថា។ បើយោងតាមការបកស្រាយបែបនេះមានន័យថា ដើម្បីពោលពាក្យ

រៀបរាប់ឱ្យបានល្អនោះ អ្នកសរសេរត្រូវចេះរៀបរាប់ឱ្យបានសមស្រួន ចេះច្បិចយកចំណុចណាដែលច្បាស់លាស់មកបកស្រាយ ហើយចេះ ប្រើគំនិតផ្ទាល់ខ្លួនសម្រាប់ឱ្យការបកស្រាយនោះ បានទទួលការចាប់ ចិត្តជិតអារម្មណ៍ពីអ្នកអាន។ អ្នករៀបរាប់នោះត្រូវមានភាពប៉ិនប្រសប់ ហើយមានភាពឈ្លាសវៃនៅក្នុងការបន្ថែមសេចក្តី ដោយមិននិយាយ បញ្ជ្រោសព្រឹត្តិការណ៍រឿងឡើយ។ ប្រធានបែបពណ៌នាមានច្រើនប្រភេទ។

ខាងក្រោម យើងនឹងសិក្សាលម្អិតទៅលើប្រធានទាំងនេះម្តង មួយៗទៅតាមលំដាប់លំដោយ ព្រមទាំងមានភ្ជាប់នឹងប្រធានគំរូសម្រាប់ បកស្រាយខ្លឹមសារផងដែរ។

## ១- ប្រធានពណ៌នាអំពីមនុស្ស

ប្រធានប្រភេទនេះ តម្រូវឱ្យចេះសរសេរបង្ហាញច្បាស់លាស់ពី ភិនភាគរូបសម្បត្តិរបស់មនុស្សណាម្នាក់ដែលបានស្គាល់ បានឃើញ ប្រាប់ទៅនរណាម្នាក់ឬច្រើននាក់ឱ្យបានដឹង និងបានស្គាល់តាមរយៈ ការពណ៌នានេះដែរ។ អ្នកត្រូវចេះសរសេររៀបរាប់ឱ្យអ្នកអានហាក់ ឃើញផ្ទាល់ភ្នែក ពីមនុស្សដែលយើងលើកយកមកពណ៌នាឬសរសេរ តាមរយៈរូបារម្មណ៍។

### គម្រោងសរសេរប្រធានពណ៌នាអំពីមនុស្ស

**ក- សេចក្តីផ្តើម** : បង្ហាញពីឈ្មោះ ភេទ អាយុ មុខរបរ លំនៅ (បើការពណ៌នានោះតម្រូវឱ្យនិយាយអំពីសិស្សសាលា ត្រូវបង្ហាញពីទី កន្លែងសិក្សាផង)។

**ខ- តួសេចក្តី** : នៅផ្នែកនេះត្រូវសរសេរលើចំណុចធំៗ២៖

❖ **ពណ៌នារូបសម្បត្តិ** : បង្ហាញពីមាឌ កម្ពស់ សម្បុរ សក់ ភ្នែក ច្រមុះ បបូរមាត់ ដៃជើង ការស្លៀកពាក់ ការនិយាយស្តី ទំនាក់ទំនងក្នុងសង្គមជាដើម។

❖ **ពណ៌នាចរិយាសម្បត្តិ** : ជាមនុស្សយកចិត្តទុកដាក់លើការងារឬទេ? ការគោរពវិន័យសាលា ច្បាប់ទម្លាប់ស្រុកទេស មានសាមគ្គីភាពក្នុងការរស់នៅ សន្តានចិត្ត (ចិត្តល្អឬចិត្តអាក្រក់)។

🕮 ***ចំណាំ*** : បន្ទាប់ពីពណ៌នាចរិយាសម្បត្តិចប់ គេត្រូវភ្ជាប់គុណវិបត្តិបន្តិចនៅក្នុងការបកស្រាយនោះផង តែមិនត្រូវសរសេររៀបរាប់វែងពេកទេ។

**គ- សេចក្តីបញ្ចប់** : បង្ហាញមនោសញ្ចេតនារបស់អ្នកសរសេរទៅលើជននោះនិងបញ្ជាក់ហេតុផលឱ្យបានច្បាស់លាស់ផង។

**ប្រធាន** : *ប្អូនមានមិត្តម្នាក់ដែលប្អូនចូលចិត្តរាប់អានគេ។ ចូរប្អូនពិពណ៌នាអំពីមិត្តម្នាក់នោះ។*

### សេចក្តីអធិប្បាយ

ខ្ញុំមានមិត្តរួមថ្នាក់ម្នាក់ឈ្មោះ ***ជីតា*** ភេទស្រី នាងមានអាយុ១២ឆ្នាំ ជាសិស្សថ្នាក់ទី៧ “ក” នៃវិទ្យាល័យកំពង់ត្របែក។ ***ជីតា*** មានលំនៅនៅភូមិឃុំស្រុកខេត្តជាមួយនឹងខ្ញុំដែរ។ នៅសាលានាងជាសិស្សម្នាក់ពូកែប្រចាំថ្នាក់ទៀតផង។

*ជីតា* ជានារីដែលមានរូបរាងស្អាតជានិច្ច។ នាងមាន មាឌតូចល្មម មានចិញ្ចើមទាំងគូខ្មៅនិលនិងរោមភ្នែកកោងង សបញ្ជាក់ថា នាងជាមនុស្សដែលមានបញ្ញាដ៏ឧត្តម។ *ជីតា* មានច្រមុះតូចស្រួចបបូរមាត់ក្រហមស្ដើងតាមលក្ខណៈធម្មជាតិ និងជាមនុស្សដែលមានសេចក្ដីហ្មត់ចត់ក្នុងការងារមិនសូវនិយាយស្ដីច្រើន ហើយមានដៃជើងវែងល្មមសមនឹងដងខ្លួនរបស់នាង។ នៅសាលា *ជីតា* ស្លៀកសំពត់ខៀវ ពាក់អាវពណ៌ស ហើយទីនុយយ៉ាងស្អាតតាមវិន័យរបស់សាលា តែនៅផ្ទះនាងស្លៀកពាក់ធម្មតា ពេលទៅចូលរួមបុណ្យទាននាងស្លៀកពាក់ទៅតាមកម្មវិធីនោះដែរ។ *ជីតា* មានពាក្យសម្ដីស្រាលពីរោះគួរឱ្យចង់និយាយលេងជាមួយ និងជាទីរាប់អានពីបណ្ដាមិត្តភក្តិទាំងឡាយនៅក្នុងសាលាជាមួយគ្នាដែរ។ *ជីតា* មានចរិយាសម្បត្តិល្អណាស់ទាំងការសិក្សានិងការរស់នៅក្នុងសង្គម។ នាងតែងជួយកិច្ចការសង្គមនានាដូចជា ជួយសម្អាតទីធ្លាសាធារណៈនិងថែរក្សាទ្រព្យសម្បត្តិសាធារណៈជាដើម។ ចំណែកនៅថ្នាក់រៀន នាងគោរពវិន័យសាលាបានខ្ជាប់ខ្ជួន ហើយខំរៀនសូត្របានពូកែគ្រប់មុខវិជ្ជា ពិសេសពេលម៉ោងសិក្សានាងតែងតែយកចិត្តទុកដាក់ ស្ដាប់គ្រូពន្យល់មិនធ្វេសប្រហែសឡើយ។ ចំពោះការងារពលកម្មវិញទោះបីជានៅក្នុងសាលារៀនក្ដី នៅផ្ទះក្ដី នាងយកចិត្តទុកដាក់ធ្វើដោយសកម្ម ហើយមានស្មារតីទទួលខុសត្រូវខ្ពស់ទៅលើកិច្ចការផ្សេងៗរបស់ខ្លួន។ *ជីតា* មានចំណងសាមគ្គីទូលាយជាមួយនឹងមិត្តភក្តិនិងអ្នកជិតខាងរបស់នាងដែរ។ ហេតុដូច្នេះហើយ

ទើបនាងបានទទួលការស្រលាញ់រាប់អានជាច្រើន ពីសំណាក់មនុស្សទូទៅ។ នៅថ្នាក់រៀននាងបានជួយដាស់តឿនមិត្តភក្តិដែលមានការខ្វះខាតនៅក្នុងការសិក្សា និងការគោរពវិន័យសាលាឱ្យបានល្អឡើងវិញ។ ក៏ប៉ុន្តែនាងជាមនុស្សដែលមានចរិតកាចបន្តិច ហើយប្រកាន់ទស្សនៈអត្តនោម័តិនិយម។

តាមចរិតលក្ខណៈរបស់ ***ជីតា*** ខ្ញុំអាចសន្និដ្ឋានបានថា នាងជាសិស្សដ៏ល្អម្នាក់ ហើយជាទីសង្ឃឹមដ៏មុតមាំរបស់មាតាបិតា និងសង្គមជាតិ។ ខ្ញុំចូលចិត្តរាប់អាននាងណាស់ ហើយខ្ញុំជឿជាក់ថា នាងនឹងក្លាយទៅជាសសរទ្រូងដ៏រឹងមាំរបស់ជាតិទៅថ្ងៃអនាគត។

## ២- **ប្រធានពណ៌នាអំពីសត្វ**

ប្រធានប្រភេទនេះ តម្រូវឱ្យអ្នកចេះសរសេរពណ៌នាអំពីសត្វ មានលំនាំដូចប្រធានពណ៌នាអំពីមនុស្សដែរ តែទាមទារឱ្យអ្នកសរសេរចេះពិនិត្យតាមដានអំពីសត្វនោះដោយហ្មត់ចត់ និងត្រូវដឹងពីសកម្មភាពរបស់វាយ៉ាងពិតប្រាកដ ពិសេសគឺមានភាពស្និទ្ធស្នាលទៀតផង ព្រោះការពណ៌នានេះទាមទារឱ្យយើងនិយាយលម្អិតលើរូបរាង និងអត្តចរិតរបស់វា ដើម្បីឱ្យអ្នកអានហាក់ដូចជាឃើញសត្វនោះនៅនឹងភ្នែករបស់គេអ៊ីចឹងដែរ។

### គម្រោងសរសេរប្រធានពណ៌នាអំពីសត្វ

**ក- សេចក្តីផ្តើម** : បង្ហាញពីពេលវេលា ទីកន្លែង ឈ្មោះ អាយុ។

**ខ- តួសេចក្តី** : ត្រូវពណ៌នាពីចំណុចសំខាន់ៗចំនួន៤ ដូចជា៖

❖ **ពណ៌នាពីរូបសម្បត្តិ** : ត្រូវបង្ហាញពីកម្ពស់ សម្បុរ ក្បាលចំពុះ (បក្សី) ខ្លួនប្រាណ កន្ទុយ ជើង រោម ភ្នែក សំឡេង។

បន្ថែមពីលើនេះ ត្រូវសរសេរពីឥរិយាបថរបស់វាបន្ថែមទៀត ដូចជាដេក ដើរ ឈរ អង្គុយ រត់ លោត ជាដើម។

❖ **ពណ៌នាពីចរិយាសម្បត្តិ** : រៀបរាប់អំពីចរិតលក្ខណៈរបស់វាជាសត្វឧស្សាហ៍ឬខ្ជិល? ស្លូតឬកាច? ស្អាតឬកខ្វក់?

❖ **ការថែរក្សា** : តើយើងថែរក្សាសត្វនោះយ៉ាងដូចម្ដេចពេលវាឈឺឬពេលវាមានបញ្ហាផ្សេងៗក្នុងការរស់នៅរបស់វា។

❖ **ផលប្រយោជន៍** : ត្រូវនិយាយពីផលប្រយោជន៍របស់សត្វនោះ២ចំណុចសំខាន់ៗ៖

➢ ពេលវារស់ : ជួយជាកម្លាំងអូសទាញឬជួយឱ្យកំណើតដល់កូនសត្វដទៃទៀតឬក៏ជាអង្គរក្សរបស់យើង។

➢ ពេលងាប់ : ផ្ដល់សាច់ ស្បែក ឆ្អឹង ឈាម។

**គ- សេចក្ដីបញ្ចប់** : ត្រូវនិយាយអំពីចំណាប់អារម្មណ៍របស់យើងរួមនឹងមនោសញ្ចេតនាផ្ទាល់ខ្លួនចំពោះសត្វនោះ។

**ប្រធាន :** *គ្រួសាររបស់ប្អូនបានចិញ្ចឹមមាន់ជាច្រើនក្បាលនៅក្នុងនោះមានអាគកមួយជាមេហ្វូង។ ចូរប្អូនពណ៌នាពីមាន់គកនោះ។*

**សេចក្ដីអធិប្បាយ**

សព្វថ្ងៃនេះ ដើម្បីកែប្រែនិងដោះស្រាយជីវភាពឱ្យបាន

ល្អប្រសើរមួយកម្រិតទៀតនោះ គ្រួសាររបស់ខ្ញុំក្រៅពីមុខរបរធ្វើស្រែចម្ការនៅមានការចិញ្ចឹមមាន់ជាច្រើនក្បាលទៀត។ ក្នុងចំណោមមាន់ទាំងនោះមានមាន់គកមួយជាមេហ្វូង ហើយវាធ្វើឱ្យខ្ញុំពេញចិត្តវាជាងគេ។ គ្រួសាររបស់ខ្ញុំបានមូលមតិគ្នាដាក់ឈ្មោះវាថា ***អាស្អួយ*** ក៏ព្រោះតែវាមានសម្បុរដូចគ្រាប់ស្អួយហើយវាមានអាយុជិតមួយឆ្នាំហើយ។

ក្នុងចំណោមមាន់ជាច្រើនក្បាល ***អាស្អួយ*** មានភារកិច្ចជាមេហ្វូង។ ទោះបីវាមានអាយុតិចក៏ពិតមែន តែវាមានមាឌធំ រាងសង្ហា ហើយមានក្បាលធំសមនឹងដងខ្លួន។ វាមានចំពុះកោងខុបដូចចំពុះសេករួមនឹងភ្នែកមួយគូភ្លឺថ្លានិងមានពណ៌ក្រហមព្រឿងៗ។ នៅលើក្បាលវាមានសិរក្រហមឆ្អូតអង្កាញ់ៗមានសណ្ឋាន ដូចជាផ្កាសិរមាន់អ៊ីចឹងដែរ។ នៅក្រោមចំពុះដ៏មាំរបស់វាមានណង់មួយគូទន់ៗ ពណ៌ក្រហមជាំយារធ្លាក់ចុះមកក្រោមស្ពោក។ ពីក្បាលមកដងខ្លួនមានកមួយដ៏មាំ ខ្លួនទាំងមូលមានរោមសំកុលដុះប្រក់ពីលើរលោងស្រិលគួរឱ្យស្រលាញ់។

***អាស្អួយ*** មានគែធំធ្លាក់កំប្លុករលីងមិនសូវមានរោម ហើយមានពណ៌ក្រហមដូចផ្លែក្រៀល។ នៅជាប់នឹងដងខ្លួនរបស់វាមានស្លាបវែងៗមួយគូមាំហើយមានរោមសំឡីខ្លីឆ្មារៗ ដុះព័ទ្ធជុំវិញខ្លួនសម្រាប់ថែរក្សាកម្តៅនៅក្នុងខ្លួនរបស់វា។ ជើង ***អាស្អួយ*** មានស្រកាក្រាស់មាំ តែមិនវែងដូចជើងកុកឬខ្លីដូចជើងទានោះទេ។ វាមានភ្លៅធំមាំ ហើយជង្គង់របស់វាក្រោះដោយស្រការឹងនិងមានខ្នាយវែងស្រួចមួយគូ ដែលជាអាវុធដ៏ពិសិដ្ឋសម្រាប់ការពារខ្លួនវាឱ្យរួចផុតពីការឃាយីរបស់សត្រូវ។

***អាស្ពួយ*** ជាមាន់មួយក្បាលដែលមានឫកពាក្លាហានណាស់។ រាល់ព្រឹកខ្ញុំស្ទើរតែបើកទ្រុងមិនទាន់ឱ្យវាចេញ ព្រោះវារត់ឆ្លេឆ្លាពេញក្នុងទ្រុង។ លុះបានចេញមកក្រៅភ្លាម វាក៏លោតកញ្ឆក់កញ្ឆេងនៅក្នុងទីធ្លាខាងមុខផ្ទះ។ រួចទទះស្លាបរងាវជារឿយៗយ៉ាងពីរោះ។ វាជាសត្វរហ័សរហួននិងមានមារយាទក្រអឺតក្រទមសម្បើមណាស់ បណ្ដាមាន់ឈ្មោលទាំងឡាយនៅក្នុងហ្វូងមិនហ៊ានទៅរកស៊ីជិតវាទេ។ នៅពេល ***អាស្ពួយ*** ឃើញមេមាន់ណាមួយដែលវាពេញចិត្តជាងគេនោះ វាក៏តាំងកាងទម្លាក់ស្លាបម្ខាងចុះក្រោមរួចរត់កាច់រាង ក្រទីក្រទា ស្វែតចុះស្វែតឡើងជុំវិញមេញីនោះ។ ក្នុងពេលនេះ ប្រសិនមានមាន់ឈ្មោលណាហ៊ានមកក្បែរវានឹងជំឡើងឫទ្ធិដេញចឹក ដេញជល់គេឯងឥតបង្អង់ឡើយ។ ឫកក្រអឺតក្រទមនេះបានតែចំពោះមាន់ឈ្មោលដូចគ្នាប៉ុណ្ណោះ តែចំពោះមាន់ញីវិញវាខំយកចិត្តគេណាស់ ដូចជាពេលជួបចំណីវាតែងបង្រ្កុកហៅមេញីឱ្យមកស៊ី ហើយវាសុខចិត្តអត់ក៏បានដែរ។

ជ្បិត ***អាស្ពួយ*** មានចរិតក្រអឺតក្រទមពិតមែន តែគ្រួសារខ្ញុំនៅតែស្រលាញ់វាជានិច្ច បើគ្មានវាពងមាន់ទាំងឡាយច្បាស់ជាពុំអាចញាស់ជាកូនបានឡើយ។ រាល់ពេលទៀបភ្លឺ ***អាស្ពួយ*** តែងរងាវដាស់ខ្ញុំនិងប្អូនខ្ញុំឱ្យភ្ញាក់ឡើងទន្ទេញមេរៀន។ វារងាវទៀងពេលណាស់ វាប្រៀបដូចជានាឡិការោទ៍មួយ សម្រាប់ដាស់គ្រួសារខ្ញុំឱ្យក្រោកឡើងធ្វើការតាមទម្លាប់អ្នកស្រុកស្រែ។

រាល់ព្រឹកខ្ញុំតែងបោសសម្អាតទ្រុងវាដេកឱ្យស្អាតជានិច្ច ចៀស

វាងកើតជំងឺផ្សេងៗ ជាពិសេសជំងឺផ្តាសាយបក្សីដែលជាជំងឺដ៏សាហាវ ហើយអាចចម្លងមកមនុស្សនិងធ្វើឱ្យមនុស្សស្លាប់បានដែរ។ នៅពេលវាមានជំងឺម្តងៗ ខ្ញុំតែងបញ្ចុកថ្នាំឬចាក់ថ្នាំឱ្យវានិងប្រឹងព្យាបាលវារហូតជាសះស្បើយ។

***អាស្តួយ*** ពេលវានៅរស់ វាផ្តល់ប្រយោជន៍ច្រើនយ៉ាងណាស់ដល់គ្រួសារខ្ញុំ លុះពេលវាងាប់ វាក៏បានផ្តល់សាច់ដ៏មានរសជាតិសម្រាប់ធ្វើជាម្ហូបអាហារ ចំណែករោមរបស់វាអាចច្នៃធ្វើជាអំបោសទៀតផង។

មាន់គក មានសារៈសំខាន់ណាស់ដល់គ្រួសារកសិករខ្មែរទូទៅដែលនិយមចិញ្ចឹមមាន់សម្រាប់ធ្វើជាម្ហូបអាហារ និងលក់យកប្រាក់ដោះស្រាយជីវភាព។ កាលពីសម័យបុរាណមាន់គកត្រូវបានគេចាត់ទុកជានាឡិកាដ៏មានតម្លៃសម្រាប់ប្រាប់ពេលវេលា។ មិនត្រឹមតែប៉ុណ្ណោះ វាបានផ្តល់សាច់និងរោមឱ្យយើងប្រើប្រាស់ថែមទៀតផង។

## ៣- ប្រធានពណ៌នាអំពីវត្ថុ

ប្រធានប្រភេទនេះ តម្រូវឱ្យចេះសរសេររៀបរាប់យ៉ាងលម្អិតពីរបស់ដែលនៅជិតខ្លួន។ វត្ថុមានច្រើនដូចជា តុ ទូ ក្តារខៀន ទឹក ដី ភ្លើង ជាដើម រាប់ថាជាវត្ថុទាំងអស់។ ការរៀបរាប់តម្រូវឱ្យអ្នកត្រូវតែស្គាល់វត្ថុនោះជាចាំបាច់ បើសិនជាមិនស្គាល់ក៏មិនអាចរៀបរាប់បានដែរ។ មានពេលខ្លះទៀត ការរៀបរាប់ពីបន្ទប់រៀនឬបន្ទប់គេងក៏អាចចាត់ទុកជាវត្ថុបានដែរ។ ហើយអ្នកសរសេរត្រូវអនុវត្តតាមគម្រោងពណ៌នាអំពីវត្ថុនេះជាចាំបាច់ដែរដើម្បីឱ្យរំលេចបាននូវរូបរាងពិតរបស់វត្ថុនោះ។

## គម្រោងសរសេរប្រធានពណ៌នាអំពីវត្ថុ

**ក- សេចក្ដីផ្ដើម** : ប្រាប់ពីឈ្មោះវត្ថុនិងទីតាំងនៃវត្ថុនោះ។

**ខ- តួសេចក្ដី** : ប្រាប់ពីបរិវេណជុំវិញវត្ថុ រួចនិយាយអំពីរូបរាងនៃវត្ថុដោយប្រាប់ពីប្រភេទនីមួយៗដូចជា ទំហំ ពណ៌ ក្លិន...។

- ផលប្រយោជន៍របស់វត្ថុនោះ ចំពោះមនុស្សយកមកប្រើប្រាស់យ៉ាងណាដែរ? នៅចុងបញ្ចប់ក៏ត្រូវរៀបរាប់អំពីគុណវិបត្តិរបស់វាភ្ជាប់មកជាមួយបន្តិចដែរ។

**គ- សេចក្ដីបញ្ចប់** : បង្ហាញពីចំណាប់អារម្មណ៍ចំពោះវត្ថុនោះ។

**ប្រធាន** : *ចូរប្អូនពណ៌នាអំពីបន្ទប់រៀនរបស់ប្អូន ។*

### សេចក្តីអធិប្បាយ

ឆ្នាំសិក្សាថ្មីនេះ ខ្ញុំបានឡើងថ្នាក់ទី៨ “ក” នៃវិទ្យាល័យកំពង់ត្របែក។ បន្ទប់រៀនថ្មីរបស់ខ្ញុំមានសភាពស្អាតល្អប្រកបដោយផាសុកភាពគួរឱ្យចង់សិក្សាក្រៃលែង។

បន្ទប់រៀនថ្មីរបស់ខ្ញុំ មានសោភណភាពល្អប្រណីត។ នៅច្រកទ្វារចូល មានស្បៃវាំងននពណ៌ផ្កាឈូកលម្អទៅដោយក្រដាសពណ៌ប្រាក់កាត់ជាក្បាច់រចនាយ៉ាងស្រស់បំព្រង។ នៅពេលចូលទៅខាងក្នុងផ្នែកខាងឆ្វេងដៃ គឺក្ដារខៀនពណ៌សសម្រាប់សរសេរហ្វឺតភ្លឺរលោង នៅចំពីលើមានរៀបចំព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រ និងសរសេរបាវចនាជាអក្សរឆ្លាក់ធំៗថា “***ព្រះរាជាណាចក្រកម្ពុជា ជាតិ សាសនា***

*ព្រះមហាក្សត្រ*’ ព្រមជាមួយគ្នានោះក៏មានដាក់តាំងទង់ជាតិប្រាសាទកំពូលបីយ៉ាងល្អ ដើម្បីបញ្ជាក់ពីអត្តសញ្ញាណជាតិខ្មែរដែរ។ ចំពីមុខខ្ញុំដែលដើរចូលនោះ ជាតុគ្រូធ្វើអំពីឈើមួយនិងនៅក្បែរនោះគឺកៅអីឈើមួយ។ នៅលើតុគ្រូមានរៀបចំដាក់កម្រាលរំលេចដោយផ្កាមានពណ៌ល្អស្រស់ ហើយនៅពីលើ គឺថូផ្កាស្រស់បំព្រង។ នៅក្បែរនោះជាផែនទីពិភពលោកមួយផ្ទាំងធំដែរ ហើយនៅជញ្ជាំងផ្នែកខាងក្រោយតុគ្រូនោះ គឺតារាងព្យួរទាំងប្រាំបួនដែលរៀបចំរចនាយ៉ាងល្អផងដែរ។ តារាងនេះទុកសម្រាប់បិទចំណាត់ថ្នាក់ និងផ្តល់ព័ត៌មានផ្សេងៗទាក់ទងនឹងការសិក្សាដល់សិស្សនៅបន្ទប់រៀនខ្ញុំ។

ក្រឡេកទៅខាងស្តាំដៃ តុសិស្សមានរៀបចំជាបួនជួរ មានសណ្តាប់ធ្នាប់ណាស់។ គេរៀបចំតុដោយឱ្យរត់តាមខ្សែការ៉ូមានចន្លោះសមល្មម។ ជុំវិញជញ្ជាំងមានបិទពាក្យស្លោក សុភាសិតមានន័យសម្រាប់ដាស់តឿនក្រើនស្មារតីដល់ការសិក្សាប្រចាំថ្ងៃ របស់សិស្សានុសិស្ស។ នៅផ្នែកខ្លះមានបិទតាំងរូបភាព ដែលដកស្រង់ចេញពីសៀវភៅសិក្សា ហើយគូរដោយដៃសិស្សមានផាត់ពណ៌ល្អវិសេសណាស់។ ផ្ទាំងរូបភាពខ្លះសរសេរជារូបមន្តគណិតវិទ្យា រូបវិទ្យា គីមីវិទ្យាដែរ។ នៅលើដំបូលមានពិតានបិទជិត និងស្អាតល្អរៀបរយ ជាស្នាដៃរបស់សិស្សគ្រប់គ្នាដែលមិនឱ្យមានពីងពាងមកធ្វើសំបុកឡើយ។ ខាងក្រោយតុសិស្សមានទូដាក់សៀវភៅមួយហើយសរសេរអក្សរថា “*បណ្ណាល័យថ្នាក់*” នៅក្នុងនោះមានសៀវភៅជាច្រើនក្បាលដែរ ដូចជាសៀវភៅភាសាខ្មែរ

សៀវភៅប្រជុំរឿងព្រេងខ្មែរ សៀវភៅច្បាប់ សៀវភៅទំនៀមទម្លាប់ជាដើម។ ទីនេះសម្រាប់សិស្សពេលចេញលេងឬម៉ោងទំនេរពីការសិក្សាបានអានដើម្បីបង្កើនចំណេះដឹងបន្ថែមទៀត។

ប្រសិនបើក្រឡេកមើលនៅតាមបង្អួចវិញឃើញថា នៅផ្នែកខាងលើគ្រប់បង្អួចសុទ្ធតែរៀបចំតុបតែងយ៉ាងប្រណីតទាំងអស់ ដូចជាមានការកាត់ក្រដាសជាក្បាច់ ជាភ្ញី និងដាក់វាំងននជាការលម្អផងដែរ។ បង្អួចធំៗប្រកបដោយបរិយាកាសដ៏បរិសុទ្ធនេះនាំឱ្យអារម្មណ៍ខ្ញុំ ក៏ដូចជាសិស្សានុសិស្សទាំងអស់ពេញចិត្តនិងមានអារម្មណ៍ចង់សិក្សាក្រៃលែង។

ខ្ញុំពេញចិត្តនឹងការរៀបចំថ្នាក់នេះណាស់ ព្រោះវាធ្វើឱ្យខ្ញុំមានទឹកចិត្តរៀនសូត្រ នៅពេលឃើញបរិស្ថានជុំវិញស្អាតដូចនេះ។ ខ្ញុំក៏ដូចជាមិត្តរួមថ្នាក់ដទៃទៀតនឹងថែរក្សាបន្ទប់រៀននេះ ឱ្យស្អាតល្អដើម្បីផាសុកភាពយើងគ្រប់គ្នា។

## ៤- ប្រធានពណ៌នាអំពីរុក្ខជាតិ

ប្រធានប្រភេទនេះ តម្រូវឱ្យចេះសរសេររៀបរាប់លម្អិតពីព័ត៌មាននៃរុក្ខជាតិណាមួយឱ្យបានច្បាស់លាស់ ដើម្បីប្រាប់អ្នកអានឱ្យបានស្គាល់ដែរ។ ការពណ៌នាតម្រូវឱ្យអ្នកសរសេរអំពីរូបរាងខាងក្រៅរហូតដល់ផលប្រយោជន៍របស់វា។ ជួនកាលប្រធានតម្រូវឱ្យអ្នកសរសេររៀបរាប់ពីរុក្ខជាតិដែលដុះចម្រុះគ្នានៅទីណាមួយ។ ការពណ៌នាបែបនេះគេហៅថាជាការពណ៌នាអំពីទេសភាពទៅវិញ។ ការបកស្រាយមានលំនាំប្រហាក់ប្រហែលគ្នាទាស់ត្រង់ថា ការពណ៌នានេះ គឺតម្រូវឱ្យសរសេរ

ពីទិដ្ឋភាពរួមប៉ុណ្ណោះមិនបានលម្អិតអំពីរុក្ខជាតិមួយៗដែលដុះនោះទេ។

**គម្រោងសរសេរប្រធានពណ៌នាអំពីរុក្ខជាតិ**

**ក- សេចក្ដីផ្ដើម** : ប្រាប់ពីកន្លែង ឈ្មោះ និងអាយុនៃរុក្ខជាតិនោះ។

**ខ- តួសេចក្ដី** :

❖ បង្ហាញទិដ្ឋភាពពីចម្ងាយដូចជា : រូបរាង កម្ពស់ ពណ៌ មែកជាដើម។

❖ បង្ហាញទិដ្ឋភាពទៅដល់ : រូបរាង កម្ពស់ ពណ៌ មែក ស្លឹក ឫស គល់ ដើម ផ្កា ផ្លែ។

❖ ប្រាប់ពីផលប្រយោជន៍ : ការផ្ដល់ម្លប់ ផ្ដល់ផ្លែ ផ្នែកផ្សេងៗនៃរុក្ខជាតិដែលគេយកទៅប្រើប្រាស់ជាឱសថឬជាឧស។

❖ ថែរក្សា : ដាក់ជី ខំដាំបន្ថែម ជួយកម្ចាត់សត្វចង្រៃ។

**គ- សេចក្ដីបញ្ចប់** : ចំណាប់អារម្មណ៍ឬមនោសញ្ចេតនារបស់យើងចំពោះរុក្ខជាតិនេះ។

**ប្រធាន** : *នៅវត្តក្នុងភូមិរបស់អ្នកមានដើមពោធិ៍មួយយ៉ាងធំដុះក្នុងនោះ។ ចូរអ្នកពណ៌នាអំពីដើមពោធិ៍នោះ។*

**សេចក្ដីអធិប្បាយ**

វត្តប្រាសាទស្ថិតនៅក្នុងភូមិរបស់ខ្ញុំ មានដើមពោធិ៍មួយដើមយ៉ាងធំដុះនៅជិតព្រះវិហារ ដែលដើមពោធិ៍នេះមានអាយុកាលជាច្រើនឆ្នាំមកហើយ។ ចាស់ៗបាននិយាយថា វាមានអាយុរាប់

តំណមនុស្សមកហើយ ព្រោះថាពេលគាត់ធំដឹងក្តី គឺឃើញដើមពោធិ៍យ៉ាងធំនេះតែម្តង។

បើសម្លឹងពីចម្ងាយឃើញថា វាមានទំហំធំជង្គ្រាង មានមែកសាខាធ្លាក់ស្ទើរដល់ដី និងពោរពេញដោយស្លឹកពណ៌ខៀវស្រងាត់ មានសណ្ឋានដូចកូនភ្នំមួយលម្អដោយព្រៃឈើដ៏ក្រាស់ដូច្នោះ។ គេអាចប៉ាន់ស្មានថា វាមានកម្ពស់ប្រមាណម្ភៃទៅសាមសិបម៉ែត្រឬលើសពីនេះទៅទៀតផង។ វាជារុក្ខជាតិដែលមានទំហំធំជាងកង់រទេះគោទៅទៀត ហើយមានឫសរឃីងរឃោងចាក់ចុះមកដីតាមមែកនិងមានឫសខ្លះរុំព័ទ្ធជុំវិញគល់ដ៏ធំមហិមារបស់វាសម្លឹងទៅគួរឱ្យសម្ញើមណាស់។

ដើមពោធិ៍នេះ ពាសដោយស្លឹកពណ៌បៃតងចាស់និងមានផ្លែពណ៌ខ្មៅទុំរាយតាមមែកតូចៗជាជួរ ជាចំណីអាហារសម្រាប់បក្សាបក្សីមានគ្រលីងគ្រលោង សារិកាកែវ ពពិច ពពូលជាដើម។ ដើមពោធិ៍មានប្រយោជន៍ណាស់ គេអាចសកយកសំបករបស់វាមកធ្វើជាឱសថ ហើយត្រួយរបស់វា គេយកមកព្យាបាលជំងឺក្រពះបានយ៉ាងសក្តិសិទ្ធិទៀតផង ក្រៅពីនេះដើមឬមែករបស់វាដែលងាប់ស្ងួតគេអាចយកមកធ្វើជាឧសសម្រាប់ចម្អិនម្ហូបអាហារបានថែមទៀត។

ចំពោះប្រជាជនខ្មែរដែលជាអ្នកកាន់លទ្ធិពុទ្ធសាសនានោះ គេតែងមានជំនឿយ៉ាងមុតមាំថា ដើមពោធិ៍នេះជារុក្ខជាតិដែលព្រះពុទ្ធបានត្រាស់ដឹង ទើបពួកគេនាំគ្នាគោរពបូជាដើមពោធិ៍នេះគ្រប់ៗគ្នា។ ខ្លះទៀតមានជំនឿថា នៅដើមពោធិ៍មានអារក្ខ អ្នកតានៅថែរក្សាឱ្យសេចក្តីសុខ

ដល់គេ ទើបនាំគ្នាធ្វើរានទេវតាដាក់ក្រោមដើមរុក្ខជាតិនេះទុកជាទីសក្ការៈផងដែរ។ យើងមិនត្រូវកាប់បំផ្លាញប្រភេទរុក្ខជាតិនេះឡើយ ព្រោះវាបានរួមចំណែកក្នុងការកែលម្អបរិស្ថានសហគមន៍យើងឱ្យមានសភាពស្រស់បំព្រង ហើយគ្រប់គ្នាគួរជួយសម្អាតក្រោមដើមវាជានិច្ច ដើម្បីផ្តល់ភាពងាយស្រួលក្នុងការប្រារព្ធធ្វើពិធីផ្សេងៗ ដែលជាទំនៀមទម្លាប់របស់ខ្មែរយើង។

ខ្ញុំពេញចិត្តនឹងការដាំដើមពោធិ៍ណាស់ ព្រោះជាប្រភេទដើមឈើដែលផ្តល់ម្លប់ច្រើន ហើយជារុក្ខជាតិដែលផ្សារភ្ជាប់នឹងជំនឿខ្មែរយើងកាន់ព្រះពុទ្ធសាសនាថែមទៀតផង។

## ៥- ប្រធានពណ៌នាអំពីសកម្មភាព

ប្រធានប្រភេទនេះ តម្រូវឱ្យចេះសរសេររៀបរាប់ពីសកម្មភាពមួយបានកើតឡើងរួចទៅហើយ ឬជាអត្ថបទបង្ហាញពីចំណាប់អារម្មណ៍ ឬក៏ជាលទ្ធផលនៃការបូកសរុបកិច្ចការ។ អ្នកសរសេរត្រូវចេះរៀបរាប់ជាប្រយោគឃ្លោងឃ្លា ដើម្បីសមស្របតាមវត្ថុបំណងដែលប្រធានចង់បាន ពោលគឺសកម្មភាពនោះជាសកម្មភាពមួយដែលបានកើតឡើងពិតៗនៅក្នុងជីវភាពជាក់ស្តែងរបស់យើងមិនមែនជាសកម្មភាព ដែលបានមកពីការពង្រីកអត្ថបទអក្សរសិល្ប៍ឬប្រលោមលោកណាមួយនោះទេ។

ការធ្វើអធិប្បាយទៅលើប្រធានប្រភេទនេះ បានមកពីសកម្មភាពក្នុងអង្គប្រជុំ សិក្ខាសាលា ពលកម្មនៅទីសាធារណៈ បុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំ ការគោរពទង់ជាតិជាដើម។ អ្នកត្រូវសរសេរតាមលំដាប់

លំដោយនៃព្រឹត្តិការណ៍ដែលបានកើតឡើង តាំងពីចាប់ផ្ដើមរហូតដល់បញ្ចប់ទៅវិញ។

## គម្រោងសរសេរប្រធានពណ៌នាអំពីសកម្មភាព

**ក- សេចក្ដីផ្ដើម** : បង្ហាញពីពេលវេលា ទីកន្លែង វត្ថុបំណង (សកម្មភាពដែលត្រូវពណ៌នា)។

**ខ- តួសេចក្ដី** :

- ❖ បង្ហាញអំពីសកម្មភាពមុនពេលកើតហេតុ
- ❖ បង្ហាញពីសកម្មភាពកំពុងកើតហេតុ
- ❖ រំលេចឱ្យឃើញពីផលប្រយោជន៍នៃសកម្មភាពនោះ។

**គ- សេចក្ដីបញ្ចប់** : បង្ហាញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនទៅលើសកម្មភាពដែលបានពណ៌នាខាងលើរួចមកហើយ។

**ប្រធាន** : *ចូរប្អូនពណ៌នាពីការគោរពទង់ជាតិនៅសាលារៀនរបស់ប្អូន។*

## សេចក្ដីអធិប្បាយ

ព្រឹកនេះជាព្រឹកថ្ងៃចន្ទ។ ទ្រនិចនាឡិកាចង្អុលម៉ោងប្រាំមួយនិងសែសិបប្រាំពីរនាទី។ ស្នូរជួងបានបន្លឺឡើងយ៉ាងពីរោះរណ្ដំជាសញ្ញាប្រាប់ថា ដល់ម៉ោងគោរពទង់ជាតិហើយ។

ស្នូរជួងនេះ បានទាញអារម្មណ៍សិស្សទាំងអស់ដែលនៅគ្រប់កន្លែងក្នុងបរិវេណសាលាឱ្យមកជុំគ្នា។ ចលនាមួយដ៏គគ្រឹក

គគ្រេងបានកើតឡើង។ សិស្សបានចេញមកកាន់ទីធ្លាសាលា។ ខ្លះចេញពីអាហារដ្ឋាន ខ្លះចេញពីបន្ទប់រៀន ចំណែកអ្នកឃើតក៏ប្រញាប់ប្រញាល់យកកង់ ម៉ូតូទៅទុកតាមកន្លែង ហើយទាំងអស់គ្នាប្រញាប់ដើរទៅរកចំណុចមួយគឺដងទង់ជាតិ។ ពួកគេនាំគ្នាឈរតម្រៀបជាជួរយ៉ាងរៀបរយតាមទីកន្លែង ដែលបានកំណត់រួចជាស្រេចនៅកណ្ដាលទីធ្លាជុំវិញដងទង់ជាតិ។

ពីរនាទីក្រោយមក សភាពអ៊ូអរដែលលាន់ឮទ្រហឹងពីមុននេះក៏ស្រាប់តែស្ងប់ស្ងាត់ឈឹង។ នៅជុំវិញដងទង់ជាតិគេឃើញតែពណ៌ពីរដែលលេចចេញច្បាស់ជាងគេ គឺពណ៌ខៀវនិងពណ៌ស។ សិស្សគ្រប់រូបប្រដាប់ដោយឯកសណ្ឋានសាលា ឈរក្នុងកាយវិការប្រុងត្រង់ភ្លឹង។ ពេលនេះមានតែមែករុក្ខជាតិមានស្លឹកពណ៌បៃតងទេ ដែលមានចលនាយោលយោគតាមកម្លាំងវាយោត្រជាក់នៃរដូវរំហើយ។ សិស្សទាំងអស់ត្រៀមរួចជាស្រេច។ ភ្នែករាប់ពាន់បានបាញ់ឆ្ពោះទៅរកទង់ជាតិដែលមានរូបប្រាសាទកំពូលបី ចងភ្ជាប់ជាមួយនឹងដងទង់ពណ៌សឈរខ្ពស់ត្រដែតនៅលើខឿនតូបដែលមានអង្កត់ផ្ចិតប្រមាណជាពីរម៉ែត្រ។

រំពេចនោះសិស្សពីររូប ប្រុសមួយ ស្រីមួយបានចេញពីជួរមកឈរទល់មុខគ្នា រួចទើបដើរតម្រង់ទៅកាន់ដងទង់ជាតិដោយជំហានស្រុះគ្នាយ៉ាងស្វាហាប់។ អ្នកទាំងពីរមានភារកិច្ចបង្ហូតទង់ជាតិ។ បញ្ជាមួយដ៏ម៉ឺងម៉ាត់លាន់ឮក្រអៅកណ្ដាលភាពស្ងប់ស្ងាត់ ប្រុងប្រៀបគោរពទង់ជាតិ...! គោរព!...

គ្រាន់តែផុតបញ្ជាភ្លាមទង់ជាតិក៏ចាប់កម្រើកឡើង ហើយអណ្ដែតសន្សឹមៗតាមបណ្ដោយដងទង់រួមជាមួយនឹងបទចម្រៀងជាតិ ដែលច្រៀងដោយសិស្សានុសិស្សទាំងអស់។ ខណៈដែលទង់កំពុងបង្ហូតឡើងទាំងសិស្ស ទាំងគ្រូ បានងើបក្បាលសន្សឹមៗតាមសម្លឹងមើលរូបទង់ជាតិប្រាសាទកំពូលបីនៃព្រះរាជាណាចក្រកម្ពុជារហូតដល់កំពូលដងទង់។

ក្រោយពីបញ្ចប់ការគោរពទង់ជាតិ សិស្សានុសិស្សទាំងអស់ក៏សម្រួលឥរិយាបថដោយបានបំបែកក្រុម តែនៅរក្សាសណ្ដាប់ធ្នាប់ដើរជាជួរត្រលប់ទៅកាន់បន្ទប់រៀនរៀងៗខ្លួនវិញ។ មិនយូរប៉ុន្មានទីធ្លាសាលាក៏ប្រែជាមានសភាពស្ងាត់ឈឹង នៅសល់តែទង់ជាតិរលាស់ភឹបៗតាមកម្លាំងខ្យល់។ ស្នូរនេះហាក់ជាឧទានសព្ទស្រែកផ្ដាំក្រើនរំឭកដល់បុត្រធីតាខ្មែរឱ្យខិតខំរៀនសូត្រ និងកសាងខ្លួនក្លាយទំពាំងស្នងឫស្សីក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ។

ខ្ញុំពេញចិត្តនឹងការគោរពទង់ជាតិនេះណាស់ ព្រោះជាការបញ្ជាក់ឱ្យឃើញពីការគោរពបូជាជាតិ សាសនា ព្រះមហាក្សត្រ ទោះបីជាខ្ញុំមិនទាន់ធ្វើអ្វីជូនជាតិ យ៉ាងហោចណាស់ខ្ញុំក៏បានគោរពជាតិតាមរយៈការគោរពទង់ជាតិនេះដែរ។ ខ្ញុំនឹងខិតខំសិក្សាដើម្បីក្លាយជាអ្នកដែលមានចំណេះដឹង សម្រាប់ជួយកសាងជាតិឱ្យបានរីកចម្រើនខ្ពង់ខ្ពស់ដូចបណ្ដាប្រទេសជឿនលឿននៅលើពិភពលោក។

## ៦- ប្រធានពណ៌នាអំពីទេសភាព

ប្រធានប្រភេទនេះ តម្រូវឱ្យចេះសរសេររៀបរាប់ពីទិដ្ឋភាពនៃធម្មជាតិដែលមានការចូលរួមធ្វើសកម្មភាពរបស់មនុស្ស សត្វនៅកន្លែងណាមួយឬរមណីយដ្ឋានណាមួយឬក៏តាមបណ្តោយផ្លូវណាមួយ ដែលយើងកំពុងធ្វើដំណើរឆ្លងកាត់និងកំពុងដើរកម្សាន្តជាដើម។

នៅពេលដែលអ្នកស្ថិតនៅទីកន្លែងនោះ អ្នកត្រូវប្រើវិញ្ញាណទាំងប្រាំរបស់អ្នកដើម្បីយកមកប្រាប់អ្នកស្តាប់ អ្នកអានឱ្យបានឃើញពីអ្វីដែលអ្នកបានរៀបរាប់នោះដែរ ដូចជាយើងត្រូវប្រើភ្នែកសម្រាប់មើល ប្រើត្រចៀកសម្រាប់ស្តាប់ ប្រើច្រមុះសម្រាប់ស្រង់ក្លិន គួបផ្សំនិងមនោសញ្ចេតនារំភើបរបស់យើងជាដើម។ នៅក្នុងការពណ៌នាអ្នកសរសេរត្រូវប្រើពាក្យប្លែកៗ ដើម្បីឱ្យអត្ថបទរឹតតែល្អមានសោភណភាពរស់រវើកឡើង។ ការសរសេរត្រូវលៃយ៉ាងណាឱ្យអ្នកអានជក់ចិត្តជិតអារម្មណ៍ហាក់ដូចបានឃើញទិដ្ឋភាពទាំងនោះផ្ទាល់នឹងភ្នែករបស់គេដែរ។

### គម្រោងសរសេរប្រធានពណ៌នាអំពីទេសភាព

**ក- សេចក្តីផ្តើម** : បង្ហាញពីពេលវេលា ទីកន្លែងណាមួយដែលត្រូវធ្វើការសរសេរពណ៌នានោះ។

**ខ- តួសេចក្តី** :

- ❖ បង្ហាញទិដ្ឋភាពពីចម្ងាយ
- ❖ បង្ហាញទិដ្ឋភាពនៅពេលទៅដល់។

**គ- សេចក្តីបញ្ចប់** : បង្ហាញពីមនោសញ្ចេតនាផ្ទាល់ខ្លួន។

**ប្រធាន** : *រដូវវស្សាបានមកដល់ហើយ។ ចូរប្អូនពណ៌នាពីទេសភាពស្រុកស្រែនៅពេលព្រឹកនាររដូវដកស្ទូង។*

## សេចក្តីអធិប្បាយ

ពេលវេលាចេះតែកន្លងទៅ រដូវកាលមួយបានផ្លាស់ចូលរដូវកាលមួយទៀត។ មិនយូរប៉ុន្មានរដូវវស្សាក៏បានមកដល់ដែលជារដូវមួយតម្រូវឱ្យប្រជាកសិករខ្មែរចាប់ផ្តើមប្រកបរបរកសិកម្ម ធ្វើស្រែរបស់គាត់សាជាថ្មីឱ្យទាន់រដូវកាលដាំដុះនេះ។ កសិករនៅភូមិចំបក់ជាស្រុកកំណើតខ្ញុំក៏ដូចជាកសិករដទៃក្នុងប្រទេសកម្ពុជា គឺសប្បាយចិត្តនឹងការធ្វើស្រែវស្សានេះណាស់។ ព្រឹកព្រលឹមពេលដែលព្រះអាទិត្យបញ្ចេញពន្លឺក្រហមព្រឿងៗពីទិសបូព៌ា កសិករយើងរួសរាន់ម្ចីម្ចាដឹកនង្គ័លរនាស់ ដោយប្រើកម្លាំងអូសទាញដូចជា គោ ក្របី ហើយប្រឹងភ្ជួររាស់ស្រែយ៉ាងសកម្ម។ ឯធម្មជាតិនាពេលព្រឹកព្រលឹមនៅរដូវនេះប្រៀបដូចជា ឱសថទិព្វសម្រាប់ព្យាបាលដួងចិត្តអ្នកមានវិបត្តិឱ្យធូរស្រាលបាន។ នៅវាលស្រែដែលមានទឹកល្អក់ល្អាច មានមច្ឆាតូចៗហែលពន្លៀកលេងគួរឱ្យរមនា។ ចំណែកស្រែខ្លះទៀតមានសន្ទូងពណ៌បៃតងត្រង់នេះមួយស្រែ ត្រង់នោះមួយស្រែ លាតសន្ធឹងឆ្ងាយដាច់កន្ទុយភ្នែកខណ្ឌចែកគ្នាជាក្រឡាចត្រង្គ ដែលមានភ្លឺស្រែពណ៌ខ្មៅប្រផេះរត់ប្រទាក់គ្នាគួរឱ្យពិចពិលរមិលមើលពេកក្រៃ។ ភ្លៀងមួយមេកាលពីយប់មិញបានបន្សល់ដល់ព្រឹកឡើងនូវតំណក់ទឹក ដែលស្រក់ជាប់នៅលើស្លឹកស្រូវនិងស្លឹកស្មៅ ហើយវេលាដែលព្រះសូរ្យសែងនៃព្រះសុរិយាបានចាំងមក

ពេលនោះតំណក់ទឹកនេះក៏រំលេចពណ៌ប្រៀបដូចជា គ្រាប់ពេជ្រវាប់ម៉ឺន កំពុងដេញពន្លឺរន្ទាលចាំងតបតទៅវិញ តែគ្រាប់ពេជ្រនិមិត្តនេះនឹងរលាយទៅវិញនៅពេលណាពន្លឺនៃព្រះអាទិត្យបានភ្លឺច្បាស់មកផែនដី។

ដើមត្នោតរាងរាវឈរត្រង់បង្អួតរាងយ៉ាងសង្ហា តាមបណ្ដោយភ្លឺស្រែ ប្រៀបបាននឹងក្លស់រាប់រយពាន់កំពុងឈរបាំងការពារសន្ទូងដែលស្ងួងរួចកុំឱ្យត្រូវពន្លឺថ្ងៃ។ គយគន់ទៅឆ្ងាយបន្តិចស្រែខ្លះមានសន្ទូងកំពុងតែបែកគុម្ពពណ៌ខៀវស្រងាត់ រីឯស្រែខ្លះទៀតដែលទើបនឹងស្ទូងរួចក៏ចាប់លាស់សស្រាញ់ពណ៌បៃតងស្រស់ដែរ។ ចំពោះស្រែដែលពុំទាន់ស្ទូងមានទឹកល្ហល្ហាចពៀបភ្លឺ និងលម្អដោយរាវីជាតិនានាដុះចម្រុះគ្នាគួរចាប់ចិត្តចេតនា។ ដើមផ្លុង ដើមច្រាច់ដុះត្រង់នេះមួយដុំត្រង់នោះមួយដុំលាយឡំនឹងដើមស្គន់អំបោះ កំពីងពួយ ព្រលិតដែលដុះបណ្តែតខ្លួនលើផ្ទៃទឹកគួរឱ្យទស្សនា។ ហ្វូងកុក ក្រសារ ហើររេរារួចក៏ចរចុះទំរកស៊ីក្នុងស្រែលាយចម្រុះពណ៌សឬប្រផេះ បញ្ចេញសំឡេងប្រចឹកគ្នាខ្សៀវខ្សារគួរស្រណោះ។ បន្តិចក្រោយមកពួកវាក៏បានហើរចេញពីទីកន្លែងនេះទៅរកចំណីនៅកន្លែងផ្សេងៗ ហើយក៏មានហ្វូងកុក ក្រសារថ្មីមកទំរកស៊ីនៅកន្លែងនេះម្តង។

ឯស្រែខាងណោះវិញ ពួកកសិករខំភ្ជួរដីយ៉ាងសស្រាក់សស្រាំ។ យូរៗម្តងគាត់ស្រែកដេញគោ ហ៊ុយ! ហ៊ុយ! ជារឿយៗ រួមផ្សំនឹងសំឡេងសត្វសារិកាកែវ គ្រលីងគ្រលោង ប្រណាំងគ្នាប្រចឹកជន្លេនតាមអាចម៍បំណះប្រៀបបាននឹងសូរចម្រៀងប្រជាប្រិយ មកប្រគំកំដរ

នៅកណ្តាលវាលស្រែ។ ដោយខ្សែកមីងៗកសិករដែលទូលបាយមក ដល់ស្រែហើយនោះក៏ប្រញាប់ប្រញាល់ចុះស្ទូង ដើម្បីឱ្យរួចរាល់កុំឱ្យ ថ្ងៃក្តៅខ្លាំងនឹងសម្រេចការងារពុំបាន។ ពួកគាត់ស្ទូងបណ្តើរនិយាយគ្នា លេងបណ្តើរ។ អ្នកខ្លះជជែកគ្នាអំពីរឿងធ្វើស្រែឆ្នាំនេះ តែអ្នកខ្លះទៀត ក៏និយាយចំអែចំអន់គ្នាលេង ឬនិទានរឿងកំប្លែងបង្កើតបានជាសំណើច ក្អាកក្អាយកណ្តាលវាលស្រែ។ នៅខាងណោះពួកសិករខ្លះទៀតខំជញ្ជូន កណ្តាប់ញាប់ដៃញាប់ជើងពុំហ៊ានឈប់បង្អង់ តែក៏ឆ្លៀតហួចជាទំនុក បទចម្រៀងប្រពៃណីយ៉ាងពីរោះរណ្តំ។

វាយោបក់រំភើយៗពីទិសនិរតីបាននាំក្លិនផ្កាឈូក ផ្កាព្រលិត និង ផ្ការល្វិព្រៃផ្សេងៗដែលដុះក្នុងត្រពាំង និងព្រៃក្បែរៗនោះឱ្យរសាត់ ពិដោរគន្ធាដ៏ក្រអូបឈ្ងុយឈ្ងប់ បង្កើតមនោសញ្ចេតនាឱ្យរឹតតែស្រលាញ់ ជាប់ចិត្តចំពោះទីកន្លែងដ៏សុខសាន្តនេះទៀត។ ខណៈនេះគេហ៊ានធានា ថា គ្មានអ្វីដែលមានសោភណភាពល្អដូចទេសភាពស្រុកស្រែនារដូវដក ស្ទូងនេះឡើយ។ ខ្យល់អាកាសដ៏បរិសុទ្ធបានផ្តល់ផាសុកភាពដល់ ប្រជាជនខុសប្លែកពីទីក្រុងដែលសម្បូរដោយផ្សែងពុល។ ការរស់នៅ របស់ប្រជាកសិករមានឥស្សរភាពគ្មានការជិះជាន់កេងប្រវញ្ច តែពេញ ដោយសាមគ្គីភាព ចេះជួយទុក្ខធុរៈគ្នាពេលមានអាសន្ន រួមគ្នាកសាង សេដ្ឋកិច្ចជាតិឱ្យរីកចម្រើនរុងរឿង។

ទេសភាពដ៏ល្អឯកនារដូវដកស្ទូងនេះ បានបណ្តុះចិត្តខ្ញុំ ឱ្យស្រលាញ់ទឹកដីកេរដូនតា ស្រលាញ់ជីវភាពជាកសិករ និងជាកម្លាំង

ចិត្តសម្រាប់ឱ្យខ្ញុំខំសិក្សារៀនសូត្រ ដើម្បីស្រង់យកបច្ចេកទេសល្អៗ យកមកប្រើប្រាស់លើដីស្រែ កែប្រែទម្លាប់ចាស់ដែលធ្លាប់ធ្វើស្រែប្រវាស់មេឃ មកមានភាពម្ចាស់ការខ្លួនឯងលើបញ្ហាកសិកម្មជាស្នូលនៃការអភិវឌ្ឍជាតិឱ្យសម្បូររុងរឿង។

## ៧- ប្រធានពណ៌នាអំពីក្របខណ្ឌអត្ថបទអក្សរសិល្ប៍

ក្រៅពីប្រធានទូទៅបែបពណ៌នា ដែលយើងបានសិក្សារួចទៅហើយនៅមានប្រធានមួយបែបទៀត ទាក់ទងនឹងអត្ថបទអក្សរសិល្ប៍។ ប្រធានបែបនេះ តម្រូវឱ្យយើងផ្អែកលើបម្រាប់អត្ថបទអក្សរសិល្ប៍ជាគោល។ ប្រធានបែបនេះក៏ជាការពណ៌នាពីមនុស្ស សត្វ វត្ថុ ទីកន្លែង សកម្មភាព ទេសភាពដូចប្រភេទប្រធានពណ៌នាទូទៅដែរ តែការពណ៌នានេះ គឺធ្វើឡើងក្នុងអត្ថបទអក្សរសិល្ប៍ប៉ុណ្ណោះ។ ការពណ៌នាទាមទារឱ្យយើងមានសមត្ថភាពខ្ពស់ ក្នុងការពង្រីកបន្ថែមតាមមនោគតិ (គំនិតស្រមើស្រមៃ) ដោយបញ្ចេញបញ្ចូលលើលំនាំរឿង ដើមរឿងឱ្យបានប្រសើរនឹងប្រធានដែលយើងបានជ្រើសរើសមក ពោលគឺជាការតែងថ្មីក្នុងអ្វីដែលមានចាស់ ហើយមិនចាកខ្លឹមសារចាស់។ ក្នុងការពណ៌នាពុំតម្រូវឱ្យយើងគោរពសង្គមបរិយាកាសឱ្យដូចរឿងដើមសុទ្ធនោះទេ។

### គម្រោងសរសេរប្រធានពណ៌នាអំពីក្របខណ្ឌអក្សរសិល្ប៍

**ក- សេចក្តីផ្តើម** : ប្រាប់ចំណងជើងអត្ថបទដើមនិងចំណុចឬវគ្គឬក៏តួអង្គដែលត្រូវបង្ហាញ (បើសកម្មភាពនោះមាននៅក្នុងសង្គមត្រូវបង្ហាញមុនទើបលើកយកអត្ថបទអក្សរសិល្ប៍នោះមកពន្លាត។

**៥- តួសេចក្ដី** ៖ និយាយពង្រីកចំណុចដែលតួអង្គក្នុងរឿងតាមគំនិតផ្ទាល់ខ្លួនរបស់អ្នក ដោយមិនប្រាសចាកពីសីលធម៌ឬតម្លៃជាតិ។ ការសរសេរត្រូវបង្ហាញពីគំនិតសំខាន់ និងសេចក្ដីលម្អិតគាំទ្រគំនិតសំខាន់រហូតដល់ចប់រឿង។ នៅក្នុងវគ្គលម្អិតមួយៗត្រូវមានជាប់ជាមួយនឹងឧទាហរណ៍ក្នុងរឿងបន្ថែមផង ដើម្បីឱ្យអត្ថបទមានតម្លៃស៊ីជម្រៅទៀត។

**៦- សេចក្ដីបញ្ចប់** ៖ មានយោបល់ផ្ទាល់ខ្លួនទៅលើអត្ថបទចាស់ និងបង្កើតគំនិតថ្មី តែមិនប្រាសចាកពីអត្ថបទអក្សរសិល្ប៍ដែលលើកមកនិយាយឡើយ។

**ប្រធាន** ៖ *ចូរពណ៌នារូបតោក្នុងអត្ថបទ "តោថ្ម" ដោយពង្រីកតាមមនោគតិរបស់អ្នក។*

## សេចក្ដីអធិប្បាយ

នៅក្បាលស្ពានថ្ម ភ្ជាប់ពីថ្នល់ជាតិទៅថែវខាងក្រៅនៃប្រាសាទនគរវត្តមានឆ្មាំថ្មពីរឈរអមសងខាងច្រកស្ពាន។ ឆ្មាំនោះ គឺជាតោថ្មដែលលោកកវីសុត្តន្តប្រីជាឥន្ទ លើកមកពណ៌នានៅក្នុងអត្ថបទកំណាព្យ "និរាសនគរវត្ត"។

តោនេះ បុព្វបុរសខ្មែរបានកសាងឡើងពីថ្មសំលៀងពណ៌កុលាប។ តោបានទទួលភារកិច្ចជាឆ្មាំយាមនៅក្បាលស្ពាននោះទាំងយប់ទាំងថ្ងៃអស់រយៈពេលរាប់រយសតវត្សរ៍ទៅហើយ។ ទោះក្ដៅ

ឬរងា ទោះជាមានព្យុះសង្ឃរានិងភ្លៀងផ្គរបក់បោកមកលើខ្លាំងយ៉ាងណាក៏ដោយ ក៏តោនៅតែប្រកាន់គោលជំហរដ៏រឹងមាំឥតរាថយឱនក្បាលចុះញ៉មឡើយ។ វាព្យាយាមការពារអង្គរទាល់តែសម្បុរកុលាបរបស់គេប្រែទៅជាខ្មៅជាំនិងកន្លែងខ្លះទៀតត្រូវរុំព័ទ្ធដោយស្លែក្រាស់ឃ្មឹក។ វាស្ថិតនៅលើទម្រមួយខ្ពស់ល្មម ដែលអាចឱ្យវាមើលឃើញនៅគ្រប់ទិសបានយ៉ាងឆ្ងាយ។ ស្ថិតនៅលើទីខ្ពស់ដូចនេះនាំឱ្យគេមើលឃើញកាន់តែច្បាស់ពីសារៈសំខាន់នៃតួនាទីភារកិច្ចឃាមល្បាតរបស់វានោះ។

បើពិនិត្យឱ្យគ្រប់ចំណុចនឹងនាំឱ្យយើងចាប់អារម្មណ៍ថា តោហាក់ដូចជាចង់បក់ស្ទុះប្រែប្រាយសង្គ្រប់ចាប់អ្វីមួយ។ ជើងខាងក្រោយអង្គុញចុះបន្តិចបណ្ដាលឱ្យខ្នងអ៊ែន ហើយផ្នែកខាងក្រោយនៃដងខ្លួនបន្ទាបចុះ ឯជើងមុខធំមាំប្រៀបបានសសរស្ដម្ភបញ្ឈរត្រង់ភ្លឹងជ្រោងក្បាលងើបធ្មឹងឡើងយ៉ាងសម្បើមអស្ចារ្យ។ រូបតោដ៏សមហើយសង្ហាតែគួរឱ្យស្ដាយស្រណោះព្រោះពេលនេះតោមានរបួសធ្ងន់ណាស់។ ខ្នងតោត្រូវសឹករេចរឹលខុសរាងរៅដើម។ ថ្ពាល់គូទឆែបអស់មួយចំហៀងដោយសារមនុស្សចង្រៃយកកាំបិត ពូថៅ ផ្គាក់ទៅសំលៀងធ្វើឱ្យតោពិការ ហើយចំណែកផ្នែកខ្លះទៀតត្រូវរបើករបេះធ្លាក់បាក់ខ្ទាត់ខ្ទាយ។ បើមើលទៅមុខតោឃើញវាហាក់ដូចជា ឈឺចាប់ ក្ដៅឆ្អួល អួលផ្សាតូចចិត្តនឹងមនុស្សឥតគំនិត អគតិ មិនស្គាល់តម្លៃស្នាដៃបុរាណខំសាង។ ពិសេស មិនយល់ពីតួនាទីរបស់តោដែលជាអ្នកឃាមឃ្លាំងសម្បត្តិវប្បធម៌ជាតិសោះ។

ភ្នែកតោខំបើកលៀនក្រឡេតសម្លឹងមុតមកមុខ ច្រមុះធំខើច រីកចុងឡើងស្ទីក រីឯមាត់បញ្ចេញធ្មេញច្រូងច្រាងនិងមានសក់សំកុលធំ សំពោងក្រញាងគួរសម្បើមក្រៃលែង។ តោខឹងមនុស្សពាលដែល មិនញញើត មិនអៀនដៃនៅតែហ៊ានប្រមាថលើរូបតោទៀត។

តោជាសាក្សីរបស់ប្រជាជនខ្មែរ ចំពោះអ្វីៗដែលកើត ឡើងក្នុងរយៈពេលរាប់សតវត្សរ៍កន្លងទៅនេះ។ អ្នកចង់បំផ្លាញតោ ប្រាកដជាមានគំនិតអាក្រក់ចង់បំបាត់ភស្តុតាងដ៏មានតម្លៃនេះ ដើម្បី អះអាងផ្ទុយទៅវិញថា ខ្មែរពុំមែនជាជាតិដែលមានអតីតកាលរុងរឿង នោះទេ។

## ៨- ប្រធានពណ៌នាអំពីរឿង

ប្រធានប្រភេទនេះ តម្រូវឱ្យចេះសរសេរពិពណ៌នាពីរឿងរ៉ាវ ដែលផ្ទុះចេញពិតៗក្នុងសង្គម ហើយត្រូវសរសេរពីព្រឹត្តិការណ៍ដែលមិន ទាន់កើត កំពុងកើត និងក្រោយពេលកើតរួចមកបង្ហាញ។

ប្រធាននេះតម្រូវឱ្យសរសេររៀបរាប់ពីព្រឹត្តិការណ៍ រឿងរ៉ាវ ដែលកើតមានពិតដូចជា ខ្យល់ព្យុះ ទឹកជំនន់ ឬជាការបកស្រាយលើ ការសម្រេចចិត្តពីបញ្ហាអ្វីមួយ។

ការសរសេរមិនមានលក្ខណៈស្មុគស្មាញអ្វីណាស់ណាទេ គឺធ្វើ តាមអ្វីដែលយើងបានជួបប្រទះប៉ុណ្ណោះ និងរៀបរាប់ទៅតាមដំណើរ រឿងដែលបានកើតឡើងពីដំបូងរហូតដល់ចប់តាមលំដាប់លំដោយ។

## គម្រោងសរសេរប្រធានពណ៌នាអំពីរឿង

**ក- សេចក្ដីផ្ដើម** : បង្ហាញមូលហេតុនៃដំណើររឿង។ ទីនេះគេអាចប្រើរចនាបថនិទានក៏បាន តែត្រូវរកទម្រង់ណាមួយដែលខ្លីងាយស្ដាប់។

**ខ- តួសេចក្ដី** : ត្រូវសរសេរដោយបង្ហាញពី៖

- ❖ ព្រឹត្តិការណ៍មុនពេលកើតហេតុ
- ❖ ព្រឹត្តិការណ៍កំពុងកើតហេតុ
- ❖ ព្រឹត្តិការណ៍ក្រោយពេលកើតហេតុឬលទ្ធផលចុងក្រោយនៃព្រឹត្តិការណ៍។

**គ- សេចក្ដីបញ្ចប់** : ចំណាប់អារម្មណ៍ឬមនោសញ្ចេតនាផ្ទាល់ទៅលើអ្វីដែលយើងបានជួបប្រទះ។

***ប្រធាន*** : *ដើមរដូវវស្សាឆ្នាំនេះ ភូមិរបស់អ្នកបានជួបគ្រោះខ្យល់ព្យុះកំណាចមួយ។ ចូរអ្នកពណ៌នារឿងខ្យល់ព្យុះនោះ។*

### សេចក្ដីអធិប្បាយ

នៅក្នុងខែមិថុនាដើមរដូវវស្សានេះ ប្រមាណម៉ោងបួនរសៀលភូមិរបស់ខ្ញុំបានជួបប្រទះនឹងខ្យល់ព្យុះដ៏កំណាចមួយ។ ព្យុះនេះបង្កមហន្តរាយយ៉ាងដំណាំដល់អ្នកភូមិខ្ញុំ។

នៅថ្ងៃនោះ មុនពេលកើតហេតុមានធាតុអាកាសក្ដៅស្អុះស្អាប់ខុសប្លែកពីធម្មតា។ ព្រះអាទិត្យបញ្ចេញកម្ដៅខ្លាំងពពកឡើងក្រហមព្រឿងៗអណ្ដែតមកពីគ្រប់ទិស ពិសេសនោះ គឺទិសនិរតីតែម្ដង។

មនុស្សសត្វអន្ទះអន្ទែងស្វែងរកខ្យល់ដកដង្ហើមពុំបាន។ ដើមឈើតូចធំក្តៅស្វិតស្លឹករួញរញ្ញរញ្ញមអស់សម្រស់ ហាក់បង្ហាញថា ខ្លួនក៏ចាញ់កម្តៅព្រះអាទិត្យដែរ។ ជ្រូក គោ ក្របីដេកដង្ហក់នៅក្រោមម្លប់ឈើស្វើរតែមិនហ៊ានចេញមកក្រៅ។ ចំណែកឯសត្វមាន់ពួកវានាំគ្នាប៉ប៉ុកដីដេកសំងិលហាលស្លាបធ្វើមាត់ម្តបៗ ហាក់បង្ហួតខ្លួនថាវាមិនចាញ់កម្តៅឬភាពស្អុះស្អាប់នេះទេ។ ចាស់ៗដែលធ្លាប់មានបទពិសោធនិងចំណាំកន្លងមកលោកបានពោលប្រាប់កូនចៅថា "ថ្ងៃនេះប្រាកដជាមានភ្លៀងធ្លាក់មិនខាន" តែគាត់ក៏ពុំបាននឹកដល់ថា នឹងមានព្យុះកើតឡើងនោះឡើយ។

ម៉ោងប្រមាណជាបីរសៀលពពកក៏ស្រុតទាបជាងមុន។ ហើយរំពេចនោះក៏មានពពកពណ៌ខ្មៅដូចផ្សែង បានអណ្តែតមកពីទិសនិរតីដេញកម្ចាត់ពពកក្រហមព្រឿងៗពីមុននោះឱ្យវិនាសបាត់អស់។ ចំណែកព្រះអាទិត្យក៏ចាប់បន្ថយកម្តៅ ហើយភាពស្អុះស្អាប់ក៏បានធូរស្រាលជាងមុន។ ខ្យល់ចាប់ផ្តើមបក់ម្តងខ្លាំងម្តងខ្សោយប្លែកខុសធម្មតាមកពីទិសនិរតី ពេលនោះគេក៏ឃើញពពកខ្មៅក្រាស់ងងឹតដាបចេញដំណើរតម្រង់មកភូមិខ្ញុំ។ ផ្គរលាន់ចាប់គ្រហឹម ផ្លេកបន្ទោរក៏ចាប់សម្តែងឫទ្ធិខ្យល់ក៏ចាប់បក់បោកកាន់តែខ្លាំង។ ម្តាយខ្ញុំរត់ចុះពីលើផ្ទះទៅសាខោអាវរួចក៏ទៅប្រមូលឧសយកមកទុកខ្លាចភ្លៀងទទឹក។ មិនទាន់ទាំងអស់ឧសផងស្រាប់តែមានសន្ធឹកគឹកៗ ដូចរថក្រោះពីចម្ងាយរត់កាន់តែខិតមកជិតអ៊ឹថឹង។ បីបួននាទីក្រោយមក ក្បាលខ្យល់លាយឡំនឹងគ្រាប់ភ្លៀងក៏បក់បោកមកដល់។ គុម្ពឫស្សីដុះប្រឹបរបងផ្ទះខ្ញុំ ដោយចាញ់

មហិទ្ធិឫទ្ធិខ្យល់កំណាចក៏ចាប់ធ្វើចលនាឱនងើបៗ ហើយចុងវាឱនស្ទើរតែដល់ដី ស្រែកថ្ងូរង៉េតង៉ត។ ដើមឫស្សីខ្លះត្រូវខ្យល់កាច់បំបាក់ពាក់កណ្ដាលដើមគួរឱ្យខ្លាច។ ចំណែកដើមឈើធំៗដែលដុះនៅពីក្រោយផ្ទះខ្ញុំខំពង្រឹងជំហរទប់ទល់នឹងខ្យល់កំណាចមិនឱ្យគំរាមកំហែងផ្ទះខ្ញុំ។

ម្ដាយខ្ញុំភ័យពេក គាត់លែងប្រមូលឧសស្ទុះឡើងទៅលើផ្ទះកញ្ឆក់ប្អូនពីខ្ញុំមកព រួចស្ទុះទៅយកកាំបិតបន្ទោះដែលសៀតនៅជញ្ជាំងប្រមាត់ទ្វារទៅដោតនៅកណ្ដាលចង្ក្រាន តាមទម្លាប់ដែលគាត់ធ្លាប់ឃើញចាស់ៗធ្វើកន្លងទៅ មិនទាន់ទាំងដល់ចង្ក្រានផងស្រាប់តែខ្យល់បានកាច់បំបាក់មែកព្រីងធំមួយបោះប្រាវមកក្បែរសំយាបផ្ទះខ្ញុំ។ ខ្ញុំភ័យពេកស្ទុះរត់តក្រុកតាមម្ដាយខ្ញុំ។ គាត់ក៏ស្រែកភ្លាត់សំឡេងឱ្យខ្ញុំលោតចុះទៅដី រួចគាត់ក៏លោតចុះទៅតាមក្រោយខ្ញុំ គាត់ដួលច្រងាប់ច្រងិលដោយធ្ងន់នឹងប្អូនខ្ញុំ។ ទាំងអស់គ្នាមិនហ៊ានជ្រកនៅក្បែរផ្ទះឬក្បែរដើមឈើធំៗទេ។ ម៉ែនាំខ្ញុំរត់ទៅជ្រកក្បែរដំបូកកណ្ដៀរយ៉ាងធំមួយនៅប្រប មាត់ស្រះខាងមុខផ្ទះ។

ពេលនោះខ្ញុំឃើញគ្រាប់ភ្លៀងថ្លោសៗ ប៉ើងធ្លាក់ប៉ះសាច់ដូចគេចោលគ្រាប់គ្រួសមកលើ។ ផ្លេកបន្ទោរដេញគ្នាឆ្វាចៗ រន្ទះបាញ់ផាំងៗហាក់ស្រែកសន្ធាប់យកព្រលឹងគ្រប់គ្នា។ ប្អូនខ្ញុំញ័រចំប្រប់រន្ធត់ខ្លាចលែងហ៊ានយំ វាខំសសុលយកសុខក្នុងរង្វង់ដៃម្ដាយរបស់ខ្ញុំ។ ដើមឫស្សីទន់ទោរស្ទើរក្រាបដល់ដី។ ដើមព្រីងឈរសង្ក្រាការពារផ្ទះខ្ញុំឱ្យរឹងមាំដដែល។ ប្រហែលដប់ប្រាំនាទីក្រោយមក ដើមព្រីងក៏ចាញ់មហិទ្ធិឫទ្ធិខ្យល់

កំណាចនោះហើយត្រូវរលើងរលំជង្រ្គាងនៅពីក្រោយផ្ទះខ្ញុំតែម្តង។ ពេលនេះមិនមានអ្វីការពារផ្ទះខ្ញុំទៀតទេ ខ្យល់កំណាចក៏ចាប់គំរាមកំហែងផ្ទះខ្ញុំម្តង។ ផ្ទះខ្ញុំចាប់ផ្តើមរង្គើបន្តិច ពុងើតកន្លែងនេះ ពុងើតកន្លែងនោះ។ ទាំងអស់គ្នាពុំមានសង្ឃឹមថា ផ្ទះនឹងអាចគេចផុតពីការរលំបានឡើយ។ តែជាសំណាងល្អ បន្តិចក្រោយមកខ្យល់ក៏បន្ថយល្បឿនហើយភ្លៀងក៏ចាប់រាំងបន្តិចម្តងៗ។ ក្តីសង្ឃឹមកចាប់កើតមានឡើង តែមួយសន្ទុះក្រោយមកក៏ស្រាប់តែមានខ្យល់កំណាចមួយមេថ្មីទៀត បានធ្វើដំណើរមកដល់។ ដើមឈើនិងដើមឫស្សីមិនទាន់ងើបត្រង់ខ្លួនស្រួលផងក៏ត្រូវរេរាំសាជាថ្មីម្តងទៀត។ ម្តងនេះផ្ទះខ្ញុំដូចជាទុរន់ទុរាមែនទែន។

ខ្យល់កំណាចថ្មីនេះ បានបណ្តាច់ចំណងជញ្ជាំងផ្ទះខ្ញុំឱ្យប៉ើងធ្លាក់ដី។ គោខ្ញុំមួយនឹមដែលចងក្បែរនោះបានផ្តើលដាច់ខ្សែរត់មកឈរជំទែងយ៉ាងប្រុងប្រយត្ន ស្លឹកត្រចៀកទាំងពីរបះឡើងបែរមុខទៅរកខ្យល់ហាក់បង្ហាញប្រាប់ម្ចាស់ថា “កុំឱ្យមានការព្រួយបារម្ភអ្វីវានៅទីនេះហើយវាអាចជួយការពារបាន”។ ម្តាយខ្ញុំភ្ញាក់ស្លក់មុខស្លាំងញាក់តត្រុំនដៃឱបប្អូនខ្ញុំជាប់ហើយព្យាយាមបួងសួងនឹកគុណជីដូនជីតា សូមឱ្យបានគេចផុតពីគ្រោះមហន្តរាយនេះ។ ខ្យល់ថ្មីនេះបក់បោកខ្លាំងជាងមុនមែនតែមានរយៈពេលខ្លី។ បន្តិចក្រោយមកខ្យល់កំណាចបានបន្ថយល្បឿនបន្តិចម្តងៗរហូតដល់បាត់សូន្យឈឹង។ ម្តាយខ្ញុំនិងខ្ញុំបានចេញមកពិនិត្យការខូចខាតនៅផ្ទះតែពុំមានអ្វីខូចខាតជាធំដុំទេ។

ខ្យល់កំណាច បានបំផ្លាញផ្ទះនៅក្នុងភូមិខ្ញុំអស់ជាងដប់ខ្នងក្នុង

ចំណោមផ្ទះហាសិបខ្នង។ រីឯដើមឈើវិញក៏រលំអស់ច្រើនដែរ។ លោកមេភូមិនិងញាតិជិតខាងបានមកសួរសុខទុក្ខគ្រួសារខ្ញុំ ព្រមទាំងបានជួយលើកជញ្ជាំងផ្ទះខ្ញុំចងឡើងវិញ។ ប្រជាជននៅក្នុងភូមិខ្ញុំចេះរួមសាមគ្គីគ្នាណាស់។ គេបានជួយឧបត្ថម្ភគ្រួសាររងគ្រោះទាំងផ្លូវចិត្តនិងសម្ភារៈតាមលទ្ធភាព។ ប្រហែលជាដប់ថ្ងៃក្រោយមកអ្នកភូមិបានពួតដៃគ្នាជួយសង់និងជួសជុលផ្ទះសំបែងឱ្យគ្រួសាររងគ្រោះបានធម្មតាវិញ។

ខ្យល់មានប្រយោជន៍សំខាន់ និងចាំបាច់បំផុតសម្រាប់ជីវិតមនុស្ស សត្វ រុក្ខជាតិនានា ប៉ុន្តែបើខ្យល់មានទំហំធំពេកវានឹងផ្តល់មហន្តរាយទៅវិញ។ ចំពោះបាតុភូតធម្មជាតិនេះយើងពុំអាចចៀសផុតឡើយ ហើយពុំទាន់មានមធ្យោបាយការពារឱ្យមានប្រសិទ្ធភាពដែរ។ យើងត្រូវប្រុងប្រយ័ត្នដោយដាំដើមឈើនៅតាមរបង ឆ្ងាយពីផ្ទះឱ្យបានច្រើនដើម្បីបន្ថយល្បឿនខ្យល់។ ពេលមានខ្យល់ព្យុះយើងមិនត្រូវនៅក្នុងផ្ទះឬជ្រកក្រោមដើមឈើធំៗទេ ព្រោះវាអាចរលំសង្កត់យើងបាន។

### ៩- ប្រធានពណ៌នារឿងទូទៅតាមឯកវាទវិធី

ប្រធានប្រភេទនេះ តម្រូវឱ្យចេះសរសេររៀបរាប់ពីរឿងអ្វីមួយដែលបានកើតឡើងចំពោះខ្លួនឯង ស្វ័យជីវប្រវត្តិជាដំណើរនៃរឿង។ ការសម្រេចចិត្តក្នុងហេតុអ្វីមួយ ដោយប្រើសព្វនាមបុរិសៈបុរសទី១ឯកវចនៈក្នុងការនិទានផ្តើមដំបូងរហូតដល់បញ្ចប់។

ពាក្យ “**ឯកវាទវិធី**” បើសម្អាងលើវិធីសាស្ត្រនិពន្ធអក្សរសិល្ប៍ជាវិធីដែលអ្នកនិពន្ធឱ្យតួអង្គនិយាយតែម្នាក់ឯង គិតតែម្នាក់ឯង សម្រេច

ចិត្តតែម្នាក់ឯងដោយមិនមានដៃគូមកសន្ទនាឡើយ។

ការបកស្រាយក្នុងតែងសេចក្តី ដើម្បីឈានដល់តួអង្គនិយាយតែម្នាក់ឯង សម្រេចចិត្តម្នាក់ឯង លុះត្រាតែមានហេតុអ្វីកើតឡើងជាមុនសិន។ ខុសពីអត្ថបទអក្សរសិល្ប៍ដែលការនិយាយម្នាក់ឯងរបស់តួអង្គ គឺមានបច្ច័យដែលនាំឱ្យមានបញ្ហានេះកើតឡើងរួចទៅហើយទើបតួអង្គយកបញ្ហានោះមកពិចារណាសាជាថ្មី។

ក្នុងការសរសេរតែងសេចក្តី ***ហេតុ*** ជាបច្ច័យដែលនាំឱ្យកើតជាបញ្ហា។ ការសម្រេចចិត្តបែបឯកវាទវិធី គឺត្រូវបកស្រាយនៅចំណុចសេចក្តីផ្តើមសិន រួចភ្ជាប់បញ្ហាទៅនឹងចំណុចតួសេចក្តីតែម្តង។

**គម្រោងសរសេរប្រធានពណ៌នារឿងខ្លីតាមឯកវាទវិធី**

***ក- សេចក្តីផ្តើម*** : បង្ហាញមូលហេតុដែលនាំឱ្យអ្នកធ្វើឯកវាទវិធីនេះឬអ្នកអាចប្រើរចនាបថនិទានក៏បាន តែត្រូវរកទម្រង់ណាដែលខ្លីហើយស្រួលស្តាប់។

***ខ- តួសេចក្តី*** : ផ្នែកនេះត្រូវសរសេរជាឯកវាទវិធី (អ្នកនិយាយតែម្នាក់ឯងដោយប្រើសព្វនាមបុរិសៈបុរសទី១)។ ដូចនេះត្រូវចៀសវាងកុំប្រើពាក្យវែងអត់ប្រយោជន៍ច្រើនពេក តែត្រូវការបញ្ជាក់ដូចជា :

*...ខ្ញុំនឹកក្នុងចិត្ត...*

*...ខ្ញុំនឹកបណ្តើរធ្វើការបណ្តើរ...*ជាដើម។

នៅក្នុងការសរសេរនេះគឺស្ថិតក្នុងសកម្មភាព ដេក ដើរ ឈរ អង្គុយ។

**ឥ- សេចក្ដីបញ្ចប់** : ត្រូវបង្ហាញឱ្យឃើញពីការសម្រេចចិត្តនោះស្ថិតក្នុងដំណោះស្រាយមួយសមស្របជានិច្ច។

**ប្រធាន** : *ចូរអ្នកនិទានពីការរារែកចិត្តរបស់អ្នកដោយប្រើឯករាទវិធីនៅមុនពេលសម្រេចចិត្ត លើបញ្ហាអ្វីមួយដែលអ្នកបានជួបប្រទះ។*

## សេចក្ដីអធិប្បាយ

នាល្ងាចថ្ងៃមួយ វេលាខ្ញុំដើរកាត់មុខផ្ទះរបស់ណារីកូនស្រីអ្នកជិតខាងខ្ញុំ នាងក៏ស្រែកហៅខ្ញុំបណ្ដើរ រត់ចេញពីក្នុងផ្ទះបណ្ដើរថា បង! បង! ល្ងាចនេះទូរទស្សន៍លេងរឿងល្អមើលណាស់ បងមកមើលទេ?

មើល "ខ្ញុំឆ្លើយ" កាលណាដល់ម៉ោងលេងណារីមកហៅបងផងណា!

ចាស៎បង!

ចុំ! ភ្លេចឱ្យឈឹង! "ខ្ញុំនឹកក្នុងចិត្តពេលបែកពីណារីហើយ រៀបចំដាំបាយនិងធ្វើម្ហូបពេលល្ងាច" ស្អែកប្រលងឆមាសអំពីភាសាខ្មែរផងតើ!... ខ្ញុំមើលមិនទាន់គ្រប់មេរៀននៅឡើយទេ។ មើល៍... មេរៀនដែលរៀនរួចមកហើយបានចំនួនប្រាំបួន ខ្ញុំមើលរួចប្រាំបីអ៊ីចឹងនៅសល់មួយទៀត។ ប្រសិនបើចាំស្អែកងើបពីងងឹតមើលប្រហែលទាន់ព្រោះឮថារឿងនោះល្អមើលណាស់ ព្រោះកាលបញ្ចាំងនៅរោងភាពយន្តម្នាក់ៗមើលរហូតពីរឬបីដងល្បីថា តួសម្ដែងទាំងស្រី ទាំងប្រុស សុទ្ធតែ

ស្អាតៗគួរឱ្យចង់មើលដែរ...។ តើរឿងនោះល្អយ៉ាងណាហ្ន៎ បានជាគេមើលដល់ពីរបីដងម្នាក់ៗ? ប៉ុន្តែ... យីង៉េ... ដូចជាមិនស្រួលទេ? មេរៀនដែលនៅសល់ក្រោយគេ ពិបាកហើយសំខាន់ណាស់ព្រោះតែអ៊ីចឹង ហើយបានជាខ្ញុំទុកវាក្រោយគេ។ បើចាំព្រឹកសឹមងើបឡើងរៀនតិចលោមិនទាន់ទៅ! មុខជាកុនហើយព្រោះខ្ញុំ សង្ស័យថា ប្រាកដជាមានសំណួរទាក់ទងដល់មិនខាននៅថ្ងៃស្អែកនេះ។ ហ៊ឹ... ចំជាស៊យមែន! បើចាំស្អែកសឹមលេងទៅមិនអី... ឬមួយទៅមើលបន្តិចរួចសឹមមករៀនវិញ? ម្យ៉ាងដែរ...។ តែ... ទេ!... មិនកើតទេ! បើរឿងនោះល្អមើលមែន ខ្ញុំជាមេជក់រឿងស្រាប់ផងមុខតែចេញមកវិញមិនរួចទេ។ ណ្ហើយ... សូវកុំឃើញឱ្យសោះល្អជាង។ ប៉ុន្តែគិតមែនទែនទៅ... ម៉ោងប្រាំបីកន្លះបានរឿងចាប់ផ្ដើមលេង។ ចុះបើខ្ញុំមើលមេរៀនឱ្យចាំមុនម៉ោងប្រាំបីកន្លះ?... ត្រូវហើយ! ប្រញាប់ដៃធ្វើម្ហូបឱ្យហើយឆាប់ទៅ បើអ៊ីចឹង! មើល... ម៉ោងប៉ុន្មានហើយឥឡូវ?... អីយ៉ា! ម៉ោងជិតប្រាំមួយហើយតើ! យីមិនកើតទេ... ឧបមាថាម៉ោងប្រាំមួយកន្លះឆ្អិនអស់។ ទម្រាំហូបរួចលាងទុកដាក់រួចម៉ោងប្រាំពីរស្រេច។ ពីម៉ោងប្រាំពីរដល់ម៉ោងប្រាំបីកន្លះ... តែមួយម៉ោងកន្លះរៀនម៉េចទាន់? រួចនៅធ្វើលំហាត់គណិតវិទ្យាមួយទៀតផង។ ណ្ហើយកុំគិតច្រើន! ខ្ជិលមើលអី! មិនខ្វះរឿងមើលទេ ព្រោះថ្ងៃក្រោយគេកាន់តែមានបច្ចេកទេសខ្ពស់ក្នុងការសម្ដែង ចំណែករឿងរៀនប្រហែលមិនបានទេ។

ពេលវេលាកន្លងទៅហើយ មិនដែលវិលត្រលប់មក

វិញនោះឡើយហើយពេលវេលាមានតម្លៃណាស់សម្រាប់យើង។ ដូច្នេះការសម្រេចចិត្តបានល្អ នាំឱ្យយើងមានភាពជឿជាក់លើខ្លួនឯងនិងមានទំនុកចិត្តខ្លួនឯងក្នុងការដោះស្រាយបញ្ហាផ្សេងៗបានល្អ។

## ១០- ប្រធានពណ៌នារឿងបែបរំឭកអនុស្សាវរីយ៍

ប្រធានប្រភេទនេះ តម្រូវឱ្យចេះសរសេរបកស្រាយរំឭករឿងទាំងឡាយដែលបានកើតឡើងកន្លងហួសទៅហើយ និងទាមទារការចងចាំរឿងទាំងអស់នោះឱ្យបានល្អ រួចយកមកនិទានសាជាថ្មីដោយរៀបតាមលំដាប់លំដោយជាលក្ខណៈតែងសេចក្តី។

### គម្រោងសរសេរប្រធានពណ៌នារឿងបែបរំឭកអនុស្សាវរីយ៍

***ក- សេចក្តីផ្តើម*** : សរសេរបញ្ហាថ្មីភ្ជាប់ទៅបញ្ហាចាស់ដែលអ្នកធ្លាប់ឆ្លងកាត់ឬបានជួបប្រទះកន្លងទៅ។

***ខ- តួសេចក្តី*** : ប្រើឃ្លាភ្ជាប់សេចក្តីមុនឈានដល់បញ្ហាសំខាន់រួចចាប់បកស្រាយជាដំណាក់ៗដូចខាងក្រោម៖

❖ ***បញ្ហាកើតឡើងដំបូង*** : តើមានបញ្ហាអ្វីដែលនាំឱ្យអ្នកសម្រេចចិត្តធ្វើបែបនេះ?

❖ ***បញ្ហាដែលកំពុងកើត*** : តើអ្នកបានធ្វើសកម្មភាពអ្វីនៅពេលនោះ? ប្រសិនជាលក្ខណៈរំឭកអនុស្សាវរីយ៍ពីការដើរកម្សាន្តត្រូវផ្សារភ្ជាប់នឹងទេសភាពនៃដំណើរទស្សនានោះជាមួយផង។

***គ- សេចក្តីបញ្ចប់***: បង្ហាញចំណាប់អារម្មណ៍ផ្ទាល់ខ្លួន។

**ប្រធាន** ៖ *រសៀលថ្ងៃអាទិត្យមួយដែលទំនេរពីការសិក្សា ដើម្បីបំបាត់ភាពអផ្សុក អ្នកបានទៅស្ងួចត្រីកម្សាន្តនៅមាត់ទន្លេ។ ចូរអ្នករំឭកពីអនុស្សាវរីយ៍ថ្ងៃនោះឡើងវិញ។*

## សេចក្ដីអធិប្បាយ

រសៀលថ្ងៃអាទិត្យមួយជាថ្ងៃសម្រាកពីការសិក្សា ខ្ញុំបានទៅស្ទូចត្រីជាមួយនឹងមិត្តភក្តិជាច្រើន នៅមាត់ទន្លេត្រើយខាងកើត។ ទេសភាពមាត់ទន្លេនៅរសៀលនោះពិតជាដក់ជាប់ក្នុងអារម្មណ៍របស់ខ្ញុំយ៉ាងខ្លាំង។

បន្ទាប់ពីជួបជុំគ្នាហើយ យើងក៏បានមកដល់មាត់ទន្លេដែលស្ថិតនៅភូមិគីឡូម៉ែត្រលេខប្រាំបួន។ ល្ងាចនោះខ្ញុំបានតាំងចិត្តថាប្រសិនបើស្ទូចត្រីមិនបានទេ ខ្ញុំមិនទៅផ្ទះវិញឡើយ។

ពេលទៅដល់ទីតាំងដែលត្រូវស្ទូច ខ្ញុំរូតរះរកកន្លែងដែលអាចអង្គុយស្ទូចត្រីស្រួលបន្តិចមិនចាំបាច់ប្ដូរកន្លែងច្រើនដង។ នៅពេលនោះដែរ ពិតជាសំណាងល្អណាស់ ព្រោះបានឃើញគល់ឈើធំមួយដែលរលំចូលទៅទន្លេ ទើបខ្ញុំរូតរះចូលអង្គុយបានមុនគេតែម្ដង ចំណែកមិត្តភក្តិជាច្រើននាក់ទៀតបានរកកន្លែងសមគួររៀងៗខ្លួន តែមិននៅឆ្ងាយពីគ្នាឡើយព្រោះដើម្បីងាយរកគ្នាត្រលប់ទៅផ្ទះវិញ។

ជំនោរខ្យល់ពេលរសៀលនាខែពិសាខ ពិតជាត្រជាក់ស្រួលណាស់ បក់មករំភើយៗនាំទឹករលករមេញប្រដេញគ្នាភ្លឺផ្លេកដូចគ្រាប់ពេជ្ររាប់ម៉ឺនសែនអណ្ដែតលើផ្ទៃទឹក។ សម្លឹងទៅត្រើយខាងលិចមាន

ផ្ទះប្រជាជនតូចធំបង្អួតខ្លួនយ៉ាងស្រស់ស្អាត សង់ក្បែរមាត់ទន្លេងពិត ជាស្រស់ស្អាតនិងមានសុភមង្គលណាស់។ ស្រុកយើងឥឡូវនេះមាន សន្តិភាពបរិបូរ ទើបមានសំណង់អគារខ្ពស់ទាប តូចធំសង់ជាហូរហែ ព្រោងព្រាតពេញរាជធានី។ កាលពីដំបូងទីនេះមិនមានសំណង់អគារ ធំៗ ខ្ពស់ៗទេ តែបច្ចុប្បន្នមានច្រើនណាស់ហើយទៅអនាគតនឹងរីក ចម្រើនជាងនេះទៀតជាពុំខាន។

ក្រឡេកទៅផ្ទៃទន្លេ មានទឹកភ្លឺចិញ្ចាចវែងឆ្ងាយសន្ធឹម ទូក នេសាទកំពុងអណ្តែតខ្លួនស្វែងរកត្រីយ៉ាងសកម្ម មុជងើបៗតាមចង្វាក់ ទឹករលកមិនឈប់ឈរ។ ដោយឡែក សត្វត្រចៀកកាំទន្លេវិញក៏មិន ទំនេរដែរ ប្រឹងឆ្វេលឆាបចាប់ចំណីប្របមាត់ទន្លេហើយស្រែកខ្សៀវខ្សារ សប្បាយជាមួយនឹងប្រជានេសាទដែរ។

ចំណែកនៅត្រើយជិតកន្លែងខ្ញុំស្ងួចត្រីនោះវិញ ប្រជាកសិករដែល មានមុខរបរដាំដំណាំបន្លែ បានមករែកទឹកស្រោចដំណាំយ៉ាងសស្រាក់ សស្រាំដែរ។ កំស្ទួលដែលចងជាប់នឹងខ្សែសន្ទូចខ្ញុំបានឱ្យសញ្ញាថា មាន ត្រីមកស៊ីនុយហើយ ទើបខ្ញុំវាត់ឡើងយ៉ាងប្រញាប់ក៏បានត្រីដូចបំណង មែន។ បើសម្លឹងពីត្រើយខាងកើតរឹតតែស្រស់ស្អាតឡើងស្មើររកអ្វី ប្រៀបគ្មាន។ ផ្ទៃមេឃពណ៌ក្រហមព្រឿងៗ ចំណែកពន្លឺអំពូលនានា ចាប់បំភ្លឺជាបណ្តើរៗ ខ្ញុំក៏ត្រូវសម្រាកពីការនេសាទដែរដោយក្តីរីករាយ ក្រៃលែង។

ទិដ្ឋភាពថ្ងៃនោះ នៅតែដិតជាប់ក្នុងចិត្តខ្ញុំជានិច្ច ហើយខ្ញុំ

មានមោទនភាពចំពោះជាតិណាស់។  ក្នុងនាមខ្ញុំជាកូនខ្មែរមួយរូបសូមសន្យាថា ខ្ញុំនឹងខិតខំរៀនសូត្រឱ្យពូកែដើម្បីក្លាយជាធនធានមនុស្សមួយរូបចូលរួមអភិវឌ្ឍសង្គមជាតិយើងឱ្យបានរីកចម្រើនរុងរឿងតទៅ។

# ប្រធាននិទានរឿង

ក្នុងសង្គមមនុស្សយើង តែងតែមានទំនាក់ទំនងគ្នាទៅវិញទៅមកតាមរយៈបម្រើបម្រាស់ភាសាជារៀងរាល់ថ្ងៃ។ អ្នកខ្លះប្រើប្រាស់ភាសាដើម្បីនិទានអ្វីដែលគេធ្លាប់បានដឹង បានឮពីមុនមកឱ្យមិត្តភក្តិឬបងប្អូនរបស់គេស្ដាប់។ គេអាចនិទានរឿងបានល្អប្រសិនបើគេបានសិក្សារឿងនោះឬស្ដាប់រឿងនោះដោយប្រុងប្រយត្ន និងចេះរៀបចំគម្រោងនៃការនិទានបានត្រឹមត្រូវ។

ដោយឡែកប្រធាននិទានរឿង ជាប្រធានដែលរៀបរាប់អំពីរឿងរ៉ាវដែលមានស្រាប់ ហើយបានកើតឡើងនៅកន្លែងណាមួយមកនិទានឱ្យភាគីម្ខាងស្ដាប់តាមព្រឹត្តិការណ៍រឿងដដែល។ ដើម្បីសរសេរប្រធានបែបនេះបានល្អគប្បីអនុវត្តដូចខាងក្រោម៖

១- ប្រើពាក្យសម្ដីរបស់អ្នកនិយាយតាំងពីដើមដល់ចប់។

២- សរសេររឿងនិទានតាមគម្រោងមានសេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់។

៣- ប្រើពាក្យប្រាប់លំដាប់កាលក្នុងសំណេររបស់អ្នកឱ្យបានត្រឹមត្រូវតាមលំដាប់នៃព្រឹត្តិការណ៍របស់រឿង។

៤- សរសេរឱ្យត្រឹមត្រូវតាមអក្ខរាវិរុទ្ធ។

៥- សរសេររៀបរាប់តាមព្រឹត្តិការណ៍ដែលមាននៅក្នុងរឿងឱ្យបានក្បោះក្បាយហើយច្បាស់លាស់។

៦- ប្រើពាក្យសម្តីអ្នកនិទានផ្ទាល់ក្នុងការសរសេរ។

## គម្រោងសរសេរប្រធាននិទានរឿង

**ក- សេចក្តីផ្តើម** : បង្ហាញពេលវេលានិងចំណងជើងរឿងរួមជាមួយឈ្មោះអ្នកនិទានឱ្យបានត្រឹមត្រូវ។

**ខ- តួសេចក្តី** : លើកយកសាច់រឿងទាំងស្រុងមកសរសេរដោយគោរពតាមលំដាប់លំដោយនៃព្រឹត្តិការណ៍រឿង។

**គ- សេចក្តីបញ្ចប់** : ចំណាប់អារម្មណ៍ចំពោះសាច់រឿងដែលបានស្តាប់រួចហើយ។

**ប្រធាន** : *ជីតារបស់អ្នកបាននិទានរឿងមួយឱ្យអ្នកស្តាប់។ ចូរអ្នកនិទានរឿងនោះឡើងវិញ។*

## សេចក្តីអធិប្បាយ

យប់មួយក្រោយពីសម្រាកការងារហើយ ចំពេលដែលព្រះចន្ទពេញវង់ភ្លឺត្រចះត្រចង់ ខ្ញុំនិងប្អូនៗរបស់ខ្ញុំបានមកអង្គុយជុំវិញជីតារបស់ខ្ញុំដើម្បីឱ្យគាត់និទានរឿងក្អែកនិងខ្ញែកឱ្យស្តាប់។ ចៅៗបានស្តាប់កម្សាន្តគ្រប់គ្នា ហើយខ្ញុំបានចងចាំរឿងនេះទាំងស្រុង។

រឿងនេះមានសេចក្តីតំណាលថា : កាលពីព្រេងនាយ

បក្សាបក្សីទាំងអស់សុទ្ធតែមានសម្បុរដូចគ្នា ខុសតែរូបរាងខ្លះប៉ុណ្ណោះ។ វេលាដែលវាហើរទៅលើអាកាសម្តងៗ មនុស្សលោកពុំអាចសម្គាល់បានថាជាសត្វអ្វីឡើយ។ ដោយសារហេតុនេះហើយទើបពពួកសត្វស្លាបទាំងអស់បានបើកអង្គប្រជុំមួយ។

លុះវេលាព្រឹកឡើង នៅលើដើមរាំងប្របមាត់ស្ទឹង ពពួកបក្សាបក្សីជាច្រើនបានមកជួបជុំគ្នា។ ពេលនោះសត្វទាំងអស់បានគិតគ្នា ឥឡូវយើងទាំងអស់គ្នាគិតរចនារូបពួកយើងឱ្យមានសម្បុរខុសៗគ្នា។ យើងធ្វើយ៉ាងនេះដើម្បីកុំឱ្យមនុស្សលោកគេយល់ច្រលំ។ លុះជំនុំគ្នាអស់រយៈពេលយ៉ាងយូរមក ទើបពួកគេសម្រេចចិត្តថា អ្នកស្រលាញ់ពណ៌សម្បុរយ៉ាងណាចូរធ្វើយ៉ាងនោះចុះតែកុំឱ្យដូចគ្នា។ ជាមួយគ្នានោះ សត្វទាំងអស់ក៏បានពិភាក្សាគ្នារើសជាងគំនូរដោយពួកគេរើសខ្វែកនិងក្អែកឱ្យធ្វើជាជាងគំនូរ។ ខ្វែកបានដាក់ពណ៌ឱ្យសត្វទាំងអស់ទៅតាមចិត្តស្រលាញ់របស់គេ នៅសល់តែក្អែកនិងខ្វែកខ្លួនឯងផ្ទាល់មិនទាន់ដាក់បានពណ៌។ ខ្វែកបានសួរទៅកាន់ក្អែកថា បងក្អែកឯងចង់ដាក់ពណ៌ដូចម្តេចដែរ? ក្អែកឆ្លើយថា តាមតែចិត្តបងខ្វែកឯងទៅចុះព្រោះបងឯងជាជាងគំនូរស្រាប់ គួរយ៉ាងណាឱ្យតែសមឱ្យតែស្អាត។ ខ្វែកបានបញ្ជាក់បន្ថែម អើ! បើដូចនេះខ្ញុំគួរបានតែពេលយប់ទេទើបរំលេចពណ៌បានល្អ បើគួរពេលថ្ងៃមិនល្អទេ។ បើដូចនេះចូរបងឯងគួរឱ្យខ្ញុំជាមុនសិន ចាំខ្ញុំគួរឱ្យបងឯងជាក្រោយ។ ក្អែកក៏គួរឱ្យខ្វែកមានពណ៌ក្រវេមក្រវាមទៅតាមចំណូលចិត្តខ្លួន។

ស្បែងងឹតចូលមកដល់ នៅលើខ្នងភ្នំខ្មែកបានហៅក្អែកទាំងអស់មកប្រជុំគ្នាហើយបានលាយធ្យូងមួយខ្ទះធំ ទើបវាបានយកកំណាត់ជ្រលក់លាបៗ ពេញសត្វទាំងអស់គ្មានសល់សាច់ត្រង់ណាបន្តិចបន្តួចឡើយ។ លុះព្រឹកឡើងក្អែកទាំងអស់ឃើញខ្លួនខ្មៅនិលគ្រប់ៗគ្នាដូចនេះក៏កើតមានកំហឹងពេញទ្រូង នាំគ្នាហើរស្រែករំពងព្រៃតាមរកខ្មែកឱ្យឃើញនឹងចឹកសម្លាប់ឱ្យវិនាស។ ឯហ្វូងខ្មែកឮគ្រាន់តែព្រលឹមស្រាងៗឡើងនាំគ្នាហើរគេចខ្លួនពួនសំងំក្នុងព្រៃបាត់អស់។ ហេតុនេះហើយទើបសត្វខ្មែករកស៊ីពេលយប់ សម្រាកនៅពេលថ្ងៃដើម្បីពួនសំងំគេចពីក្អែកដែលជាសត្រូវនឹងគ្នាតាំងពីពេលនោះមក។

រឿងនេះបានអប់រំយើងឱ្យស្អប់ខ្ពើមអំពើបោកប្រាស់ ត្រូវចេះសាងមិត្តប្រសើរជាងសត្រូវ។

ក្រោយពីស្តាប់រឿងនេះចប់ហើយ ខ្ញុំនិងបងប្អូនរបស់ខ្ញុំសប្បាយរីករាយយ៉ាងខ្លាំង ព្រោះទទួលបានការអប់រំល្អៗសម្រាប់អប់រំខ្លួនឱ្យរស់នៅក្រោមដំបូលសន្តិភាពអហិង្សានៅក្នុងសង្គមតទៅ។

# ប្រធានសរសេរសំបុត្រ

ប្រធានសរសេរសំបុត្រ តម្រូវឱ្យយើងប្រើរបៀបសរសេរផ្សេងពីគេ។ ប្រធាននេះមានគោលការណ៍សរសេរសាំញ៉ាំបន្តិច តែមិនមានការលំបាកណាស់ណាទេ គឺត្រូវការគោរពលក្ខខណ្ឌមួយចំនួនដែលជាបែបបទសម្រាប់សរសេរ។

ប្រធានបែបសរសេរសំបុត្ររួមមានបីប្រភេទធំៗ៖

- *សំបុត្រផ្លូវការ*
- *សំបុត្រឯកជនសួរសុខទុក្ខធម្មតា*
- *សំបុត្រសួរសុខទុក្ខបែបពណ៌នា*

ក- សំបុត្រផ្លូវការ : ជាលិខិតផ្លូវច្បាប់ដែលទាក់ទងរវាងអង្គភាពរដ្ឋនិងអង្គភាពរដ្ឋ អង្គភាពឯកជននិងអង្គភាពឯកជនដោយមានការចុះហត្ថលេខានិងបោះត្រា។ លិខិតជាផ្លូវការមានពីរប្រភេទ៖

- លិខិតបទដ្ឋាន
- លិខិតផ្លូវការធម្មតា

ខ- សំបុត្រឯកជនសួរសុខទុក្ខធម្មតា : ជាសំបុត្រផ្ទាល់ខ្លួនផ្ញើទៅ

កាន់នរណាម្នាក់។ ជាទូទៅគេដាក់នៅក្នុងស្រោម ទើបផ្ញើតាមប្រៃសណីយ៍ ដូចជាសំបុត្រទាក់ទងនឹងឪពុកម្ដាយ ប្ដីប្រពន្ធ កូន បងប្អូន មិត្តភក្តិ លោកគ្រូ អ្នកគ្រូ... ដែលនៅឆ្ងាយពីគ្នា។

នៅក្នុងទំនាក់ទំនងនេះ គេប្រើសំណេរជំនួសការនិយាយដើម្បីឆ្លើយឆ្លងគ្នានិងផ្ដល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

គ- សំបុត្រសួរសុខទុក្ខបែបពណ៌នា : មានលក្ខណៈដូចសំបុត្រសួរសុខទុក្ខដែរ ប៉ុន្តែសំបុត្រពណ៌នាជាប្រភេទសេចក្ដីមួយដោយឡែក។ អ្នកសរសេរសំបុត្រត្រូវតែដឹងខ្លួនជានិច្ចថា ខ្លួនកំពុងតែនិយាយទៅកាន់នរណាម្នាក់ (ផ្ទុយពីប្រធានពណ៌នាដែលខ្លួនបានធ្វើហាក់មិនដឹងខ្លួនថាមានអ្នកស្ដាប់ឬអ្នកអានអត្ថបទរបស់ខ្លួន)។ ក្នុងករណីនេះអ្នកសរសេរសំបុត្រ ត្រូវប្រើរចនាបថមួយស្ទើរតែប្រហែលគ្នានឹងរចនាបថនិទានរឿងឬពណ៌នារឿងដែរ។ ពេលនេះយើងនឹងលើកយកប្រធានប្រភេទសរសេរសំបុត្រពីរមកសិក្សាស្វែងយល់ ដើម្បីឱ្យអ្នកសិក្សាពិចារណាដូចតទៅ៖

## ១- សំបុត្រឯកជនសួរសុខទុក្ខធម្មតា

គម្រោងសរសេរសំបុត្រឯកជនសួរសុខទុក្ខធម្មតា

**ក- សេចក្ដីផ្ដើម**

❖ ក្បាលសំបុត្រ : ចុះទីកន្លែង ថ្ងៃ ខែ ឆ្នាំដែលសរសេរ។

❖ ការគោរព : ដាក់ឈ្មោះនិងមុខងារអ្នកទទួល។

**ខ- តួសេចក្ដី**

❖ បង្ហាញពីបំណងនិងខ្លឹមសារនៃសំបុត្រ។

❖ សួរសុខទុក្ខដល់អ្នកទទួល។

❖ ប្រាប់សុខទុក្ខអ្នកសរសេរដល់អ្នកទទួល។

❖ ប្រាប់ពីបំណងនៃអ្នកសរសេរទៅអ្នកទទួល។

**គ- សេចក្តីបញ្ចប់**

❖ ពាក្យជូនពរ

❖ ការចុះហត្ថលេខានិងដាក់ឈ្មោះ

☞ ***កំណត់សម្គាល់*** : នៅក្នុងកិច្ចការប្រលងឬកិច្ចការក្នុងថ្នាក់ ពុំតម្រូវឱ្យមានហត្ថលេខានិងឈ្មោះអ្នកសរសេរទេ។

**ប្រធាន** : *ប្អូនបានបែកឆ្ងាយពីមិត្តសម្លាញ់ប្អូនជាយូរមកហើយ ឥឡូវនេះ ចូរប្អូនសរសេរសំបុត្រមួយច្បាប់ដើម្បីសួរសុខទុក្ខមិត្ត របស់ប្អូននោះ។*

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨

មកដល់ចិន្តាសម្លាញ់ជាទីនឹករឭក

ចិន្តា! អស់រយៈពេលជាងមួយឆ្នាំមកហើយដែលខ្ញុំបានឃ្លាតពីសម្លាញ់និងភូមិកំណើតមករស់នៅនិងបន្តការសិក្សានៅភ្នំពេញ។ នៅក្នុងរយៈពេលនេះ ខ្ញុំមិនបានដឹងពីសុខទុក្ខរបស់សម្លាញ់យ៉ាងណានោះទេ។ ខ្ញុំតែងរឭកមកដល់សម្លាញ់ជានិច្ច។ តើសម្លាញ់មានសេចក្តីសុខទុក្ខយ៉ាងណាដែរ? ឯការសិក្សារបស់សម្លាញ់ឆ្នាំនេះយ៉ាងណាដែរ?

ចំណែកខ្ញុំឯណោះមានសេចក្តីសុខជាធម្មតាទេ។ សព្វថ្ងៃខ្ញុំរៀន

នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ជីវភាពរស់នៅរបស់ខ្ញុំសព្វថ្ងៃខ្វះខាតច្រើនណាស់។ សម្លាញ់ដឹងស្រាប់ហើយថា ខ្ញុំជាកូនកំព្រាឪពុកម្ដាយ ហើយមកបន្តការសិក្សានៅភ្នំពេញ ដោយរស់នៅជាមួយនឹងម្ដាយមីង។ គាត់ពុំសូវមានជីវភាពធូរធារទេ ហើយមានកូនច្រើននៅក្នុងបន្ទុកទៀតផង។ ខ្ញុំសព្វថ្ងៃខិតខំរៀនសូត្រនៅសាលាផងនិងជួយធ្វើកិច្ចការផ្ទះសំបែងផង។ ពេលខ្លះខ្ញុំក៏ខ្វះថវិកាសម្រាប់ទិញសម្ភារៈសិក្សានិងសម្លៀកបំពាក់ទៀតផង តែខ្ញុំពុំហ៊ានហាមាត់សុំលុយមីងទេព្រោះខ្ញុំអាណិតគាត់ដោយគាត់ក៏ពុំសូវសម្បូរប្រាក់ដែរ។ ពិបាកណាស់សម្លាញ់ មានម្ដងនោះ ខ្ញុំសម្រេចចិត្តខ្ចីលុយមិត្តភក្តិខ្លះនៅក្នុងថ្នាក់របស់ខ្ញុំ គេឈ្មោះធារ៉ា។ ធារ៉ាមានចិត្តល្អណាស់ គេបានឱ្យលុយខ្ញុំដោយមិនឱ្យខ្ញុំសងវិញឡើយ។ ខ្ញុំអៀនខ្មាសខ្លួនឯងណាស់សម្លាញ់ ខ្ញុំគិតថា ខ្ញុំនឹងសន្សំលុយសងធារ៉ាវិញ។

ទោះជាខ្ញុំលំបាកខ្វះខាតលុយកាក់រៀនសូត្រ និងកិច្ចការនៅផ្ទះច្រើនហត់នឿយប៉ុនណាក៏ដោយ ក៏ខ្ញុំនៅតែមានសេចក្ដីសុខក្នុងចិត្ត ព្រោះខ្ញុំសង្ឃឹមនិងជឿជាក់ចំពោះការតស៊ូព្យាយាមរបស់ខ្ញុំថា នឹងបានផលល្អនៅពេលខាងមុខ។ សម្លាញ់ដឹងទេ ទីបំផុតការសិក្សារបស់ខ្ញុំត្រូវទទួលបានលទ្ធផលល្អគួរជាទីមោទនៈ។ មិត្តភក្តិរៀនជាមួយគ្នាមានចិត្តអាណិតស្រលាញ់ខ្ញុំ គេបានឱ្យរង្វាន់ខ្ញុំ ពិសេសគឺពួកគេត្រេកអរចំពោះជ័យជំនះរបស់ខ្ញុំគ្រប់ៗគ្នា សូម្បីតែលោកគ្រូក៏សរសើរខ្ញុំមិនដាច់ពីមាត់ថា ខ្ញុំជាសិស្សក្រីក្រតែមានការតស៊ូខ្ពស់ក្នុងការសិក្សា។ ឯសម្លាញ់វិញ

តើការសិក្សាឆ្នាំនេះយ៉ាងណាដែរ? ឆ្នាំនេះជាឆ្នាំប្រលងបញ្ចប់ការសិក្សានៅសាលាចំណេះទូទៅផង ខ្ញុំជឿជាក់ថា សម្លាញ់ពិតជាខំសិក្សាអស់ពីសមត្ថភាពព្រោះថា សម្លាញ់ក៏ជាអ្នកស្រលាញ់ការសិក្សាដែរ ហើយសម្លាញ់មានឪពុកម្ដាយជាអ្នកបីបាច់ថែរក្សា និងជួយលើកទឹកចិត្តនៅពេលណាដែលឯងទទួលបានជោគជ័យក្នុងការសិក្សា។

ព្រមជាមួយគ្នានេះដែរ ខ្ញុំក៏សូមផ្ញើជូនសេចក្ដីនឹករឭកនិងសួរសុខទុក្ខពីចម្ងាយដល់ក្រុមគ្រួសាររបស់ចិន្ដាផង ជាពិសេសលោកពូអ្នកមីងដោយសេចក្ដីនឹករឭកដ៏លើសលប់ក្រៃលែងពីខ្ញុំ។ សព្វថ្ងៃតើគាត់មានសេចក្ដីសុខឬទុក្ខយ៉ាងណាដែរ? បើសម្លាញ់បានទទួលសំបុត្រខ្ញុំហើយ សូមសម្លាញ់ប្រញាប់សរសេរតបមកខ្ញុំវិញផង។

ដោយពេលវេលាពុំអនុញ្ញាត ខ្ញុំលាសម្លាញ់ត្រឹមនេះសិនចុះ យើងនឹងជួបគ្នាដោយផ្ទាល់នៅវិស្សមកាលឆាប់ៗខាងមុខនេះ។

ជាបញ្ចប់ សូមសម្លាញ់និងក្រុមគ្រួសារទទួលបានសេចក្ដីសុខគ្រប់ទិនទិវារាត្រី ហើយសូមឱ្យសម្លាញ់និងក្រុមគ្រួសារជួបប្រទះនឹងពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨

ពីខ្ញុំដែលនៅឆ្ងាយ

............................

## ២- **សំបុត្រសួរសុខទុក្ខបែបពណ៌នា**

### គម្រោងសរសេរសំបុត្រសួរសុខទុក្ខបែបពណ៌នា

**ក- សេចក្ដីផ្ដើម** : ក្បាលសំបុត្រចុះថ្ងៃ... ខែ... ឆ្នាំ... និងការគួរសមឬមនោសញ្ចេតនារបស់អ្នកផ្ញើចំពោះអ្នកទទួល។

**ខ- តួសេចក្ដី** : ជាការបកស្រាយបញ្ហាដែលប្រធានតម្រូវឱ្យសរសេរ។ អ្នកសរសេរត្រូវឆ្លៀតសួរសុខទុក្ខឬជូនព័ត៌មានទៅគ្រួសារដូចគ្នានឹងសំបុត្រសួរសុខទុក្ខធម្មតាដែរ ប៉ុន្តែគួរកត់សម្គាល់ថា ការសួរសុខទុក្ខគួរកុំសរសេរឱ្យលើសពី៥បន្ទាត់ បើលើសត្រឹម១០បន្ទាត់យ៉ាងច្រើនព្រោះការសួរសុខទុក្ខនេះ គ្រាន់តែជាការបន្ទាប់បន្សំប៉ុណ្ណោះនៅក្នុងសំបុត្រពណ៌នា។ នៅក្នុងការសរសេរអ្នកត្រូវបញ្ជាក់អំពី៖

- ❖ មូលហេតុដែលនាំឱ្យយើងធ្វើការពណ៌នាពីប្រធានបទនេះ។
- ❖ ពណ៌នាចំតួ (អ្វីដែលត្រូវពណ៌នា)។
- ❖ យោបល់របស់អ្នកពណ៌នា។

**គ- សេចក្ដីបញ្ចប់** : ដូចសរសេរសំបុត្រសួរសុខទុក្ខធម្មតាដែរ៖

- ❖ ជូនពរសព្ទសាធុការជាពាក្យគួរសម។
- ❖ ហត្ថលេខានិងឈ្មោះអ្នកសរសេរ។

➥ *ក្នុងកិច្ចការប្រលងមិនចាំបាច់ចុះហត្ថលេខានិងឈ្មោះទេ។*

**ប្រធាន** : *ចូរអ្នកសរសេរសំបុត្រពណ៌នារូបនារីម្នាក់ជូនចំពោះឪពុកម្ដាយរបស់អ្នកនៅស្រុកកំណើត។*

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩

គោរពជូនលោកឪពុកអ្នកម្តាយជាទីស្រលាញ់

កូនបានទទួលសំបុត្រពុកម៉ែចុះថ្ងៃទី២៥នោះហើយ។ កូនត្រេកអរណាស់ដោយដឹងថា ពុកម៉ែបានសុខសប្បាយ។ ចំណែករូបកូនសូមពុកនិងម៉ែកុំព្រួយបារម្ភឱ្យសោះ កូនខំយកចិត្តទុកដាក់រៀនសូត្រឥតមានធ្វេសប្រហែសមុខវិជ្ជាណាមួយឡើយ។ គ្រប់មុខវិជ្ជាកូនសុទ្ធតែបានពិន្ទុលើសមធ្យម។ ឯបងផលក៏សុខសប្បាយដែរ។

ពុកម៉ែជ្រាបទេថា បងផលបែបពេញចិត្តនឹងនារីម្នាក់ហើយ។ គាត់ប្រាប់ខ្ញុំថា នឹងអញ្ជើញពុកម៉ែមកលេងភ្នំពេញបានបួនប្រាំថ្ងៃដើម្បីគិតគូរពីរឿងនេះ។ គាត់ពុំបានសរសេរសំបុត្រជម្រាបពុកនិងម៉ែអំពីរឿងនេះឡើយ ប៉ុន្តែខ្ញុំលួចសរសេរមកមុនព្រោះខ្ញុំចង់ជម្រាបពុកនិងម៉ែឱ្យស្គាល់បងស្រីនោះខ្លះៗជាបណ្តើរៗ។ បងស្រីនោះឈ្មោះដានី។ ពុកម៉ែស្តាប់មើលឈ្មោះនេះពីរោះណាស់ ហើយជួនជាមួយនឹងឈ្មោះបងផលទៀតផងគឺ នួន ដានី និង ឱ សុផល។ គាត់ជាគ្រូបង្រៀននៅអនុវិទ្យាល័យមួយ ហើយមានអាយុប្រមាណជាម្ភៃឆ្នាំ។ តាមពិតបងដានីមិនមែនជានារីល្អឆើត ដូចនាងវិសាលដែលម៉ែតែងមានប្រសាសន៍នោះទេ។ គាត់មានកម្ពស់ប្រមាណមួយម៉ែត្រហុកសិបសមល្មមនឹងមាឌរបស់គាត់ ធាត់មិនធាត់ស្គមមិនស្គម តាមយោបល់របស់ខ្ញុំមាឌបងដានីប៉ុណ្ណឹង គឺល្មមនឹងបងផលហើយ។ ខ្ញុំជឿជាក់ថា ពុកម៉ែបានឃើញក៏គង់មានយោបល់ស្របនឹងខ្ញុំមិនខានដែរ។ បងដានីមានសម្បុរ

ស្រអែម។ បងផលគាត់តែងប្រាប់គេឯងថា សម្បុរបែបនេះហើយដែលគេហៅថា សម្បុរមាស។ ភ្នែកបងដានីភ្លឺស្រទន់សមជាមនុស្សមានចរិតស្លូតបូត។ ដូចខ្ញុំជម្រាបម៉ែពុកអ៊ីចឹង បងដានីមិនស្អាតណាស់ណាពេកទេប៉ុន្តែមិនដឹងថា មកពីមូលហេតុអ្វីទេ កាលណាគេសម្លឹងមុខគាត់យូរ គេហាក់ដូចជាជាប់ចិត្តចង់តែសម្លឹងមើលហើយ មើលទៀតរកដកភ្នែកមិនបាន។ ទឹកមុខគាត់ហ្មត់ចត់ជាមនុស្សគិតវែងឆ្ងាយ។ ពេលណាគាត់ញញឹមឬសើចអ្វីៗនៅលើមុខគាត់ ហាក់បកស្រាយពីភាពអធ្យាស្រ័យនិងរាក់ទាក់ស្មោះត្រង់ឥតលាក់លៀម។ ពុកនិងម៉ែប្រហែលស្មានថា ខ្ញុំស្គាល់បងដានីយូរហើយមើលទៅ។ តាមពិតខ្ញុំបានជួបគាត់តែបួនប្រាំដងប៉ុណ្ណោះ។ ប៉ុន្តែចាប់ពីដឹងថា បងផលចាប់ចិត្តទៅលើគាត់មកខ្ញុំក៏ចាប់ផ្ដើមសង្កេតដែរទៅ ដើម្បីឱ្យមានគំនិតខ្លះៗយកមករាយការណ៍ជម្រាបពុកនិងម៉ែដើម្បីកុំឱ្យពុកនិងម៉ែចោទថា មិនជួយឈឺឆ្អាលមើលការខុសត្រូវបងប្អូន។ ខ្ញុំថែមទាំងបានលួចសួរមិត្តម្នាក់ដែលជាប់ញាតិឆ្ងាយរបស់គាត់ផង។ គេប្រាប់ខ្ញុំថា សព្វថ្ងៃបងដានីគ្មានឪពុកម្ដាយទេ គាត់រស់នៅជាមួយនឹងម្ដាយមីង ប៉ុន្តែបើនិយាយពីរឿងសណ្ដាប់ធ្នាប់វិញ អ្នកជិតខាងសរសើរគាត់គ្រប់គ្នាថា គាត់មិនសូវចូលចិត្តដើរលេងដូចនារីក្មេងៗឯទៀតទេ។ ពេលទំនេរគាត់សំងំអានសៀវភៅឬដេរប៉ាក់ស្រោមខ្នើយ អាវ កន្សែងផ្ញើទៅម្ដាយមីងគាត់លក់នៅឯផ្សារ។ រឿងប៉ាក់ឱន ម្រាមដៃ គាត់កម្រើកយ៉ាងញាប់និងប៉ិនប្រសប់មើលមិនទាន់។ ចំណែកក្នុងការបង្រៀនសិស្សវិញ ថ្វីបើគាត់

ទើបចេញពីសាលាបណ្តុះបណ្តាលបានពីរឆ្នាំ ប៉ុន្តែគាត់មានបទពិសោធក្នុងការបង្រៀនសិស្សណាស់ សូម្បីតែលោកនាយកសាលាក៏មានការកោតសរសើរគាត់ដែរ។ ពុកម៉ែ! បើបងផលបានរៀបការនឹងបងដានីខ្ញុំអរណាស់។ តាមមើលទៅមនុស្សកំព្រើកំព្រាអ៊ីចឹងដល់បានបងប្អូនពុកម៉ែមកមុខតែចេះស្រលាញ់គ្នាពុំខាន។ ចំពោះខ្ញុំផ្ទាល់ ខ្ញុំសូមជម្រាបពុកម៉ែតាមត្រង់ទៅចុះ ខ្ញុំក៏លួចស្រលាញ់គាត់ខ្លះៗទៅហើយ។ សំណូមពររបស់ខ្ញុំ គឺសូមពុកម៉ែជួយជ្រោមជ្រែងឱ្យបងផលបានរៀបការជាមួយនឹងបងដានី ក្នុងពេលឆាប់ៗនេះកុំបីខាន។

ជាទីបញ្ចប់នេះ កូនសូមគោរពជូនពរលោកពុកអ្នកម៉ែឱ្យមានសុខភាពល្អដើម្បីជាម្លប់ដ៏ត្រជាក់នៃកូនទាំងពីរ។

ដោយក្តីស្រលាញ់នឹករឭកនិងគោរពពីកូនដែលនៅឆ្ងាយ

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤

ហត្ថលេខា

.........................

# ប្រធានពន្យល់

ប្រធានពន្យល់ គឺជាការអធិប្បាយស្រាយបំភ្លឺគំនិតទស្សនវិទូ អ្នករិះគន់តួអង្គអក្សរសិល្ប៍ណាម្នាក់ ការបកស្រាយបញ្ហាសាំញ៉ាំនៅក្នុងជីវភាពសង្គមជាក់ស្ដែងឬក្នុងស្នាដៃអក្សរសិល្ប៍ និងប្រើសិល្ប៍វិធីមធ្យោបាយបែបណាដើម្បីឱ្យយល់ច្បាស់ពីខ្លឹមសារ មតិ គំនិត ទស្សនៈ បញ្ហាទាំងនោះ។

ដើម្បីស្គាល់ប្រធានពន្យល់គេត្រូវតែពិនិត្យលើបម្រាប់ពាក្យ៖

***ក- ចំណោទសួរ*** : ប្រធានពន្យល់គេអាចសម្គាល់ពាក្យចោទសួរមួយចំនួនដូចជា៖

- ❖ តើ...?
- ❖ តើអ្វីខ្លះ...?
- ❖ ហេតុអ្វី...?
- ❖ ហេតុដូចម្ដេច...?
- ❖ ពីព្រោះអ្វី...?
- ❖ មូលហេតុ...?

ម្យ៉ាងទៀត គឺសម្គាល់ដោយសារនៅចុងប្រយោគមានពាក្យ៖

❖ ......យ៉ាងណាខ្លះ?

❖ ......យ៉ាងដូចម្ដេច?

❖ ......បែបណាខ្លះ?

❖ ......មានប៉ុន្មានយ៉ាង?

❖ ......អ្វីខ្លះ?

**៩- ពាក្យបង្គាប់បញ្ជា** : ប្រធានពន្យល់អាចសម្គាល់បានដោយសារពាក្យបង្គាប់បញ្ជាបន្ថែមទៀត ដូចជា៖

❖ ចូរធ្វើនិទស្សន៍

❖ ចូរបង្ហាញ

❖ ចូរពន្យល់

❖ ចូរស្រាយបំភ្លឺ

❖ ចូរបញ្ជាក់

❖ ចូរវិភាគ

❖ ចូរឆ្លុះបញ្ចាំង

❖ ចូរបកស្រាយ។

## ទម្រង់សរសេរសេចក្ដីអធិប្បាយ

**១- ផ្ដើមសេចក្ដី** : ពុំមែនជាការបកស្រាយឬបញ្ចេញមតិយោបល់ ឬក៏បញ្ជាក់ថា ទស្សនៈដែលប្រធានលើកយកមកចោទនោះត្រូវឬខុស មានលក្ខណៈបែបណានោះទេ គ្រាន់តែនាំអារម្មណ៍អ្នកអានឱ្យចូលដល់ការបកស្រាយយ៉ាងពិស្ដារនៅតួសេចក្ដី ដោយគ្រាន់តែចោទជាបញ្ហា

ដើម្បីឱ្យអ្នកអានមានចម្ងល់និងចង់ដឹងចង់យល់តទៅទៀត។ វាមានសារៈសំខាន់ណាស់ ដូច្នេះអ្នកសរសេរត្រូវសរសេរឱ្យខ្លីល្មមនិងត្រូវផ្ចិតផ្ចង់បំផុត។

នៅក្នុងសេចក្តីផ្តើមគេចែកជាបីផ្នែក៖

❖ លំនាំបញ្ហា : ជាការដឹកនាំសេចក្តីឱ្យទាក់ទងទៅនឹងប្រធានដែលបានចោទ។ នៅក្នុងផ្នែកនេះអ្នកសរសេរមិនត្រូវបង្ហាញការរិះគិតវែងឆ្ងាយពេកទេ តែត្រូវមានការផ្ចិតផ្ចង់បំផុត ហើយទាមទារការសរសេរព្រាងសេចក្តីជាមុនសិន។ ផ្នែកនេះត្រូវចេះលើកទៅតាមការចោទរបស់ប្រធានដូចជា បើប្រធានគេចោទជាលក្ខណៈអក្សរសិល្ប៍ អ្នកត្រូវធ្វើលំនាំបែបអក្សរសិល្ប៍ បើចោទបែបសុភាសិតអ្នកត្រូវធ្វើលំនាំបែបសុភាសិតដែរ។ ការចេះធ្វើលំនាំតាមលក្ខណៈនៃប្រធានបានចោទនោះនាំឱ្យការសរសេររបស់យើងងាយស្រួល ហើយមានគំនិតទូលាយទៀតផង។ នៅចំណុចនេះត្រូវចាប់ដើមបន្ទាត់វែងបន្តិច គឺប្រមាណជា៣សង់ទីម៉ែត្រដើម្បីសម្គាល់ចំណុចសេចក្តីផ្តើម។

❖ ចំណូលបញ្ហា : ត្រូវលើកយកគំនិតប្រធានមកបង្ហាញដោយគ្រាន់តែមានឃ្លាភ្ជាប់សេចក្តីឱ្យបានត្រឹមត្រូវ និងដាក់ប្រធាននោះនៅក្នុងសញ្ញា “...” ជាការស្រេច។

❖ ចំណោទបញ្ហា : ត្រូវចោទសួរទៅតាមលំនាំរបស់ប្រធានដែលបានចោទ។ ការចោទជាបញ្ហានេះ អ្នកចេះចោទតាមប្រភេទប្រធានថាតើប្រធានពន្យល់គេត្រូវចោទរបៀបម៉េច? ប្រធានពិភាក្សាគេត្រូវចោទ

របៀបម៉េច? ពិសេសការចោទចំណោទបញ្ហានេះ អ្នកអានអាចនឹងដឹងថា តើអ្នកសរសេរមានគម្រោងបែបណា ហើយស្គាល់ប្រភេទប្រធានឬទេ? តើអ្នកអាចយល់បញ្ហារបស់ប្រធានបានទេ? នៅចំណុចនេះអ្នកសរសេរត្រូវចាប់ផ្ដើមបន្ទាត់សម្គាល់កថាខណ្ឌថ្មី តែមិនត្រូវចោទវែងដូចចំណុចលំនាំបញ្ហាទេ។

**២- តួសេចក្ដី** : អ្នកសរសេរត្រូវរៀបចំគំនិតសរសេររបស់ខ្លួនឱ្យមានសណ្ដាប់ធ្នាប់ ហើយមានទំនាក់ទំនងគ្នាតាមលំដាប់លំដោយពីលើមកក្រោមនិងត្រូវឈានពីបញ្ហាបន្ទាប់បន្សំទៅបញ្ហាសំខាន់។ មុនឆ្លងពីគំនិតមួយទៅគំនិតមួយទៀត អ្នកសរសេរចាំបាច់ត្រូវមានឃ្លាភ្ជាប់សេចក្ដី។ ការបកស្រាយត្រូវមានឧទាហរណ៍មកបង្ហាញឱ្យបានច្បាស់ដើម្បីបញ្ជាក់ការពន្យល់ឱ្យរឹតតែល្អថែមទៀត។ រីឯឧទាហរណ៍ដែលលើកយកមកបង្ហាញនេះគឺ ត្រូវចេះច្រិចយកតែខ្លឹមសារសំខាន់ៗប៉ុណ្ណោះ កុំសរសេរវែងអន្លាយបែបជាសង្ខេបរឿង។

នៅក្នុងតួសេចក្ដី *(ប្រធានពន្យល់ទូទៅ)* ចែកចេញជា៖

❖ ឃ្លាភ្ជាប់សេចក្ដី : ជាប្រយោគខ្លីសម្រាប់ភ្ជាប់សេចក្ដីបកស្រាយប្រធាន។ ឃ្លាភ្ជាប់សេចក្ដីនេះមិនគួរសរសេរវែងពេកទេ គេអាចប្រើឃ្លាភ្ជាប់ខ្លីៗបានហើយ។

❖ ពន្យល់ពាក្យ : ជាការជ្រើសរើសពាក្យគន្លឹះសំខាន់ៗនៅក្នុងប្រធានមកពន្យល់ដោយដាក់នៅក្នុងសញ្ញា "..." រួចក៏ចាប់ពន្យល់ន័យយកតែម្ដងដោយមិនចាំបាច់ដាក់ថ្នាក់ពាក្យទេ។ នៅផ្នែកឃ្លាភ្ជាប់សេចក្ដី

និងពន្យល់ពាក្យត្រូវសរសេរដាក់មួយកថាខណ្ឌ។ ដោយឡែកឃ្លាភ្ជាប់សេចក្តីត្រូវចាប់ដើមបន្ទាត់វែងជាងគេ ព្រោះជាចំណុចសម្គាល់តួសេចក្តី ក្រៅពីនេះការចាប់កថាខណ្ឌថ្មីមិនចាំបាច់វែងដូចនោះទេ គឺប្រមាណជា១សង់ទីម៉ែត្របានហើយ។

❖ ពន្យល់ប្រធាន : ជាការពន្យល់តែន័យចម្បងរបស់ប្រធានតែប៉ុណ្ណោះមិនត្រូវសរសេរវែងពេកទេ ហើយក៏កុំក្បោះក្បាយដែរ។ នៅចំណុចនេះ គឺពន្យល់បែបយ៉ាងណាធ្វើឱ្យអ្នកអានចាប់អារម្មណ៍ទៅលើការបកស្រាយបន្ថែមទៀតនៅចំណុចខាងក្រោម។ ការពន្យល់ប្រធានអ្នកសរសេរត្រូវចាប់កថាខណ្ឌថ្មីដែរ ហើយសរសេរមិនគួរឱ្យលើសពី៣បន្ទាត់ ហើយបើច្រើនត្រឹម៥បន្ទាត់ជាកំណត់ សរសេរវែងពេកនាំឱ្យអស់គំនិតនៅពេលដែលចាប់សរសេរនៅចំណុចបកស្រាយប្រធាន។

❖ បកស្រាយប្រធាន : ត្រូវបកស្រាយលម្អិតទៅលើចំណុចពន្យល់ប្រធានបន្ថែមទៀត។ ការពន្យល់លម្អិតនេះទាមទារការពិនិត្យអត្ថន័យស៊ីជម្រៅណាស់ទៅលើខ្លឹមសារប្រធាន។ ចំណុចនេះត្រូវចាប់កថាខណ្ឌឬដើមបន្ទាត់ថ្មីមួយទៀត គឺស្មើនឹងចំណុចតូចៗក្នុងតួសេចក្តី ដូចជាពន្យល់ប្រធានជាដើម ដើម្បីសម្គាល់ការមកដល់ចំណុចបកស្រាយប្រធាន។ ផ្នែកនេះត្រូវលើកឧទាហរណ៍បញ្ជាក់ឱ្យបានច្បាស់លាស់៖

❖ ការលើកឧទាហរណ៍ : ជាការលើកភស្តុតាងមកបង្ហាញដើម្បីឱ្យការបកស្រាយរបស់យើង មានលក្ខណៈទូលំទូលាយនិងមានបែបផែនត្រឹមត្រូវទៀតផង។ ចំណុចឧទាហរណ៍ត្រូវចាប់កថាខណ្ឌមួយទៀត។

ការលើកឧទាហរណ៍មានចំនួន៣ដែលត្រូវធ្វើ ដូចជា៖

- *ឧទាហរណ៍ក្នុងប្រវត្តិសាស្ត្រ* ៖ ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ហើយបានចងក្រងជាគម្ពីរ ជាសាស្ត្រាដោយមានការចុះកាលបរិច្ឆេទច្បាស់លាស់។ អ្នកសរសេរតែងសេចក្ដីមិនត្រូវសរសេរការបកស្រាយខ្លួនជាលេខទេត្រូវសរសេរជាអក្សរជានិច្ច។ ការលើកឧទាហរណ៍នៅចំណុចនេះ គឺធ្វើឡើងតាមការលើកបានប៉ុណ្ណោះ បានន័យថា បើមានត្រូវលើក តែបើគ្មានមិនគួរគប្បីព្យាយាមលើកមកបង្ហាញទេ។

- *ឧទារបាណ៍ក្នុងសង្គម* ៖ ចំណុចនេះសំខាន់ណាស់គ្រប់ប្រធានឬទស្សនៈដែលបានចោទ គឺសុទ្ធតែមានពិតនៅក្នុងសង្គមទាំងអស់។ អ្នកសរសេរដាច់ខាតត្រូវលើកមកបង្ហាញជានិច្ច ហើយយ៉ាងហោចណាស់ក៏ត្រូវមាន៣ឬ៤ចំណុចដែរ។ ចំណុចដែលលើកមកនេះគឺត្រូវមានជាប់ទាក់ទងជាមួយនឹងប្រធានបទដែលបានចោទ។

- *ឧទាហរណ៍ក្នុងអក្សរសិល្ប៍* ៖ អក្សរសិល្ប៍ដែលលើកមកបង្ហាញ ត្រូវតែច្បាស់លាស់ថា មានក្នុងកម្មវិធីសិក្សាជានិច្ច។ ប្រសិនបើអ្នករៀនត្រឹមថ្នាក់ទី៩ ត្រូវលើកមកតែក្នុងកម្មវិធីសិក្សាត្រឹមថ្នាក់ទី៩ចុះមកក្រោម។ ប្រសិនអ្នករៀនដល់ថ្នាក់ទី១២ ត្រូវលើកមកតែក្នុងកម្មវិធីសិក្សាត្រឹមថ្នាក់ទី១២ ចុះមកក្រោមជានិច្ច។ ការលើកអក្សរសិល្ប៍មកបង្ហាញ គឺធ្វើឡើងដោយសង្ខេបមូលន័យតែប៉ុណ្ណោះ មិនមែនជាការសង្ខេបអត្ថបទរឿងទាំងស្រុងទេ។ ប្រសិនជាការលើកនេះមានជាប់ជាមួយនឹងសម្ដីតួអង្គ អ្នកត្រូវដាក់សម្ដីនោះនៅក្នុងសញ្ញា “...” នេះ

ជាដរាប។ ការលើកឧទាហរណ៍ដែលសមស្ួនអាចមានពីពរឿងទៅ។

❖ **សំយោគគំនិត** : ជាការប្រមូលផ្តុំគំនិតដែលសរសេរដាក់នៅក្នុងការសន្និដ្ឋានមួយតែមិនត្រូវឱ្យមានទំហំវែងអន្លាយទេ។ នៅចំណុចនេះអ្នកសរសេរត្រូវចាប់កថាខណ្ឌថ្មីបន្ថែមទៀត ដើម្បីសម្គាល់ថា មកដល់ចំណុចចុងបញ្ចប់នៃតួសេចក្តីហើយ។ អ្នកគួរសរសេរត្រឹមចំនួន៥បន្ទាត់ បើច្រើនត្រឹម១០បន្ទាត់ជាកំណត់ មិនត្រូវឱ្យលើសពីនេះទេ ព្រោះអាចជាន់សេចក្តីពន្យល់របស់យើងនៅចំណុចបកស្រាយប្រធាន។

**៣- សេចក្តីបញ្ចប់** : ជាការសរុបធំទៅលើការបកស្រាយនៅផ្នែកខាងលើ។ ការសរសេរសេចក្តីបញ្ចប់មិនទាមទារឱ្យវែងពេកទេ តែឱ្យមានការគោរពលក្ខខណ្ឌទាំងពីរចំណុចរបស់ប្រធាន៖

❖ **វង្វាយតម្លៃប្រធាន** : ជាការឆ្លើយទៅនឹងចំណោទបញ្ហាដែលបានចោទខាងលើ។ ការធ្វើវង្វាយតម្លៃប្រធានគ្រាន់តែជាការធ្វើសេចក្តីថា ប្រធាននេះមានខ្លឹមសារអប់រំយ៉ាងណាដែរ? អាចប្រើបានជាសកលមានចំណុចវិជ្ជមានអ្វីខ្លះ? ផ្តល់ពុទ្ធិសម្រាប់អ្នកអានឬអ្នកសិក្សាដែរឬទេ? ការធ្វើវង្វាយតម្លៃនេះមិនតម្រូវឱ្យវែងពេកទេ ប្រហែលជា៥បន្ទាត់ ឬ៦បន្ទាត់បានហើយ។ ចំណុចនេះជាចំណុចបញ្ចប់សេចក្តី អ្នកសរសេរត្រូវចាប់ដើមបន្ទាត់ឱ្យស្មើនឹងចំណុចលំនាំបញ្ហា ជាសេចក្តីផ្តើមឬចំណុចឃ្លាភ្ជាប់សេចក្តីក្នុងចំណុចតួសេចក្តីដែរ។ ប្រសិនជាចំណុចធំៗទាំងពីរខាងលើចោលបន្ទាត់ត្រឹមប៉ុន្មាន នៅចំណុចនេះក៏ត្រូវចោលបន្ទាត់ត្រឹមប៉ុណ្ណឹងដែរចៀសវាងការចោលបន្ទាត់វែងខ្លី។

❖ មតិផ្ទាល់ខ្លួន : ជាការសំណូមពរនិងដើម្បីរចនាបថផងនោះ នៅចំណុចនេះត្រូវចាប់កថាខណ្ឌថ្មីមួយទៀត តែមិនត្រូវឱ្យបន្ទាត់វែងស្មើនឹងចំណុចវង្វាយតម្លៃប្រធានឡើយ។ នៅចំណុចនេះ គឺជាការចាប់អារម្មណ៍ទៅលើការបកស្រាយ និងជាការបញ្ចេញទស្សនៈផ្ទាល់ខ្លួន ដើម្បីបានជាគន្លឹះល្អនៅក្នុងការប្រើប្រាស់លើការសិក្សាអប់រំ។

ប្រធានពន្យល់មាន៤បន្ថែមទៀត គឺពន្យល់បែបសុភាសិត ពន្យល់ទស្សនៈទូទៅឬពាក្យស្លោក ពន្យល់ជាលក្ខណៈប្រៀបធៀប និងពន្យល់លក្ខណៈចោទជាសំណួរ។

ខាងក្រោមនេះនឹងសិក្សាម្តងមួយៗ ដើម្បីឱ្យកាន់តែច្បាស់លាស់ថែមទៀតទៅលើប្រភេទប្រធានពន្យល់នីមួយៗ៖

## ១- ប្រធានពន្យល់បែបសុភាសិត

ប្រធាននេះ បកស្រាយវែកញែកទៅលើសុភាសិត ដើម្បីរកខ្លឹមសារអប់រំដែលមានបង្កប់នៅក្នុងនោះ។ សុភាសិតអាចមានន័យពីរ គឺន័យត្រង់និងន័យធៀប តែជួនកាលក៏មានតែន័យត្រង់ គ្មានន័យធៀបនៅក្នុងនោះដែរ។

### គម្រោងបកស្រាយប្រធានពន្យល់បែបសុភាសិត

**ក- សេចក្តីផ្តើម** : ចែកជា៣សំខាន់ៗ៖

❖ លំនាំបញ្ហា : លើកយកបញ្ហាផ្សេងៗឱ្យជាប់ទាក់ទងជាមួយនឹងសុភាសិតមកសរសេរបង្ហាញ។

❖ ចំណោលបញ្ហា : ធ្វើឃ្លាភ្ជាប់សេចក្តីមួយ រួចលើកយកទស្សនៈ

ប្រធានមកដាក់នៅក្នុងសញ្ញា “...”។

❖ **ចំណោទបញ្ហា** : ជាការចោទសួរតាមលក្ខណៈប្រធានពន្យល់។ បើជាប្រធានសុភាសិត ការចោទសួរក៏តាមលក្ខណៈសុភាសិតដែរ។

**៩- តួសេចក្តី** : បកស្រាយដោយពិស្តារដោយមានឧទាហរណ៍ច្បាស់លាស់។ នៅផ្នែកនេះគេអាចចែកជា៖

❖ ឃ្លាឆ្នាប់សេចក្តី : “ប្រធានមានពាក្យដែលត្រូវពន្យល់”។

❖ **ពន្យល់ពាក្យ** : មុននឹងដល់ពន្យល់ពាក្យ គឺត្រូវមានឃ្លាភ្ជាប់សេចក្តី។ ទាំង២ចំណុចនេះត្រូវដាក់១កថាខណ្ឌ។

❖ **ពន្យល់ប្រធាន** : គ្រាន់តែជាការពន្យល់ច្បោលៗពីអត្ថន័យរបស់ប្រធានដែលបានចោទ។ ចំណុចនេះដាក់១កថាខណ្ឌ។ អ្នកសរសេរមិនត្រូវពន្យល់វែងពេកទេ ព្រោះអាចជាន់ដល់ការបកស្រាយប្រធាន។

❖ បកស្រាយប្រធាន

*ក- បកស្រាយន័យត្រង់* : បកស្រាយន័យដែលសុភាសិតបានលើកឡើង។ នៅចំណុចនេះ គេមិនត្រូវនិយាយអ្វីក្រៅពីន័យប្រធានឡើយ ហើយពន្យល់ឱ្យអស់សេចក្តីរបស់ប្រធាន។ ឧទាហរណ៍ថា ប្រធានគេលើកឡើងពី “ទូកទៅកំពង់នៅ” នៅចំណុចបកស្រាយនេះ គឺនិយាយតែពីទូកនិងកំពង់ប៉ុណ្ណោះ។ ចំណុចបកស្រាយន័យត្រង់នេះត្រូវដាក់នៅ១កថាខណ្ឌដែរ។

*ខ- បកស្រាយន័យធៀប* : ការធ្វើទំហៀបន័យរបស់សុភាសិតមករកតម្លៃនៃការអប់រំវិញ។ ឧទាហរណ៍ពាក្យ *“ទូក”* គេប្រៀបបាននឹង

អ្វី? ចំណែកពាក្យថា *"កំពង់"* គេប្រៀបបាននឹងអ្វី? ប្រៀបធៀបចប់ត្រូវពន្យល់អត្ថន័យដែលរកឃើញក្នុងន័យធៀបនេះឱ្យអស់សេចក្តី មុននឹងចូលដល់ការលើកយកឧទាហរណ៍មកបញ្ជាក់បន្ថែម។ ចំណុចនេះគប្បីដាក់១កថាខណ្ឌដែរ។

- *ការលើកឧទាហរណ៍មកបញ្ជាក់* : នៅមុនពេលលើកឧទាហរណ៍អ្នកត្រូវប្រើឃ្លាភ្ជាប់សេចក្តីមួយដែរ។ នៅចំណុចនេះត្រូវសរសេរតែ១កថាខណ្ឌ។ ឧទាហរណ៍ដូចជា ប្រវត្តិសាស្ត្រ សង្គម អក្សរសិល្ប៍។ ចំណុចលើកក្នុងប្រវត្តិសាស្ត្រប្រសិនបើមិនមាននៅក្នុងប្រវត្តិសាស្ត្រទេ អ្នកមិនគប្បីលើកមកបង្ហាញឡើយ។ ចំណែកក្នុងសង្គមនិងក្នុងអក្សរសិល្ប៍ត្រូវតែលើកមកបង្ហាញជានិច្ច ដោយខានមិនបានឡើយ។

❖ សំយោគគំនិត : ការធ្វើសេចក្តីរួមខ្លីមួយទៅលើការបកស្រាយខាងលើដោយមិនឱ្យវែងពេកទេ។ នៅចំណុចនេះត្រូវចាប់១កថាខណ្ឌដែរមុនចាប់ផ្តើមសរសេរ។

**គ- សេចក្តីបញ្ចប់** : មាន២កថាខណ្ឌដែលចែកចេញជា៖

❖ វង្វាយតម្លៃប្រធាន : ជាការឆ្លើយតបទៅនឹងសំណួរដែលបានចោទនៅសេចក្តីផ្តើមចំណុចចំណោទបញ្ហា ដោយគ្រាន់តែឆ្លើយថា តើប្រធាននេះអប់រំអំពីអ្វី? ដើម្បីអ្វី? មានអត្ថន័យស៊ីជម្រៅនៅគ្រប់សម័យកាលឬទេ?

❖ មតិផ្ទាល់ខ្លួន : ជាការបញ្ចេញគំនិតផ្ទាល់ខ្លួនចំពោះប្រធាន។

អ្នកសរសេរ អាចប្រើសព្វនាមបុរិសៈបុរសទី១ពហុវចនៈ យកមកសរសេរបាន។ ចំណុចនេះគប្បីសរសេរជាក់១កថាខណ្ឌដែរ។

**ប្រធាន** : *សុភាសិតមួយបានពោលថា "ទឹកត្រជាក់ត្រីកុំ" ។ តើសុភាសិតនេះមានអត្ថន័យយ៉ាងណា? ចូរបកស្រាយ។*

**សេចក្តីអធិប្បាយ**

**ក- ផ្តើមសេចក្តី**

❖ លំនាំបញ្ហា : ការមានទំនាក់ទំនងគ្នាជារឿងចាំបាច់បំផុតសម្រាប់រស់នៅរបស់មនុស្សក្នុងសង្គម។

❖ ចំណូលបញ្ហា : ដោយសង្កេតឃើញថា ទំនាក់ទំនងនេះពុំទាន់បានល្អ ស្មោះត្រង់ និងស្អិតរមួតនៅឡើយនោះ ទើបបុព្វបុរសខ្មែរយើងបានលើកយកសុភាសិតមួយឃ្លាថា "ទឹកត្រជាក់ត្រីកុំ"។

❖ ចំណោទបញ្ហា : តើសុភាសិតនេះមានអត្ថន័យយ៉ាងណាដែរ?

**ខ- តួសេចក្តី**

❖ ឃ្លាឆ្នាប់សេចក្តី : ប្រធានមានពាក្យគន្លឹះដែលត្រូវពន្យល់។

❖ ពន្យល់ពាក្យ : ពាក្យថា "កុំ" នៅទីនេះមានន័យថា ប្រមូលផ្តុំគ្នា ឬមកប្រជុំគ្នាច្រើនឡើងៗ។

❖ ពន្យល់ប្រធាន : ប្រធានមានន័យថា ស្រះឬប្រឡាយឬក៏ទន្លេដែលមានទឹកត្រជាក់ គឺត្រីតែងមកប្រមូលផ្តុំគ្នារស់នៅយ៉ាងច្រើនទីនោះ ព្រោះត្រីមិនត្រូវការរស់នៅក្នុងទឹកក្តៅទេ។

❖ បកស្រាយប្រធាន : (បកស្រាយន័យត្រង់) តាមធម្មជាតិត្រី ត្រូវរស់នៅក្នុងទឹក តែការរស់នៅក្នុងទឹក ត្រីក៏បានជ្រើសរើសទឹកដែលអាចផ្ដល់សេចក្ដីសុខសាន្តឱ្យវាផងដែរ។ តាមធម្មតាពេលណាដែលមានទឹកភ្លៀងជន់ពេញស្រែឬពេលទឹកទន្លេឡើង ត្រីតែងចេញពីបឹងបួ ព្រែកទន្លេទៅរស់នៅកន្លែងថ្មី ដើម្បីពងនិងងាយស្រួលរកចំណី។ លុះពេលភ្លៀងឈប់ធ្លាក់ ទឹកទន្លេក៏ចាប់ផ្ដើមស្រក ត្រីក៏តែងចុះមកតាមទឹកដើម្បីរស់នៅកន្លែងណាមួយជាទីកក់ក្ដៅ ហើយវាយល់ថា ជាកន្លែងដែលអាចផ្ដល់សេចក្ដីសុខដល់វាបានឬត្រូវវិលត្រលប់ទៅរកកន្លែងដើម ដែលមានទឹកត្រជាក់នោះវិញ។ បើត្រីធ្លាប់រស់នៅនឹងកន្លែងដែលមានទឹកត្រជាក់ហើយ ទោះបីជាត្រីត្រូវឆ្លងកាត់ឧបសគ្គយ៉ាងណាក៏ត្រីត្រូវធ្វើដំណើរទៅរកកន្លែងដែលមានទឹកត្រជាក់នោះវិញជាដរាប។

ទឹកត្រជាក់មាននៅកន្លែងដែលមានម្លប់ឈើ មានសម្រាស់ និងមានផ្ទៃទឹកទូលាយ។ ត្រីនិងទឹកអាស្រ័យគ្នាទៅវិញទៅមក។ ទឹកជាពំនឹងរបស់ត្រី តែបើទឹកក្ដៅហើយត្រីច្បាស់ជាពុំអាចរស់នៅបានទេពួកវាប្រាកដជាគេចទៅរកទឹកថ្មីដែលត្រជាក់ដើម្បីជ្រកកោនពុំខាន។

❖ បកស្រាយន័យធៀប : សុភាសិតនេះបុព្វបុរសបានបង្កប់នូវអត្ថន័យអប់រំយ៉ាងទូលំទូលាយសម្រាប់ណែនាំមនុស្ស ដែលរស់នៅក្នុងសង្គម គឺ “ត្រី” ប្រៀបបាននឹងមនុស្សក្រីក្រ គ្មានទ្រព្យសម្បត្តិ គ្មានចំណេះវិជ្ជា គ្មានអំណាច សំដៅដល់ប្រជាជនដែលរស់នៅក្នុងប្រទេសណាមួយទាំងមូល។ រីឯ “ទឹក” គឺប្រៀបបាននឹងមនុស្សដែលមាន

ទ្រព្យសម្បត្តិ មានចំណេះវិជ្ជាខ្ពង់ខ្ពស់ មានអំណាច មានលទ្ធភាពគ្រប់បែបយ៉ាង សំដៅដល់អំណាចដែលគ្រប់គ្រងប្រជាជនក្នុងប្រទេសណាមួយទាំងមូល។

ដោយពិនិត្យឃើញទំនាក់ទំនងពុំទាន់ស្និតរមួត ពុំមានសមភាពនឹងគ្នា គឺនៅមានការប្រើអំណាចជិះជាន់យ៉ាងឃោរឃៅកេងប្រវញ្ចមកលើអ្នកតូចតាច ទើបបុព្វបុរសបានអប់រំយើងឱ្យធ្វើចិត្តជា "ទឹកត្រជាក់ត្រីកុំ"។ ទឹកត្រជាក់សំដៅដល់ធម្មជាតិគ្រប់បែបយ៉ាងដែលអ្នកគ្រប់គ្រងត្រូវប្រកាន់យកក្នុងការដឹកនាំប្រទេស។ អ្នកគ្រប់គ្រងល្អត្រូវមានចិត្តល្អសន្ដោសប្រោសប្រណីមិនរើសមុខ ប្រកបដោយគតិយុត្តិធម៌មិនលម្អៀងពិសេស គឺលោកត្រូវចេះអាណិតអាសូរជួយស្វែងរកយុត្តិធម៌សេរីភាពសុភមង្គលជូនប្រជាជននៅក្រោមបង្គាប់ ឬប្រជាជននៅក្នុងប្រទេសទាំងមូល។ បុព្វបុរសយើងមានឧត្តមគតិខ្ពស់ណាស់ លោកចង់អប់រំយ៉ាងណាកុំឱ្យសាមគ្គីភាពរវាងអ្នកគ្រប់គ្រងដឹកនាំ មានការប្រេះឆាជាមួយនឹងអ្នកដែលត្រូវគ្រប់គ្រង ព្រោះថាអ្នកទាំងនោះមានពំនឹងមកលើអ្នកដឹកនាំយ៉ាងមុតមាំណាស់។ បើអ្នកដឹកនាំក្លាយជាទឹកក្ដៅ ពេលនោះគេពុំអាចរស់ក្រោមការត្រួតត្រាដ៏អយុត្តិធម៌ ខ្វះសេចក្ដីសន្ដោសមេត្តាបានឡើយ ពួកគេប្រាកដជារត់ទៅជ្រកកោននៅកន្លែងថ្មីមួយទៀតដែលមានទឹកត្រជាក់ល្អដើម្បីរស់នៅពុំខាន។ ភាពជាអ្នកគ្រប់គ្រងឬជាអ្នកដឹកនាំត្រូវធ្វើខ្លួនឱ្យក្លាយជាទឹកត្រជាក់ ដើម្បីឱ្យត្រីទាំងឡាយប្រមូលគ្នាមករស់នៅដោយសប្បាយរីករាយក្រោមម្លប់ដ៏ត្រជាក់របស់ខ្លួន។

- *ឧទាហរណ៍ក្នុងប្រវត្តិសាស្ត្រ* : នៅរបបប្រល័យពូជសាសន៍ ដែលរបបនោះប្រជាជនខ្មែរយើងរស់នៅលំបាកវេទនាបំផុត ស៊ីអត់ ស៊ីឃ្លាន ព្រាត់ប្រាសពីគ្នា ប្ដី ប្រពន្ធ កូន ឪពុក ម្ដាយ ពិសេសគឺពួកវា បានកាប់សម្លាប់ប្រជាជនដោយឥតញញើតដៃ។ នេះគឺជារបបទឹកក្ដៅ ដែលពុំអាចផ្ដល់សេចក្ដីសុខឱ្យប្រជាជនជាត្រី រស់នៅក្រោមការត្រួតត្រា របស់ខ្លួនបានឡើយ។ នៅទីបំផុតប្រជាជនយើងបាននាំគ្នាក្រោកឈរ តស៊ូវាយផ្ដួលរំលំរបបទឹកក្ដៅឱ្យវិនាសសាបសូន្យ ហើយរួមរស់នៅ ក្រោមរបបគ្រប់គ្រងថ្មីជារបបទឹកត្រជាក់ និងបានផ្ដល់សេចក្ដីសុខដល់ ប្រជាជនតាំងពីក្រុងរហូតដល់ជនបទនាពេលបច្ចុប្បន្ននេះ។

- *ឧទាហរណ៍ក្នុងសង្គម* : លើសពីនេះទៅទៀតបើសម្លឹងនៅ ក្នុងគ្រួសារមួយមានប្រើអំពើហិង្សា ដូចជាប្ដីវាយធ្វើបាបប្រពន្ធកូនស្ទើរ រាល់ថ្ងៃនោះឃើញថា រស្មីសុភមង្គលនៃគ្រួសារត្រូវរលត់សោះសូន្យ ជីវិតហាក់ដូចជាគ្មានខ្លឹមសារអ្វីទាំងអស់។ ផ្ទុយទៅវិញបើគ្រួសារនោះ មានឪពុកម្ដាយចេះផ្ដល់ព្រហ្មវិហារធម៌ដល់កូន ប្ដីចេះយល់ចិត្តប្រពន្ធ ប្រពន្ធចេះយល់ចិត្តប្ដី គ្រួសារនោះប្រាកដជាទទួលបានសេចក្ដីសុខ ហើយកូនចៅប្រាកដរស់នៅដោយសុភមង្គលជាពុំខាន។

- *ឧទាហរណ៍ក្នុងអក្សរសិល្ប៍* : នៅក្នុងវណ្ណកម្មអក្សរសិល្ប៍ រឿងកុលាបប៉ៃលិនដែលជាស្នាដៃរបស់លោក **ញ៉ុក ថែម** ឃើញថា ដោយមានក្ដីអាណិតស្រលាញ់កម្មករ បានបណ្ដាលឱ្យពួកគេខិតខំធ្វើការ បម្រើលោក **ហ្លួងរតនសម្បត្តិ** ដោយអស់ពីចិត្តថ្លើម ពិសេសពួកគេរស់

ដោយសេចក្តីសុខបំផុតនិងស្មោះត្រង់ជាមួយនឹងលោកជាដរាប។ នៅពេលដែលលោកហ្លួងរតនសម្បត្តិជួបគ្រោះអាសន្ន គឺជួបចោរប្លន់ទាំងពីរលើក ពួកគេបានជួយលោកឱ្យរួចផុតគ្រោះថ្នាក់ដោយជោគជ័យ។ ទាំងនេះដោយសារតែហ្លួងរតនសម្បត្តិប្រកាន់ធម៌ជាទីកត្រជាក់ និងបានផ្តល់សេចក្តីសុខគ្រប់បែបយ៉ាងដល់ហ្វូងត្រីទាំងឡាយ គឺពួកកម្មករជាដើម។ ដូចគ្នានេះដែរនៅក្នុងរឿងភូមិតិរច្ឆាន ស្នាដៃនិពន្ធរបស់លោក **ឌឿក អំ** និង លោក **ឌឹក គាម** បានបង្ហាញពីរបបទឹកក្តៅដែលពួកអាណានិគមនិយមបារាំង បានដាក់នឹមដែកមកលើប្រទេសកម្ពុជាជិតមួយសតវត្សរ៍ ហើយបានបង្កទុក្ខលំបាកវេទនាដល់ប្រជាជនយ៉ាងច្រើនរាប់មិនអស់។ ប្រជាជនរស់នៅដោយភាពភ័យខ្លាចខ្វះសុវត្ថិភាពមួយរយភាគរយ។ បារាំងបានជំរិតទារពន្ធពីប្រជាជនដ៏ធ្ងន់ហួសហេតុរហូតដល់មានការចាប់ឃុំឃាំងប្រជាជនណា ដែលគ្មានប្រាក់សម្រាប់បង់ពន្ធឱ្យវាទៀតផង។ អត់ទ្រាំនឹងអំពើនេះពុំបានប្រជាជនយើងដែលដឹកនាំដោយអ្នកក្លាហានពីររូបគឺ **ផួន** និង **នៅ** បានដឹកនាំកម្លាំងប្រជាជនប្រឆាំងបារាំង ដោយបានសម្លាប់រ៉េស៊ីដង់ប្រចាំខេត្តកំពង់ឆ្នាំងម្នាក់ឈ្មោះ **បាដេស** និងសហការីពីររូបទៀតឱ្យស្លាប់នៅនឹងកន្លែង។ នេះសឱ្យឃើញថា នេះជាការរើបម្រះចេញពីរបបទឹកក្តៅដោយមិនស្តាយជីវិត។ ដោយឡែកនៅក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ លោក **សួន សុរិន្ទ** ជាអ្នកនិពន្ធបានបង្ហាញពីការដឹកនាំដ៏ឈ្លាសវៃរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ប្រកាន់ភាពអ្នកដឹកនាំជាទឹកត្រជាក់ផ្តល់

សេចក្តីសុខ និងការអភិវឌ្ឍលើគ្រប់វិស័យដល់ប្រជាជនគ្រប់ទិសទី។ តួអង្គ **សម** ដែលធ្លាប់ហែលការឈឺចាប់និរាសព្រាត់ប្រាសនៅក្នុងរបបអាណានិគមបារាំងបានក្លាយខ្លួនជាប្រធានក្រុមប្រឹក្សាឃុំសង្កាត់ ហើយក៏បានធ្វើខ្លួនជាទឹកត្រជាក់ចូលរួមនយោបាយអង្គសម្តេចឪ ដើម្បីរួមសាមគ្គីជាមួយនឹងប្រជាជនបានសេចក្តីសុខដរាបទៅ។

❖ សំយោគគំនិត : សរុបសេចក្តីមកការគ្រប់គ្រងជាទឹកត្រជាក់ពិតជានាំសេចក្តីសុខ សម្បូរសប្បាយដល់ប្រជាពលរដ្ឋជាត្រីរស់ក្នុងសង្គមពិតប្រាកដណាស់ ព្រោះរាល់រូបត្រីត្រូវការនិងរស់នៅបានតែក្នុងទឹកត្រជាក់ប៉ុណ្ណោះ ពោលគឺត្រូវការអ្នកដឹកនាំដែលចេះអាណិតស្រលាញ់ប្រជាជនដោយមិនរើសមុខ។

### គ- សេចក្តីបញ្ចប់

❖ វាយតម្លៃប្រធាន : សុភាសិតនេះមានអត្ថន័យនិងអត្ថរសល្អវិសេសវិសាលណាស់ ហើយត្រូវគ្រប់សម័យកាលទាំងអស់សម្រាប់សាមគ្គីភាពផងគ្នារវាងអ្នកដឹកនាំនិងអ្នកដែលត្រូវគេដឹកនាំ។ សុភាសិតនេះចាត់ទុកជាត្រីវិស័យសម្រាប់អនុវត្តក្នុងភាពជាអ្នកដឹកនាំ ដែលធានាបាននូវការរីកចម្រើន និងមានស្ថិរភាពនយោបាយក្នុងស្រុក។

❖ មតិផ្ទាល់ខ្លួន : ប្រជាជនដែលជាត្រីវិញក៏ត្រូវចេះត្រិះរិះពិចារណាជួយចូលរួមយ៉ាងសកម្ម ដើម្បីធ្វើយ៉ាងណាកុំឱ្យទឹកថ្លាដែលខ្លួនរស់នៅនោះប្រែជាល្អក់ខ្វល់ដោយសារតែខ្លួន។ ដើម្បីរីកចម្រើន ចាំបាច់មនុស្សដែលរស់នៅក្នុងសង្គមត្រូវចេះយោគយល់គ្នា មានទំនុកចិត្តគ្នាទៅវិញ

ទៅមកប្រៀបបានត្រី និងទឹកបំពេញកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមកដែរ។

📖 **ចំណាំ** : នៅពេលធ្វើកិច្ចការប្រលងអ្នកមិនត្រូវសរសេរចំណុចដែលមានអូសបន្ទាត់ពីក្រោមចូលសន្លឹកកិច្ចការទេ។ រាល់ចំណុចនីមួយៗនោះត្រូវជំនួសដោយការចុះដើមបន្ទាត់វិញ។ ចូរអានគំរូខាងក្រោមបន្តទៀត៖

**ប្រធាន** : *សុភាសិតខ្មែរមួយឃ្លាបានពោលឡើងថា "តម្លក់វាទៅ ទើបញ្ញៅវាមក"។ តើសុភាសិតនេះមានន័យយ៉ាងណា? ចូរពន្យល់។*

**សេចក្ដីអធិប្បាយ**

ការរស់នៅក្នុងសង្គម មនុស្សតែងមានទំនាក់ទំនងគ្នាទៅវិញទៅមកជាដរាប។ នៅក្នុងទំនាក់ទំនងនេះ ជាញឹកញយតែងជួបបញ្ហាទំនាស់ចោទប្រកាន់គ្នាទៅវិញទៅមក បង្កបានជាវិបត្តិក្នុងសង្គមមិនចេះចប់។ ដោយសង្កេតឃើញដូច្នេះហើយ ទើបបុរាណបានលើកសុភាសិតមួយឃ្លាថា " តម្លក់វាទៅទើបញ្ញៅវាមក"។

តើសុភាសិតនេះមានអត្ថន័យយ៉ាងណាដែរ?

ប្រធានមានពាក្យគន្លឹះដែលត្រូវពន្យល់។ ពាក្យថា "តម្លក់" គឺជាឧបករណ៍ម្យ៉ាងដ៏សាមញ្ញរបស់ប្រជាជនខ្មែរមានរាងវែង ធ្វើអំពីកូនឈើឬឫស្សី មានចងខ្សែនឹងកំណាត់កូនឈើរាងកូក់សម្រាប់យកទៅបេះផ្លែឈើដែលនៅខ្ពស់ឬវត្ថុអ្វីដែលនៅឆ្ងាយពីដៃ។ ដោយឡែកពាក្យថា "ញ្ញៅ" គឺឈ្មោះផ្លែរុក្ខជាតិម្យ៉ាងមានសំបករឹងក្រាស់ពេលណាដែល

វាទុំគេអាចយកមកបរិភោគបាន។

ប្រធានមានន័យថា បើគេមិនប្រើតម្លក់សម្រាប់បេះផ្លែត្នោតទេនោះ គឺគេមិនអាចបេះផ្លែឈើនេះធ្វើជាអាហារបានឡើយ។

ធម្មតាដើមត្នោត ជារុក្ខជាតិម្យ៉ាងដែលមានបន្លាច្រើនវែងៗហើយមុតនិងមិនងាយឱ្យឡើងទៅបេះផ្លែវាបានឡើយ តែបើដើមចាស់ក៏គង់នៅមានបន្លានៅតាមមែកដែរ។ ចំណែកមែករបស់វាផុយស្រួយណាស់ បើសិនហ៊ានឡើងស្ទួតែបន្តិច មុខជាបាក់ធ្លាក់បង្កគ្រោះថ្នាក់មិនខាន បើគេចង់បេះផ្លែវាគេត្រូវប្រើតម្លក់ទៅទាញឬកន្ត្រាក់ទើបវាជ្រុះមកដី។

សុភាសិតនេះ លោកបានបង្កប់ពាក្យទូន្មានប្រៀនប្រដៅប្រសើរណាស់សម្រាប់យកមកប្រតិបត្តិក្នុងការរស់នៅឱ្យបានថ្លៃថ្នូរ។ ក្នុងន័យនេះ “តម្លក់” ប្រៀបបានជាមធ្យោបាយផ្សេងៗសម្រាប់ប្រើក្នុងការដោះស្រាយបញ្ហាផ្សេងៗដែលកើតមានឡើងនៅចំពោះមុខ។ ចំណែក “ផ្លែត្នោត” គឺជាលទ្ធផលដែលសម្រេចបាន។ រស់នៅក្នុងសង្គមការប្រឈមនឹងបញ្ហានានាដែលកើតមានឡើងចំពោះមុខ មនុស្សត្រូវចេះរកវិធីសាស្ត្រ ឬមធ្យោបាយណាមួយមកអនុវត្ត ដើម្បីទទួលបានលទ្ធផលជាផ្លែផ្កា។ មធ្យោបាយនោះគឺជា “តម្លក់”។ ពេលណាគេចេះប្រើតម្លក់សម្រាប់បេះផ្លែត្នោតឬប្រើមធ្យោបាយសម្រាប់ដោះស្រាយបញ្ហានោះ គេមុខតែទទួលបានជ័យជម្នះពុំខាន។ មធ្យោបាយដែលគេប្រើសម្រាប់ដោះស្រាយបញ្ហាមានច្រើនយ៉ាងណាស់។ អ្នកខ្លះប្រើលុយជាមធ្យោបាយ ដូចជាចង់បានរថយន្តទំនើបមួយគ្រឿង គេត្រូវប្រើលុយទៅទិញ បើមិនដូច្នោះ

ទេអ្នកលក់គេមិនឱ្យរថយន្តនោះឡើយ។ បន្ថែមពីលើនេះទៅទៀត បើគេចង់រកស៊ីជារបរជំនួញជួញដូរអ្វីមួយ ក្នុងគោលបំណងឱ្យជីវភាពខ្លួនបានធូរធារនោះ គឺគេត្រូវប្រើជំនាញច្បាស់លាស់ដើម្បីប្រកបរបរនោះ ទើបគេអាចសម្រេចតាមផែនការរបស់គេបាន។ មធ្យោបាយខ្លះទៀតគេប្រើចំណេះវិជ្ជាក្នុងការដោះស្រាយបញ្ហាដូចជា សិស្សានុសិស្សដើម្បីបានសញ្ញាបត្រមួយសន្លឹក គេត្រូវឆ្លងកាត់ការប្រលងបញ្ចេញសមត្ថភាព និងការយកចិត្តទុកដាក់សិក្សាពីដើមឆ្នាំសិក្សារៀងមក ទើបគេអាចប្រលងជាប់សញ្ញាបត្រដូចក្ដីប្រាថ្នារបស់គេបាន។ នៅមានមធ្យោបាយខ្លះទៀតដែលគេចូលចិត្តប្រើចិត្តសាស្ត្រដើម្បីសម្រេចផ្លែផ្កាដែរ។ អ្នកខ្លះចូលចិត្តបន្ទាបខ្លួនដើម្បីឱ្យគេអាណិតស្រលាញ់ ឯខ្លះទៀតចូលចិត្តជួយទុក្ខធុរៈអ្នកដទៃក៏ព្រោះតែចង់បានសេចក្ដីសុខ។ ចាស់ៗដែលរក្សាសីលប្រាំ ចាំសីលប្រាំបីប្រឹងប្រែងគោរពពុទ្ធោវាទ ក៏ព្រោះប្រាថ្នាសេចក្ដីសុខទៅបរលោក។ ព្រះពុទ្ធទ្រង់បានទូន្មានពុទ្ធបរិស័ទថា “**សុខតោ សុខានំ**” មានន័យថាឱ្យសុខទៅគេ គឺគេឱ្យសុខមកយើង។ រដ្ឋាភិបាលយកចិត្តទុកដាក់លើការអភិវឌ្ឍជាតិនោះ ជាលទ្ធផលមួយដែលប្រជាជនលែងជួបគ្រោះទុរភិក្ស និងសង្គមជាតិទទួលបានការរីកចម្រើនបានល្អប្រសើរ។

នៅក្នុងរឿងកុលាបប៉ៃលិន លោក **ញ៉ុក ថែម** ជាអ្នកនិពន្ធបានបង្ហាញថា ចៅចិត្រជាមនុស្សដែលមានចរិតសុភាពរាបសា ស្មោះត្រង់នឹងចៅហ្វាយនាយគ្រប់ស្ថានភាព រស់នៅមានភាពហ្មត់ចត់ក្នុងការងារក៏

នាំឱ្យខ្លួនគេទទួលបានក្ដីស្រលាញ់រាប់អានពីកម្មករ ដែលធ្វើការជាមួយគ្នានិងចៅហ្វាយនាយផងដែរ។ ជាងនេះទៀតនោះរហូតដល់នាង **យុន នារី** ជាចៅហ្វាយក្រមុំខ្លួន ស្មគ្រព្រមប្រគល់សេចក្ដីស្នេហាថែមទៀតផង។ ដោយឡែកក្នុងរឿងធនញ្ជ័យ តួអង្គនេះបានប្រើប្រាជ្ញាដោះស្រាយបញ្ហានានាទទួលបានជោគជ័យជានិច្ច ដូចជាផ្ចាញ់ប្រាជ្ញាសេដ្ឋីនិងស្ដេចរហូតស្ដេចស្រុកចិន និងធ្វើឱ្យនគរមួយនេះលែងហ៊ានប៉ះពាល់ **ធនញ្ជ័យ** ទៀតផង។ ឯរឿងភូមិតិរច្ឆានអ្នកនិពន្ធបង្ហាញថា ដោយសារតែមានការជិះជាន់ពីបារាំងពេក ទើបកើតមានចលនាបះបោរប្រឆាំងជាច្រើនដងដូចជាអ្នកមុខកំពូលបានលើកគ្នាបីពាន់នាក់នាំញត្តិមកថ្វាយ **ហ្លួង ស៊ីសុវត្ថិ** ដោយឡែកកម្មករនៅអង្គរបានស្ទាក់សម្លាប់លោក **កូម៉យ** ហើយចលនាបះបោរសម្លាប់រ៉េស៊ីដង់ម្នាក់ឈ្មោះ **បាដេស** គឺកើតចេញពីអំពើព្រៃផ្សៃរបស់គាត់ដែរ។ ទាំងនេះសុទ្ធជាតម្លក់និងជាផ្លែញ្ញៀទាំងអស់។

សរុបសេចក្ដីមក ផលដែលទទួលបាន គឺមានហេតុនៅពីខាងក្រោយជានិច្ច។ ផលនេះហើយដែលគេចាត់ទុកថា ជាផ្លែញ្ញៀដែលត្រូវជ្រុះមកដល់ដៃអ្នកបេះដោយសារតម្លក់ជាហេតុ។ បើប្រើតម្លក់ទៅវាយទៅកន្ត្រាក់វាខ្លាំងពេក អាចនឹងជ្រុះមកបង្កការឈឺចាប់ដល់អ្នកបេះពុំខានឡើយ។

ឆ្លងតាមការបកស្រាយខាងលើឃើញថា ប្រធានមានតម្លៃយ៉ាងឧត្ដម និងមានអត្ថន័យស៊ីជម្រៅនៅគ្រប់សម័យកាលដើម្បីទុកជាប្រទីបអប់រំអនុជនជំនាន់ក្រោយឱ្យដើរលើផ្លូវត្រង់សម្រាប់ជីវិត

ឱ្យមានរស្មីដែលជាក្ដីសង្ឃឹមនៃមនុស្សគ្រប់រូបនិងគ្រប់សម័យកាល។

សុភាសិតនេះ ប្រៀបដូចជាឱសថទិព្វសម្រាប់លើកស្ទួយចិត្តគំនិតអ្នកសិក្សាឱ្យចេះម្ចាស់ការខ្លួនឯង កាន់ការអ្វីឱ្យប្រាកដទើបលទ្ធផលដែលបានមកល្អជាទីគាប់ចិត្ត។

## ២- ប្រធានពន្យល់បែបពាក្យស្លោកឬទស្សនៈទូទៅ

ប្រធាននេះ តម្រូវឱ្យមានការបកស្រាយដូចប្រធានសុភាសិតដែរ តែខុសត្រង់ថា ប្រធាននេះមិនមានបកស្រាយន័យធៀបអ្វីទេ។

គម្រោងសរសេរប្រធានពន្យល់បែបពាក្យស្លោកឬទស្សនៈទូទៅ

### ក- សេចក្ដីផ្ដើម

❖ លំនាំបញ្ហា : សរសេរបញ្ហាផ្សេងៗដែលជាប់ទាក់ទងជាមួយនឹងទស្សនៈរបស់ប្រធានតែមិនត្រូវឱ្យចំជាមួយនឹងប្រធានពេកទេ។

❖ ចំណូលបញ្ហា : ប្រើឃ្លាភ្ជាប់ប្រធាន រួចលើកទស្សនៈប្រធានមកដាក់ក្នុងសញ្ញា “...”។

❖ ចំណោទបញ្ហា : ចោទសួរតាមរបៀបប្រធានពន្យល់។

### ខ- តួសេចក្ដី

❖ ឃ្លាឆ្លាប់សេចក្ដី : “ប្រធានមានពាក្យគន្លឹះដែលត្រូវពន្យល់”។

❖ ពន្យល់ពាក្យ : ពន្យល់តែពាក្យគន្លឹះក្នុងប្រធាន។

❖ ពន្យល់ប្រធាន : ពន្យល់ទៅលើអត្ថន័យប្រធានជាចម្បងនិងពន្យល់ច្បោលៗ ដើម្បីបង្កើនការចង់អានបន្តនៅចំណុចបកស្រាយន័យ

ពិស្ដារនៅក្នុងប្រធាន។

❖ បកស្រាយប្រធាន : បកស្រាយតែន័យត្រង់ដោយមិនមានន័យធៀបទេ។

- ឧទាហរណ៍ : (ក្នុងប្រវត្តិសាស្ត្រ សង្គម អក្សរសិល្ប៍)។

❖ សំយោគគំនិត : ធ្វើសំយោគរួមទៅលើការបកស្រាយខាងលើតែមិនត្រូវវែងពេកនោះឡើយ។

**គ- សេចក្ដីបញ្ចប់**

❖ វាយតម្លៃប្រធាន : ឆ្លើយតបនឹងចំណោទបញ្ហាដែលបានចោទខាងលើនៅផ្នែកសេចក្ដីផ្ដើមចំណុចចំណោទបញ្ហា។

❖ មតិផ្ទាល់ខ្លួន : បញ្ចេញមតិផ្ទាល់ខ្លួនដោយប្រើសព្វនាមបុរិសៈបុរសទី១ពហុវចនៈ។

**ប្រធាន** : *គេថា "អក្សរសិល្ប៍និងសិល្បៈមានមុខងារយ៉ាងសំខាន់ក្នុងការផ្សាយចំណេះដឹង"។ ចូរបកស្រាយ។*

**សេចក្ដីអធិប្បាយ**

ការសិក្សាអក្សរសិល្ប៍ ក៏ដូចជាសិល្បៈត្រូវបានមជ្ឈដ្ឋានជុំវិញវាយតម្លៃថា មានប្រយោជន៍ណាស់ក្នុងការអប់រំចំណេះដឹងមនុស្សឱ្យរស់នៅក្នុងសង្គមបានថ្លៃថ្នូរសមជាពលរដ្ឋល្អ។ មនុស្សមានចំណេះដឹងខាងផ្នែកនេះ ក៏ជាកិត្តិយសមួយសម្រាប់ខ្លួនគេឱ្យទទួលបទពិសោធជីវិតមកអប់រំបញ្ញាស្មារតីបានត្រចះត្រចង់។ ហេតុដូច្នេះហើយទើប

មានទស្សនៈមួយបានលើកឡើងថា "អក្សរសិល្ប៍និងសិល្បៈមានមុខងារយ៉ាងសំខាន់នៅក្នុងផ្សាយចំណេះដឹង"។

តើទស្សនៈដែលបានលើកឡើងខាងលើនេះ មានអត្ថន័យយ៉ាងណាសម្រាប់អប់រំ?

ប្រធានដែលបានលើកឡើងខាងលើ មានពាក្យគន្លឹះដែលត្រូវពន្យល់។ ពាក្យថា "អក្សរសិល្ប៍" ពាក្យនេះមានន័យច្រើនយ៉ាងតែអាចយល់ខ្លីថា ជាកម្រងស្នាដៃរបស់អ្នកនិពន្ធដែលចងក្រងឡើងដោយមានសិល្បិ៍វិធីតែងនិពន្ធនិងតម្លៃអប់រំទៅក្នុងនោះ។ ចំណែកពាក្យថា "សិល្បៈ" មានន័យថា ចំណេះដឹងខាងជាង។ នៅទីនេះមានន័យថា ខាងរាំច្រៀង សម្តែងកាយវិការឱ្យទាក់ទាញចិត្ត។

ប្រធានខាងលើមានន័យថា ស្នាដៃតែងនិពន្ធដែលមានសិល្បិ៍វិធីអប់រំក៏ដូចជាវិជ្ជាខាងការរាំច្រៀងកាយវិការ គឺមាននាទីយ៉ាងសំខាន់នៅក្នុងការបង្រៀនមនុស្សក្នុងសង្គម ឱ្យទទួលបានមេរៀនជីវិតដ៏ល្អសម្រាប់ជាទិសដៅនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់គេ។

ដូចអ្វីដែលប្រធានបានអះអាងមែន កាលណាមនុស្សម្នាក់ក៏ដូចជាច្រើនគ្នាបានសិក្សាឬទស្សនាស្នាដៃអក្សរសិល្ប៍មួយ ទោះជាខ្សែភាពយន្តក្តីឬប្រលោមលោកក្តី គេតែងតែចង់យកគំរូតាមតួអង្គណាដែលពោរពេញទៅដោយសេចក្តីយុត្តិធម៌ ចេះការពារយុត្តិធម៌ឬជាមនុស្សដ៏អស្ចារ្យជានិច្ច។ បន្ទាប់ពីនោះមកគេក៏តាំងធ្វើខ្លួនជាតួនោះទាំងការប្រើពាក្យពេចន៍ឃ្លោងឃ្លាក៏មិនចាកពីចរិតតួឯកនោះដែរ។ ឯសិល្បៈក៏ដូច្នេះដែរ នៅគ្រាដែលគេបានទស្សនាឬឃើញការសម្តែងណាមួយដែលជាទីចាប់ចិត្តរបស់គេក៏តាំងចិត្តថា នឹងរៀនហាត់តាមធ្វើកាយវិការតាមឱ្យ

ដូចជាអ្នកសម្តែងដើម។ របៀបរាំក្តី ការធ្វើដំណើរក្តី មនុស្សដែលបានទទួលការបង្ហាញពីតួដើមហើយ ក៏ចង់ឱ្យការសម្តែងរបស់ខ្លួនដូចជាម្ចាស់ដើមជានិច្ច។

នៅក្នុងរឿងរាមកេរ្តិ៍បន្ទាប់ពីការសិក្សាចប់ ឬអ្នកខ្លះបានទស្សនាភាពយន្តចប់ គេក៏ស្រមៃថា ខ្លួនគេជាព្រះរាមព្រោះតែព្រះរាមជាតួអង្គអស្ចារ្យ ចេះសិល្ប៍ហោះហើរចេះមន្តវិជ្ជាសិល្ប៍ដែលនាំឱ្យគេទទួលអារម្មណ៍ថា អស្ចារ្យណាស់ អណ្តែតអណ្តូងព្រោះតែសិល្ប៍អាគមរបស់ព្រះរាម។ ចំណែកនាងសីតាដែលល្បីសុសសាយថា ជាស្ត្រីដែលល្អជាងគេ ទោះជាទេវតាក៏មានសម្រស់មិនស្មើនាងនោះ ក៏ជាអារម្មណ៍មួយនាំនារីទាំងឡាយចង់បានសម្រស់ស្អាតល្អ ដូចជារូបនាងដែរ។ ពេលនោះគេខំស្និតស្នាងរាងកាយឱ្យដូចនាងសីតា ទាំងស្នាមញញឹម ឬសម្តីកាយវិការទឹកមុខជាដើម។ មានពេលខ្លះទៀតមនុស្សបានទស្សនាភាពយន្តដទៃដែលល្បីថា ល្អមើល តួឯកក៏ស្អាតៗ សម្តីនោះក៏ពីរោះក៏នាំឱ្យគេស្រមៃថា ខ្លួនជាតួឯកក្នុងរឿងនោះដែររហូតមានពេលខ្លះទៀតគេខំធ្វើតម្រាប់តាមតួអង្គទាំងមិនដឹងខ្លួនក៏មានដែរ។ ចំណែកសិល្បៈវិញ នៅទីនេះគឺសំដៅតែទៅលើការរាំច្រៀងប៉ុណ្ណោះ។ អ្នកទាំងឡាយ ដែលបានទស្សនាការសម្តែងរាំច្រៀងនៅលើមហោស្រព ឬកញ្ចក់ទូរទស្សន៍ក៏តាំងហាត់រាំតាម ដោយបញ្ចេញក្បាច់រាំបង្កើនការទាក់ចិត្តឱ្យដូចជាអ្វីដែលគេបានឃើញដែរ។

ដូច្នេះ អក្សរសិល្ប៍ក្តី សិល្បៈក្តីសុទ្ធតែមានតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយចំណេះដឹងឱ្យបានជ្រួតជ្រាប ដល់បណ្តាសាធារណជនយ៉ាងឆាប់រហ័ស និងងាយស្រួលក្នុងការទទួលយកចំណេះដឹងទាំងនេះ

ទៅអនុវត្តក្នុងជីវភាពរស់នៅរបស់គេម្នាក់ៗ។ ប្រសិនណាអក្សរសិល្ប៍ ឬសិល្បៈបង្ហាញតែពីភាពឆើតឆាយឬកាប់ចាក់ដោយអយុត្តិធម៌ នេះក៏ជាបញ្ហាដែលជះឥទ្ធិពលអាក្រក់ដល់សង្គមរស់នៅដែរ ព្រោះអ្នកទស្សនាត្រូវតោងចាប់អ្វីដែលគេបានឃើញ ហើយគ្មានវិធានការច្បាស់លាស់នៅក្នុងការទប់ស្កាត់។

ឆ្លងតាមការបកស្រាយខាងលើសបញ្ជាក់ថា អក្សរសិល្ប៍ និងសិល្បៈ គឺជាអាវុធមុខពីរយ៉ាងសក្តិសិទ្ធិនៅក្នុងសង្គម។ ប្រសិនណាការផ្សព្វផ្សាយអក្សរសិល្ប៍មានទិសដៅល្អក្នុងការអប់រំ នៅពេលនោះ មនុស្សក្នុងសង្គមជាតិនឹងទទួលបានការអភិវឌ្ឍយ៉ាងសម្បូរបែបខាងសីលធម៌និងគុណធម៌។ ផ្ទុយទៅវិញប្រសិនណាជាអក្សរសិល្ប៍បង្ហាញតែភាពកោងកាច សាហាវព្រៃផ្សៃ សង្គមជាតិ ក៏មុខតែទទួលវិបត្តិដោយសារតែបញ្ហានេះជាក់ជាពុំខាន។

ដូច្នេះមនុស្សទាំងអស់រស់នៅក្នុងសង្គមជាតិខ្មែរត្រូវចេះពិចារណាឱ្យបានវែងឆ្ងាយ មុននឹងទទួលគំនិតណាមួយមកអប់រំជីវិត ប្រសិនណាការទទួលយកនោះចម្រើនសេចក្តីថ្លៃថ្នូររបស់ខ្លួនសឹមទទួលយក វៀរចាកការសោកស្តាយទៅថ្ងៃក្រោយព្រោះតែវិបត្តិនៃការផ្សព្វផ្សាយអក្សរសិល្ប៍និងសិល្បៈនេះ។

## ៣- ប្រធានពន្យល់ប្រៀបធៀប

ប្រធានបែបនេះ គឺតម្រូវការបកស្រាយលើ២មតិដើម្បីស្វែងរកចំណុចវិជ្ជមាននិងចំណុចអវិជ្ជមាន។ ការបកស្រាយប្រធានប្រភេទនេះ គឺគេបកស្រាយម្តងមួយមតិៗ ហើយនៅរាល់ការបកស្រាយត្រូវមានឧទាហរណ៍ឱ្យបានច្បាស់លាស់។

ជាទូទៅប្រធានប្រភេទនេះ គេមិនដែលជួបប្រទះការចោទនៅក្នុងសុភាសិតទេ ច្រើនតែជាប្រធានដែលចោទចេញពីអក្សរសិល្ប៍ដោយរើសយកតួអង្គណាមួយក្នុងរឿង ទៅប្រៀបធៀបនឹងតួអង្គក្នុងរឿងមួយទៀត ឬអាចចោទពីការរស់នៅក្នុងសង្គមណាមួយធៀបទៅនឹងសង្គមមួយទៀត។

គម្រោងសរសេរប្រធានពន្យល់ប្រៀបធៀប

**ក- សេចក្តីផ្តើម**

❖ លំនាំបញ្ហា

❖ ចំណូលបញ្ហា

❖ ចំណោទបញ្ហា

**ខ- តួសេចក្តី**

❖ ឃ្លាភ្ជាប់សេចក្តី

❖ ពន្យល់ពាក្យ

❖ ពន្យល់ប្រធាន

❖ បកស្រាយប្រធាន

❖ បកស្រាយមតិប្រធានទី១ដោយលម្អិត មានឧទាហរណ៍និងធ្វើសំយោគតូចមួយ។ ការធ្វើសំយោគតូចនេះមិនចាំបាច់ចុះដើមបន្ទាត់ទេ។

❖ បកស្រាយមតិប្រធានទី២ដោយលម្អិត មានឧទាហរណ៍និងធ្វើសំយោគតូចមួយ។ ការធ្វើសំយោគតូចនេះមិនមានចុះដើមបន្ទាត់ទេ។

❖ សំយោគគំនិត : យកលក្ខណៈរួមនៃមតិទាំង២មកបូកបញ្ចូលគ្នានិងធ្វើសេចក្តីគាំទ្រមួយដែរ។

**គ- សេចក្តីបញ្ចប់**

❖ វាយតម្លៃប្រធាន

❖ មតិផ្ទាល់ខ្លួន។

**ប្រធាន** : *ទស្សនៈអ្នកសិក្សាអក្សរសិល្ប៍បានលើកឡើងថា "តួអង្គ* ***នៅ ផួន*** *នៅក្នុងរឿងភូមិតិរច្ឆាននិងតួអង្គ* ***លឹម មុីង*** *នៅក្នុងរឿងគូលីកំនែនសុទ្ធតែជាតួអង្គដែលមានគំនិតស្នេហាជាតិពិតប្រាកដ"។ ចូរធ្វើការបង្ហាញ។*

**សេចក្តីអធិប្បាយ**

ការសិក្សាអក្សរសិល្ប៍ មានអត្ថប្រយោជន៍ច្រើនណាស់សម្រាប់អប់រំមនុស្សឱ្យមើលឃើញពីសង្គមនីមួយៗ និងយកគំរូតាមវីរភាពនៃតួអង្គណាមួយ ដែលបានលះបង់ប្រយោជន៍ផ្ទាល់ខ្លួនដើម្បីការពារបុព្វហេតុអ្វីមួយច្បាស់លាស់ ហើយបានបម្រើដល់សេចក្តីត្រូវការរបស់មនុស្សផងទាំងឡាយ។ យ៉ាងណាមិញគេបានអះអាងថា "តួអង្គ **នៅ ផួន** ក្នុងរឿងភូមិតិរច្ឆាននិងតួអង្គ **លឹម មុីង** នៅក្នុងរឿងគូលីកំនែន សុទ្ធតែជាតួអង្គដែលមានគំនិតស្នេហាជាតិពិតប្រាកដ"។

តើតួអង្គទាំងពីររឿងនេះបានលះបង់អ្វីខ្លះដើម្បីប្រយោជន៍ជាតិ?

ប្រធានមានពាក្យគន្លឹះដែលត្រូវពន្យល់។ ពាក្យថា

“ស្នេហាជាតិ” គឺមានសេចក្ដីថា ស្រលាញ់ជាតិ ស្រលាញ់ទឹកដីហើយ ហ៊ានធ្វើអ្វីៗដើម្បីការពារផលប្រយោជន៍ជាតិ។

តាមន័យនេះ គឺប្រធានចង់បង្ហាញប្រាប់ថា រឿងទាំងពីរស្ថិតក្នុងចលនារំដោះទាមទារអ្វីមួយដែលបង្កឡើងដោយការគ្រប់គ្រង។ នៅក្នុងពេលនោះតួអង្គគំរូនៃសាច់រឿង ត្រូវបានអ្នកនិពន្ធលើកមកបង្ហាញក្នុងការធ្វើសកម្មភាពប្រឆាំងតបតទៅវិញ ហើយការប្រឆាំងនេះតួអង្គមានគុណធម៌ ស្រលាញ់ជាតិ ទឹកដី សេរីភាពពិតប្រាកដ។

តាមរយៈការលើកឡើងខាងលើឃើញថា រឿងភូមិតិរច្ឆានដែលជាស្នាដៃនិពន្ធរបស់លោក **ឡៀក អំ** និងលោក **ឌឹក តាម** ហើយការសរសេរទៀតសោត ជាប្រលោមលោកលំនាំប្រវត្តិសាស្ត្រលាតត្រដាងពីសម័យកាលមួយ ដែលប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់បារាំង។ កាលពីបារាំងជាម្ចាស់អាណានិគមនោះបានកេណ្ឌប្រជារាស្ត្រខ្មែរឱ្យទៅជួយធ្វើចម្បាំងនឹងអាល្លឺម៉ង់ ហើយស្លាប់ជួសពួកវា។ បារាំងពុំបានគិតពីគុណបំណាច់ដែលខ្មែរខំទៅជួយច្បាំងវាឡើយ ផ្ទុយទៅវិញពួកនេះបែរជាប្រឹងដំឡើងពន្ធសព្វសរពើដើម្បីសង្កត់ករាស្ត្រខ្មែរ យកប្រាក់ទៅជួសជុលប៉ះប៉ូវសេដ្ឋកិច្ចប្រទេសវាដែលទទួលរងការខូចខាតដោយសារសង្គ្រាមទៅវិញ។ ស្ថិតក្នុងជីវភាពដ៏លំបាកហួសពីការពណ៌នានោះ រាស្ត្រដែលអត់លុយសម្រាប់បង់ពន្ធត្រូវពួកវាចាប់យកទៅដាក់គុកឬពិន័យជាពីរជាបី តាមតែការគិតរបស់វា។ លើសពីនេះទៅទៀតនៅឆ្នាំមួយពាន់ប្រាំបួនរយម្ភៃប្រាំ

លោកវ៉េស៊ីដង់ប្រចាំខេត្តកំពង់ឆ្នាំងឈ្មោះ **បារាំង** មិនត្រឹមតែជំរិតទារពន្ធពីប្រជាជននៅខេត្តនេះទេ ថែមទាំងចុះដើរទារពន្ធដោយខ្លួនឯងទៀតផង។ តាមការរៀបរាប់របស់អ្នកនិពន្ធបង្ហាញថា ទីណាដែលលោកទៅដល់ ទីនោះនឹងមានអ្នកជាប់ខ្នោះដោយសារតែគ្មានប្រាក់បង់ពន្ធជូនលោក ថែមទាំងត្រូវលោកធំរូបនេះលោតទៅធាក់ ទៅទាត់ទាំងប្រជាជនជាប់ខ្នោះទៀតផង។ ដោយអត់ទ្រាំនឹងអំពើនេះមិនបានទើបមានឈ្មោះ **នៅ** និងឈ្មោះ **ផួន** ជាអ្នកភូមិព្រៃខ្មែរបានផ្ដើមគំនិតក្នុងការសម្លាប់លោកធំបារាំងរូបនេះឱ្យខានតែបាន ដើម្បីរំសាយកំហឹងជូនប្រជាពលរដ្ឋនិងជាតិខ្មែរ។

អ្នកទាំងពីរ ស៊ូលះបង់ប្រយោជន៍ផ្ទាល់ខ្លួនដើម្បីជាតិ ពោលគឺបានទុកសេចក្ដីសុខក្នុងគ្រួសារ ហើយងាកមកតទល់នឹងអាណានិគមដោយអត់មានញញើត។ គាត់បានដឹងច្បាស់ជាមុនពីលទ្ធផលដែលទទួលបន្ទាប់ពីសម្លាប់បារាំង តែក្នុងនាមជាមនុស្សដែលមានឈាមជ័រជាខ្មែរម្នាក់ គាត់ត្រូវតែប្ដូរជីវិតដោយឥតស្ដាយស្រណោះ។ គាត់បាននិយាយនៅមុនពេលសម្លាប់បារាំងថា "ពួកម៉ាកឯងនិយាយបែបនេះល្អម្យ៉ាងដែរ។ ចិត្តឯងដូចចិត្តអញតែសុំពួកម៉ាកកុំភ្លេចថា ភ្នែកបារាំងច្រើនដូចភ្នែកម្នាស់ បើយើងសម្លាប់វារួចក៏គង់តែយើងគេចរត់ទៅណាមិនផុតដែរ ទីបំផុតគេសម្លាប់យើងវិញដដែល"។ ទោះបីជាការពិចារណាឃើញបែបនេះក្ដី ក៏នៅតែមានចិត្តប្រាថ្នាចង់សម្រេចកិច្ចការអ្វីមួយជូនជាតិតាមលទ្ធភាពដែលគាត់អាចធ្វើបាន ដូចសម្ដីជួនបាន

និយាយថា "បើយើងមិនអាចធ្វើការណាមួយដែលហួសពីនិស្ស័យយើងបានទេក៏គង់មានការឯទៀតយើងធ្វើកើតដែរមែនទេ"។ គាត់និយាយបែបនេះ គឺគាត់មិនចង់ក្លាយជាអ្នកដឹកនាំប្រទេសទេតែគាត់ចង់សម្រេចកិច្ចការអ្វីមួយជូនជាតិ បំណាច់តែគាត់បានកើតមកជាកូនខ្មែរហើយនោះ។ ការសម្រេចចិត្ត ថានឹងសម្លាប់បារាំងឈ្មោះ **បាដេស** ឱ្យបាននោះបានបណ្ដាលឱ្យគាត់ខំដើរប្រមូលគូកនដើម្បីសម្រេចផែនការ។ ខណៈដែលបានគ្រប់ចំនួនទើបការប្រតិបត្តិការនេះចាប់ផ្ដើមឡើង និងបានសម្លាប់ឈ្មោះ **បាដេស** នេះនៅវត្តក្រាំងលាវ រួមជាមួយនឹងបក្សពួកជាចៅបម្រើដាច់ថ្លៃរបស់វាមួយចំនួនទៀត។ ខណៈដែលសម្រេចផែនការនេះរួចមកឈ្មោះ **នៅ** និង **ជួន** ក៏មានបំណងទៅសម្លាប់បារាំងនៅកំពង់ឆ្នាំងទៀតដើម្បីព្រមានបារាំង ឱ្យឃើញពីចលនាបះបោរប្រឆាំងតបចំពោះអំពើជិះជាន់ផ្ដាច់ការរបស់វា។ វីរជនទាំងពីរនាក់នេះមិនបានឈរឱបដៃមើលសេចក្ដីលំបាកវេទនា ដែលបណ្ដាលមកពីការជិះជាន់នេះបានឡើយ។ ទោះបីជារូបគាត់មិនមែនជានិស្សិត បញ្ញវន្តក៏ពិតមែន តែឧត្ដមគតិគាត់ជាកូនខ្មែរមិនចេះខ្វះនិងមានតម្លៃលើសអ្វីៗទាំងអស់ និងបានក្លាយខ្លួនជាអ្នកក្លាហាននៅក្នុងសន្ដានចិត្តកូនខ្មែរគ្រប់ជំនាន់។ ទោះបីជាអ្នកទាំងពីរត្រូវរាជការបារាំងចាប់ធ្វើទោសយ៉ាងណាក្ដី ក៏សកម្មភាពប្រកបដោយសុភវិនិច្ឆ័យនេះ នាំឱ្យរាជការបារាំងភ្ញាក់រឭក បើកភ្នែកសម្លឹងមើលពីទុក្ខលំបាករបស់ប្រជាជនខ្មែរ និងពិចារណាបន្ធូរបន្ថយពន្ធឱ្យប្រជារាស្ត្រខ្មែរខ្លះដែរ។ រួមសេចក្ដីមកសកម្មភាពរបស់អ្នកទាំងពីរ

ពិតជាឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងពិតប្រាកដថា អ្នកទាំងពីរជាតួអង្គស្នេហាជាតិយ៉ាងពិតប្រាកដ ដែលចេះមានគំនិតរើបម្រះទោះស្ថិតក្នុងស្ថានភាពមួយ ដែលអ្នកស្រុកកំពុងតែបាក់ស្បាតខ្លាចអំណាចអ្នកដឹកនាំដែលជាម្ចាស់អាណានិគមមិនមានគំនិតរើបម្រះនោះ។

ដោយឡែកតួអង្គ **លឹម** និង **ម៉ឹង** នៅក្នុងរឿងគូលីកំណែនវិញក៏ត្រូវបានជាប់ឈ្មោះ ជាតួអង្គដែលមានទឹកចិត្តស្នេហាជាតិដ៏មោះមុតដែរពោល គឺអ្នកទាំងពីរពុំព្រមឈរឱបដៃមើលបរទេសកំពុងប៉ុនប៉ងយកប្រទេសជាតិខ្លួនជាចំណុះវាឡើយ។ អ្នកទាំងពីរបានលះបង់សេចក្តីសុខផ្ទាល់ខ្លួនដើម្បីចូលខ្លួនក្នុងចលនារំដោះជាតិ។ ដោយឡែកតួអង្គ **លឹម** អ្នកនិពន្ធបង្ហាញថា គេមានសេចក្តីឈឺចាប់ឥតឧបមាចំពោះសង្គ្រាមចក្រពត្តិដែលកើតឡើងនៅលើទឹកដីខ្មែរ ហើយសង្គ្រាមនេះបានសម្លាប់ឪពុកម្តាយគេ ពិសេសគឺគូដណ្តឹងនាង **ហេង** ដែលជាគូជីវិតនឹងត្រូវរៀបការជាមួយគ្នានៅកំលុងមួយខែទៀតប៉ុណ្ណោះ។ **លឹម** ក៏មានសេចក្តីឈឺចាប់ផងដែរចំពោះពូ **ចាន់** ដែលអាងតែអំណាចដើរពង្រាត់ប្រពន្ធកូនគេដោយអត់អៀនខ្មាស។ គំនុំគ្រួសារ ស្នេហា និងគំនុំជាតិដែលត្រូវគេជិះជាន់ បានប្រមូលផ្តុំដូចជាកម្តៅភ្នំភ្លើងដែលជំរុញឱ្យរូបគេត្រូវតែលាចាកពីស្រុកកំណើតទៅចូលរួមក្នុងចលនាជាតិ វាយផ្តួលខ្មាំងសត្រូវឱ្យបាន ដើម្បីស្វែងរកសេចក្តីសុខសន្តិភាពជូនជាតិមាតុភូមិជាទីស្នេហារបស់ខ្លួនវិញ ពិសេសគឺត្រូវតែសងសឹកជាមួយនឹងចក្រពត្តិដើម្បីរកយុត្តិធម៌ជូនឪពុកម្តាយនិងគូដណ្តឹងរបស់គេ។ គេបានសច្ចាថា

ដរាបណាគេវាយសត្រូវមិនទាន់អស់ពីទឹកដីទេ គេមិនអាចវិលចូលស្រុកបានឡើយ។

ដោយឡែក **ម៉ឹង** ក៏ដូច្នោះដែរ គឺជាជនរងគ្រោះក្នុងអំពើជិះជាន់ពីសំណាក់បរទេសដែរ ពោលគឺរូបគេមានថៅហ្វាយជាបរទេសដែលតែងរិះគន់និងមើលងាយរូបគេក៏ដូចជាមើលងាយខ្មែរ។ គេមានសេចក្តីឈឺចាប់ណាស់ ពេលដែលឃើញជាតិរបស់គេត្រូវពួកបច្ចាមិត្រទន្ទ្រានគ្រប់ទិសទី និងមើលឃើញពីការរស់នៅដ៏សែនលំបាករបស់ប្រជាជនខ្មែរ។ នៅទីបំផុតគេបានលាបុណ្យសក្តិលាតំណែងជាមន្ត្រីលាសង្សារ អ្នកគ្រូ **គូ រស់** ជាទីស្រលាញ់ លាទាំងឪពុកម្តាយទៅចូលរួមនឹងចលនាខ្មែរឥស្សរៈ ដើម្បីវាយដណ្តើមសន្តិភាពជូនជាតិខ្លួនវិញ។ សេចក្តីតាំងចិត្តរបស់ **ម៉ឹង** ក៏មិនខុសពីលឹមដែរ។ គេទុកសេចក្តីស្លាប់ឱ្យនៅដោយឡែក ហើយតម្កល់ប្រយោជន៍ឱ្យនៅខាងមុខរួច ប្រឆាំងជាមួយនឹងបច្ចាមិត្តដោយឥតញញើតខ្លាចស្លាប់។ ទីបំផុត **ម៉ឹង** ត្រូវពិការដៃម្ខាង តែគេមិនតក់ស្លុតទេ ហើយក៏មិនស្តាយស្រណោះដែរ ផ្ទុយទៅវិញគេបែរជាញញឹម ដោយបានឃើញប្រទេសជាតិរួចផុតពីកណ្តាប់ដៃបរទេស។ ទោះជាយ៉ាងនេះក្តី **ម៉ឹង** នៅមានគោលជំហរមួយទៀត គឺគេបានមើលឃើញពីនឹមអាណានិគមថ្មីដែលប៉ុនប៉ងយកកម្ពុជាធ្វើអាណានិគម ទើបឱ្យគេសម្រេចចិត្តរស់នៅក្នុងព្រៃដើម្បីបន្តយុទ្ធនាការប្រឆាំងតបនឹងបក្សពួកល្មោភសង្គ្រាមនេះ។ ទាំងនេះសឱ្យឃើញថាទាំង **លឹម** ទាំង **ម៉ឹង** គឺសុទ្ធតែមានស្មារតីស្នេហាជាតិយ៉ាងពិតប្រាកដ

ហើយពួកគេម្នាក់ៗ សុទ្ធតែតម្កល់ប្រយោជន៍ជាតិជាធំជាងប្រយោជន៍ខ្លួនឯងទាំងអស់ ជាអ្នកដែលស្រលាញ់ សន្តិភាព សេរីភាពជូនប្រជាជន។

សរុបសេចក្តីមកទាំងតួអង្គ **នៅ** និង **ជួន** នៅក្នុងរឿងភូមិតិរច្ឆានទាំងតួអង្គ **លឹម** និង **ម៉ិង** ក្នុងរឿងគូលីកំដែន គឺសុទ្ធជាតួអង្គដែលមានស្មារតីស្នេហាជាតិយ៉ាងពិតប្រាកដ។ អ្នកទាំងអស់គ្នានេះសុទ្ធតែតម្កល់ប្រយោជន៍ជាតិធំជាងប្រយោជន៍គ្រួសារ និយាយរួមគេទុកសេចក្តីសុខផ្ទាល់ខ្លួននៅពីក្រោយខ្នង ហើយរកសេចក្តីសុខ សេរីភាពជូនជាតិជាធំជាជាងឈរឱបដៃឱ្យពួកបច្ចាមិត្រយកប្រទេសខ្លួន ជាឈ្នាន់បម្រើនយោបាយខ្មៅងងឹតរបស់ពួកវា។

ដូចការបកស្រាយខាងលើឃើញថា អ្នកនិពន្ធដែលបានសរសេររឿងទាំងពីរគឺសុទ្ធតែមានគោលជំហរដូចគ្នា ពោលគឺបង្ហាញនូវគំរូវីរភាពរបស់តួអង្គក្នុងរឿងខ្លួន ដែលបានលះបង់ប្រយោជន៍ផ្ទាល់ខ្លួនដើម្បីបុព្វហេតុជាតិជាចម្បងដោយពុំស្តាយស្រណោះពីអាយុជីវិតខ្លួនឡើយ។

បុព្វបុរសខ្មែរជំនាន់មុន លោកសុទ្ធតែពលីជីវិតដើម្បីការពារទឹកដី រក្សាបូរណភាពជាតិដ៏បវរទុកឱ្យកូនចៅជំនាន់ក្រោយរស់នៅក្នុងភាពថ្លៃថ្នូរ។ ដូច្នេះក្នុងនាមជាកូនខ្មែរគ្រប់រូបត្រូវបន្តថែរក្សាទឹកដីដ៏ឧត្តមនេះឱ្យបានគង់វង្ស និងត្រូវចេះប្រឆាំងរាល់ការឈ្លានពានពីសំណាក់សត្រូវជិតឆ្ងាយតាមគ្រប់រូបភាព។

## ៤- ប្រធានពន្យល់លក្ខណៈចោទជាសំណួរឬពន្យល់ក្នុងក្របខណ្ឌអក្សរសិល្ប៍

ប្រធានពន្យល់លក្ខណៈចោទជាសំណួរ ស្ថិតក្នុងប្រធានពន្យល់សុទ្ធដែរ តែគ្រាន់តែគេចោទជាសំណួរ រួចឱ្យយើងធ្វើការសន្និដ្ឋានរកចម្លើយត្រឹមត្រូវដោយមានភ្ជាប់ឧទាហរណ៍ច្បាស់លាស់មកបង្ហាញផង។

ការធ្វើអធិប្បាយប្រធានប្រភេទនេះ មិនសូវមានលក្ខណៈសាំញ៉ាំដូចជាប្រភេទប្រធានពន្យល់ទាំង៣ខាងលើទេ។ ប្រធានបែបនេះជាប្រធានបែបធ្វើការសន្និដ្ឋាន ដូច្នេះអ្នកសរសេរចាំបាច់ត្រូវចេះវាយតម្លៃគំនិតអ្នកនិពន្ធនិងក្តាប់ឱ្យបានទាំងអត្ថន័យនិងអត្ថរូបរឿង។ គន្លឹះសំខាន់បំផុតនៃការសរសេរឬបកស្រាយប្រធានប្រភេទនេះ៖

- ត្រូវស្គាល់មូលន័យរបស់រឿងទាំងមូល។
- ត្រូវស្គាល់បញ្ហាសំខាន់ៗទាំងអស់របស់រឿង។
- ត្រូវស្គាល់គំនិតដឹកនាំរបស់អ្នកនិពន្ធ។

### គម្រោងសរសេរប្រធានពន្យល់លក្ខណៈចោទជាសំណួរ

**ក- សេចក្តីផ្តើម** : ធ្វើឃ្លាភ្ជាប់សេចក្តីឱ្យជាប់ទាក់ទងនឹងសំណួររួចចោទសួរដូចប្រធានពន្យល់សុទ្ធដែរ។ ការធ្វើឃ្លាភ្ជាប់នេះមិនគួរឱ្យវែងពេកទេ ចៀសវាងការសរសេរច្រំដែលនៅចំណុចតួសេចក្តី។

**ខ- តួសេចក្តី** : ធ្វើការវិភាគលម្អិតទៅលើសំណួរជាលក្ខណៈរបាយការណ៍ឱ្យបានច្បាស់និងមានភ្ជាប់នឹងឧទាហរណ៍ផង។ នៅផ្នែកនេះគប្បីត្រូវចេះចាប់យកចំណុចសំខាន់ៗបន្ថែម ដើម្បីធ្វើយ៉ាងណាឱ្យ

ការបកស្រាយឈរលើគំនិតច្បាស់លាស់។ គេអាចនិយាយថា ជាការបកស្រាយដែលមានសណ្ឋានជាអត្ថបទព័ត៌មានខ្លីមួយ។ អ្នកបង្ហាញពីអ្វី អ្នកត្រូវមានអំណះអំណាងច្បាស់លាស់ទើបការអធិប្បាយយើងច្បាស់លាស់មានលក្ខណៈជាវិទ្យាសាស្ត្រ។ ក្នុងការសរសេរចប់មួយគំនិតត្រូវចុះបន្ទាត់ផ្ដើមគំនិតថ្មីទៀត។ គេមិនកំណត់ចំនួនកថាខណ្ឌទេ អាស្រ័យទៅលើគំនិតអ្នកសរសេរ ហើយជួនកាលប្រធានគេកំណត់ឱ្យសរសេរចំនួន៧ឬ៨កថាខណ្ឌក៏ត្រូវសរសេរកំណត់ចំនួនប៉ុណ្ណោះដែរ។

**គ- សេចក្ដីបញ្ចប់** : ជាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនមានលំនាំប្រហាក់ប្រហែលនឹងប្រធានពណ៌នាដែរ។

**ប្រធាន** : *តាមយោបល់អ្នក តើអ្នកនិពន្ធរឿងធនញ្ជ័យមានគំនិតយ៉ាងណាបានជាឱ្យធនញ្ជ័យជាតួអង្គឯកស្លាប់?*

## សេចក្ដីអធិប្បាយ

ក្នុងរឿងខ្មែរពីបុរាណ អ្នកនិពន្ធមិនសូវធ្វើឱ្យតួអង្គឯកជាតួអង្គតំណាងគុណធម៌ យុត្តិធម៌ស្លាប់នោះទេ ព្រោះគេតែងចាត់ទុកថាឱ្យតួអង្គឯកស្លាប់ គឺការដាក់ទណ្ឌកម្មទៅលើតួអង្គនោះ។ ម្យ៉ាងធ្វើឱ្យការតស៊ូក្នុងចលនាទាមទារយុត្តិធម៌នោះបរាជ័យ ហើយមនុស្សរស់ក្នុងភាពអស់សង្ឃឹម។ ផ្ទុយទៅវិញនៅក្នុងរឿងធនញ្ជ័យពេលដែលបញ្ចប់រឿង អ្នកនិពន្ធបែរជាឱ្យតួអង្គឯកខ្លួន គឺ **ធនញ្ជ័យ** ស្លាប់ទៅវិញ។

តើការឱ្យ **ធនញ្ជ័យ** ស្លាប់ជាការដាក់ទណ្ឌកម្មដែរឬទេ? តើអ្នក

និពន្ធមានគំនិតយ៉ាងណាបានជាឱ្យតួអង្គឯកស្លាប់យ៉ាងនេះ?

ដើម្បីឆ្លើយតបចំពោះចម្ងល់ខាងលើ គេត្រូវពិនិត្យឱ្យបានល្អិតល្អន់ពីការបង្ហាញរបស់អ្នកនិពន្ធ ជុំវិញការស្លាប់របស់តួអង្គ **ធនញ្ជ័យ** ជាមុនសិន។ រឿងនេះមានចំណងជើងថា "**ធនញ្ជ័យ**" ទិសដៅនៃការសរសេរត្រូវមានជាប់ទាក់ទងយ៉ាងជិតស្និទ្ធនឹងតួអង្គនេះ។ នៅក្នុងសាច់រឿង អ្នកនិពន្ធបានធ្វើឱ្យតួអង្គខ្លួនតែងមានទំនាស់ជាមួយនឹងវណ្ណៈខ្ពស់ជាងខ្លួនជានិច្ច ប៉ុន្តែរាល់ទំនាស់ដែលកើតឡើងហើយត្រូវបាន **ធនញ្ជ័យ** យកជ័យជម្នះជានិច្ច។ គ្រប់ទំនាស់ទាំងសេដ្ឋី មន្ត្រីសុទ្ធ តែខឹង **ធនញ្ជ័យ** យ៉ាងខ្លាំង តែនៅមិនអាចធ្វើអ្វី **ធនញ្ជ័យ** បានឡើយ។

ស្តេចនគរខ្មែរកាលនោះបានចេញបញ្ជាគេឱ្យសម្លាប់ **ធនញ្ជ័យ** ប៉ុន្មានដងហើយក៏ **ធនញ្ជ័យ** នៅតែមិនស្លាប់។ ទីបំផុតអ្នកនិពន្ធបានធ្វើឱ្យស្តេចកោតសរសើរចំពោះប្រាជ្ញារបស់ **ធនញ្ជ័យ** និងលែងហ៊ានប៉ះពាល់ដល់អាយុជីវិតគាត់ទៀត។ ស្តេចស្រុកចិនកោតក្រែង **ធនញ្ជ័យ** ណាស់ ថែមទាំងឱ្យសំពៅនិងខ្ញុំកំដរជាតិចិនមកតាមបម្រើ **ធនញ្ជ័យ** ហើយអង្វរសុំឱ្យតែ **ធនញ្ជ័យ** កុំខឹងនឹងខ្លួនដែលបានប្រព្រឹត្តលើសលស់កាលពីមុន។ លុះនៅពេល **ធនញ្ជ័យ** ស្លាប់អ្នកនិពន្ធមិនបានឱ្យគាត់ស្លាប់ដោយចាញ់កម្លាំងកាយប្រាជ្ញា ឬឧបាយកលខ្មៅងងឹតរបស់នរណាម្នាក់ដែរ តែគាត់ស្លាប់ដោយសារជំងឺបានន័យថា **ធនញ្ជ័យ** ស្លាប់តាមបែបធម្មជាតិ ដែលតាក់តែងឱ្យសត្វលោករាល់រូបពុំមាននរណាម្នាក់នឹងចៀសផុតបានឡើយ។ ការស្លាប់នេះគេមិនអាចចោទបានថា គាត់ស្លាប់ដោយ

ចាញ់ពួកនាម៉ឺនឬស្ដេចឬក៏ទទួលទណ្ឌកម្មពីអ្នកនិពន្ធឡើយ។

បើពិចារណាទៅលើចំណុចម្ខាងទៀតគេអាចយល់បានថា ការធ្វើឱ្យ **ធនញ្ជ័យ** ស្លាប់នៅក្នុងករណីនេះ ជាលក្ខខណ្ឌចាំបាច់របស់អ្នកនិពន្ធដើម្បីបញ្ចប់រឿង ព្រោះបើអ្នកនិពន្ធមិនឱ្យ **ធនញ្ជ័យ** ស្លាប់ទេសាច់រឿងនៅតែបន្តអូសបន្លាយរហូតគ្មានទីបញ្ចប់ ដោយហេតុថាទំនាស់នៅតែកើតមានជារៀងរហូត ព្រោះ **ធនញ្ជ័យ** ដាច់ខាតមិនព្រមរណបចុះចាញ់ឬសម្រួលឥរិយាបថចំពោះអ្នកមានអំណាច ដែលចូលចិត្តប្រើអំណាចគាបសង្កត់អ្នកតូចឡើយ ពោលគឺ **ធនញ្ជ័យ** មិនព្រមឱនក្បាលគោរពឡើយ។

ហេតុអ្វីបានជាអ្នកនិពន្ធមិនព្រមឱ្យ **ធនញ្ជ័យ** ឈ្នះដោយផ្ដួលរំលំអ្នកទាំងនោះទៅ? គោលបំណងរបស់អ្នកនិពន្ធចង់ឱ្យ **ធនញ្ជ័យ** ឈ្នះរហូតដល់ដង្ហើមចុងក្រោយ តែគាត់មិនអាចឱ្យតួឯកមួយនេះឈ្នះដោយវិធីផ្ដួលរំលំអ្នកទាំងនោះបានឡើយ ព្រោះអ្នកនិពន្ធបានគោរពទៅតាមផ្នត់គំនិតខ្មែរដែលគោរពកោតខ្លាចអ្នកទាំងនោះ ហើយចាត់ទុកជាអ្នកមានបុណ្យមកចាប់ជាតិ ម្យ៉ាងទៀតអ្នកនិពន្ធមិនទាន់ស្គាល់របបណាផ្សេងក្រៅពីរបបនេះឡើយ។ បញ្ហានេះអាចជាឫសគល់ដ៏ចម្បងដែលនាំឱ្យអ្នកនិពន្ធត្រូវបញ្ចប់រឿងគាត់តម្រូវឱ្យតួឯកស្លាប់ គឺស្លាប់ដើម្បីបញ្ចប់រឿង បញ្ចប់បេសកកម្មតស៊ូប្រឆាំងនឹងអំពើជិះជាន់។

អ្នកនិពន្ធបានបញ្ចប់រឿងដោយឱ្យ **ធនញ្ជ័យ** ស្លាប់មែន តែបានបង្កប់អត្ថន័យយ៉ាងជ្រាលជ្រៅបំផុត មានន័យថា ការតស៊ូដើម្បីឧត្ដមគតិគឺជាការតស៊ូដ៏ស្វិតស្វាញ និងត្រូវប្រើពេលវេលាយូរអង្វែងទើបអាច

សម្រេចគោលដៅបាន។ ការងារនេះត្រូវមានលក្ខណៈបន្តវេនពីជំនាន់មួយទៅជំនាន់មួយទៀត មានន័យថា បើអ្នកជំនាន់មុនតស៊ូបានមួយជំហាន អ្នកជំនាន់ក្រោយត្រូវតែតស៊ូឱ្យបានមួយជំហានឬពីរជំហានទៀត។ ក្នុងពេលនេះ **ធនញ្ជ័យ** អស់ភារកិច្ចខ្លួនមែនតែអ្នកនិពន្ធបានធ្វើឱ្យអ្នកអានបានឃើញថា បេសកកម្មដែល **ធនញ្ជ័យ** ធ្វើនោះនៅមិនទាន់ចប់ទេ ដូចជាគាត់បានពោលពាក្យជាបណ្ដាំផ្ញើសម្រាប់ស្ដេចជាដើម។ ត្រង់ន័យនេះ បញ្ជាក់ថារាល់អ្នកដឹកនាំត្រូវប្រកាន់គោលជំហរខ្លួនជានិច្ចទើបសង្គមជាតិបានរីកចម្រើន។ សេចក្តីក្លាហានរបស់ **ធនញ្ជ័យ** ពិតជាដក់ជាប់នៅក្នុងសន្ដានចិត្តអ្នកអានគ្រប់ស្រទាប់។ ម្យ៉ាងទៀតអ្នកជំនាន់ក្រោយពិតជាស្គាល់តួនាទីជាប្រវត្តិសាស្ត្ររបស់ខ្លួនថា ជាកម្លាំងចលករធំបំផុតរបស់ជាតិក្នុងការការពារទឹកដី សិទ្ធិសេរីភាព និងសម្រេចវាសនាខ្លួនឯង។ ទាំងអស់នេះគឺជាគំនិតរបស់អ្នកនិពន្ធដ៏ឈ្លាសវៃដែលបង្ហាញតាមរយៈស្នាដៃរបស់លោក។

នៅទីបញ្ចប់នៃរឿងអ្នកនិពន្ធមានជំនឿយ៉ាងមុតមាំថា អ្វីៗដែល **ធនញ្ជ័យ** បានបណ្ដុះហើយពិតជាមិនមាននរណាអាចមកក្តិចបានឡើយ។ ជំនឿជាក់នេះឆ្លុះបញ្ចាំងតាមរយៈនិមិត្តរូបផ្នូររបស់ **ធនញ្ជ័យ** ដែលអត់មាននរណាមួយហ៊ានទៅប៉ះពាល់ឱ្យអន្តរាយឡើយ។

សរុបយោបល់មក ប្រការដែលអ្នកនិពន្ធធ្វើឱ្យតួអង្គឯកស្លាប់ពុំមែនមានន័យថា ជាការដាក់ទណ្ឌកម្មឬចាញ់ឧបាយកលរបស់ជនណាម្នាក់ឡើយ ពោលគឺមរណភាពនេះជាច្បាប់ធម្មជាតិដែល

តាក់តែងឱ្យមនុស្សរាល់រូបត្រូវទទួល ហើយវាក៏ជាសត្យានុម័តិផង ជាគំនិតសុទិដ្ឋិនិយមរបស់អ្នកនិពន្ធផង ព្រមទាំងជាការបណ្ដុះស្មារតីទទួលខុសត្រូវដល់អ្នកជំនាន់ក្រោយថែមទៀត។

# ប្រធានពិភាក្សា

ប្រធានពិភាក្សា គឺជាប្រធានតែងសេចក្ដីមួយបែបដែលតម្រូវឱ្យអ្នកថ្លឹងថ្លែងពិចារណាទៅលើមតិពីរ គឺមតិស្របនិងមតិផ្ទុយ ឬមួយជាការផ្ដល់យោបល់វែកញែក ដោយបង្ហាញហេតុផលនិងមានអំណះអំណាងច្បាស់លាស់ទៅលើខ្លឹមសារនៃការបកស្រាយ។ ប្រធានពិភាក្សាមានពីរ គឺពិភាក្សាតែមួយមតិឬហៅថាពិភាក្សាសុទ្ធនិងពិភាក្សាពីរមតិហៅថាពិភាក្សាប្រៀបធៀប។

ប្រធានពិភាក្សាសុទ្ធឬពិភាក្សាមួយមតិ គឺតម្រូវឱ្យអ្នកសរសេរបង្កើតមតិថ្មី ដើម្បីប្រឆាំងមតិប្រធាននិងមានអំណះអំណាងបញ្ជាក់ដែរ។

ប្រធានពិភាក្សាប្រៀបធៀបឬពិភាក្សាពីរមតិ គឺប្រធានបានចោទមានពីរមតិរួចជាស្រេច ហើយមតិទាំងពីរនេះប្រឆាំងគ្នារួចជាស្រេចទៅហើយ ដែលតម្រូវឱ្យអ្នកសរសេរបកស្រាយស្របទៅតាមមតិប្រធានទាំងពីរដោយមានជាប់ជាមួយនឹងអំណះអំណាងផងដែរ។

គេអាចសម្គាល់ប្រធានពិភាក្សាបានដោយមានពីររបៀប៖

**១- ពាក្យចោទសួរ**

- តើអ្នកយល់ស្របដែរឬទេ?

- ចំពោះអ្នកវិញ តើយល់ដូចម្ដេច?

- តើអ្នកយល់យ៉ាងណាដែរ?

- តើមតិនេះត្រឹមត្រូវដែរឬទេ?

- តើមតិទាំងពីរនេះមួយណាត្រឹមត្រូវជាង?

**២- ពាក្យបង្គាប់បញ្ជា**

- ចូរពិភាក្សា។

- ចូរវិនិច្ឆ័យ។

- ចូរថ្លឹងថ្លែង។

- ចូរវែកញែក។

- ចូរប្រៀបធៀប...។

ដើម្បីបកស្រាយប្រធានប្រភេទនេះបានត្រឹមត្រូវល្អ សូមអ្នកធ្វើតាមការណែនាំដូចខាងក្រោម៖

- ត្រូវគោរពតាមគោលការណ៍ប្រធានពិភាក្សាឱ្យបានត្រឹមត្រូវ។

- ត្រូវកំណត់ប្រធានបទឱ្យបានត្រឹមត្រូវ។

- ត្រូវស្គាល់ប្រភេទប្រធានពិភាក្សាឱ្យបានច្បាស់លាស់។

- រាល់ការបកស្រាយមតិត្រូវមានអំណះអំណាងបញ្ជាក់។

- ការភ្ជាប់ឃ្លាមួយទៅឃ្លាមួយត្រូវមានឃ្លាភ្ជាប់សេចក្ដី។

- ត្រូវចេះធ្វើគម្រោងមុននឹងបកស្រាយចៀសវាងការបកស្រាយច្រលំឬចាកប្រធានជាដើម។

- គោរពតាមក្បួនខ្នាតវេយ្យាករណ៍។

- ត្រូវសរសេរឱ្យមានរបៀបរៀបរយល្អ។
- គោរពតាមគោលការណ៍អក្ខរាវិរុទ្ធខ្មែរ។

## ១- ប្រធានពិភាក្សាសុទ្ធឬពិភាក្សាមួយមត

ប្រធានបែបនេះ គេចោទមកតែមួយមតិប៉ុណ្ណោះ។ ការចោទនេះជួនពេលខ្លះអាចត្រូវក៏មាន ពេលខ្លះអាចខុសក៏មាន។ ប្រធានបែបនេះតម្រូវឱ្យអ្នកបកស្រាយបង្កើតទស្សនៈថ្មី ដើម្បីធ្វើការប្រឆាំងជាមួយនឹងមតិប្រធាន។ ទោះបីជាមើលឃើញមតិប្រធានថាត្រូវក៏ដោយក៏ប្រធាននេះតម្រូវឱ្យបង្កើតមតិប្រឆាំងជានិច្ច។ ការថ្លឹងថ្លែង គឺមតិណាដែលត្រូវរក្សាតម្លៃដដែលដោយមិនមានការផ្លាស់ប្តូរ។

### គម្រោងសរសេរប្រធានពិភាក្សាសុទ្ធឬពិភាក្សាមួយមត

### ក- សេចក្តីផ្តើម

- ❖ លំនាំបញ្ហា : ធ្វើសេចក្តីឱ្យជាប់ទាក់ទងនឹងប្រធាន។
- ❖ ចំណូលបញ្ហា : លើកយកទស្សនៈប្រធានមកដាក់។
- ❖ ចំណោទបញ្ហា : ចោទសួរជារបៀបប្រធានពិភាក្សា។

### ខ- តួសេចក្តី

- ❖ ឃ្លាភ្ជាប់សេចក្តី : “ប្រធានមានពាក្យគន្លឹះដែលត្រូវពន្យល់”។
- ❖ ពន្យល់ពាក្យ : ពន្យល់ពាក្យគន្លឹះដោយមានឃ្លាភ្ជាប់សេចក្តី។
- ❖ ពន្យល់ប្រធាន : ពន្យល់ទស្សនៈប្រធានដែលបានចោទ។
- ❖ បកស្រាយប្រធាន : ចែកជាពីរសំខាន់ៗ៖

+ *បកស្រាយមតិស្រប* គឺបកស្រាយឱ្យស្របតាមទស្សនៈរបស់ប្រធានដែលបានចោទ រួចត្រូវលើកយកឧទាហរណ៍មកបញ្ជាក់ឱ្យបានច្បាស់លាស់ (ក្នុងប្រវត្តិសាស្ត្រ ក្នុងសង្គម ក្នុងអក្សរសិល្ប៍) នៅចុងបញ្ចប់ គឺត្រូវធ្វើសំយោគតូចមួយដោយមិនចុះដើមបន្ទាត់។

+ *បកស្រាយមតិផ្ទុយ* គឺអាស្រ័យដោយមតិប្រធានមានតែមួយនៅពេលនេះចាំបាច់អ្នកសរសេរត្រូវបង្កើតទស្សនៈថ្មី ដើម្បីប្រឆាំងនឹងមតិរបស់ប្រធាន។ ទោះបីជាមតិប្រធានយល់ថាត្រឹមត្រូវ ក៏ចាំបាច់នៅតែបង្កើតទស្សនៈប្រឆាំងជានិច្ច។ ការបង្កើតទស្សនៈប្រឆាំងនេះទៀតសោត គឺបើប្រធាននិយាយពីអ្វី ចាំបាច់អ្នកត្រូវបង្កើតទស្សនៈប្រឆាំងនោះនិយាយពីប្រធានបទនោះដដែលទើបសមរម្យ។ នៅពេលបង្កើតទស្សនៈដែលប្រឆាំងនឹងប្រធានបានហើយ អ្នកត្រូវបកស្រាយមតិនោះសាជាថ្មីឡើងវិញ ដោយត្រូវមានឧទាហរណ៍មកបញ្ជាក់ឱ្យបានច្បាស់លាស់ បន្ទាប់មកត្រូវធ្វើសំយោគគំនិតតូចមួយដោយមិនមានចុះដើមបន្ទាត់ឡើយ។

❖ សំយោគគំនិត : នៅពេលនេះចាំបាច់ត្រូវយកមតិទាំង២មកផ្ទឹមថ្លឹងថ្លែងរកសេចក្តីខុសត្រូវ។ មតិទាំងពីរគឺមតិប្រធាននិងមតិដែលបង្កើតឡើង។ អ្នកត្រូវវិនិច្ឆ័យដោយផ្អែកលើគោលការណ៍សីលធម៌និងសេចក្តីថ្លៃថ្នូររបស់សង្គមជាមូលដ្ឋាន ដើម្បីជ្រើសរើសយកមតិណាមួយជាមតិដែលត្រឹមត្រូវជាងគេ។ នៅពេលវាយតម្លៃគេមិនអាចថាមតិប្រធានត្រឹមត្រូវឬមតិដែលបង្កើតឡើងនោះត្រឹមត្រូវទេ គឺអាស្រ័យ

ទៅលើការវិនិច្ឆ័យប៉ុណ្ណោះ។

ពេលអ្នកមិនបានសំយោគគំនិតទេការបកស្រាយ គឺគ្មានន័យអ្វីទាំងអស់ ព្រោះសំយោគគំនិតសំខាន់ណាស់សម្រាប់ប្រធានពិភាក្សា។ ពេលចាប់បានមតិណាមួយត្រឹមត្រូវហើយ អ្នកត្រូវនិយាយពីមូលហេតុដែលនាំឱ្យយកមតិនោះជាមតិដែលត្រឹមត្រូវផង។ ការបដិសេធមតិមួយដែលមិនត្រឹមត្រូវ គឺមិនអាចប្រើឃ្លាបដិសេធដាច់ខាត ត្រូវចេះប្រើឃ្លាមួយដែលស្តាប់ទៅពីរោះ ដូចជាអាចសរសេរបានថា *"មតិនេះត្រឹមត្រូវម្យ៉ាងដែរ តែ..., ការយល់ឃើញនេះបានតែជ្រុងម្ខាង ប៉ុន្តែ..., មតិដែលលើកឡើងនេះមិនទាន់ត្រឹមត្រូវទេ ព្រោះ..., មានមនុស្សជាច្រើនណាស់ដែលយល់ឃើញដូចនេះ ប៉ុន្តែ..."* ជាដើម។

**គ- សេចក្តីបញ្ចប់**

❖ វង្វាយតម្លៃប្រធាន : វាយតម្លៃប្រធានដែលបានលើកឡើងខាងលើដូចជាអ្វីដែលធ្លាប់បានធ្វើក្នុងប្រធានពន្យល់ដែរ តែខុសត្រង់ថាបើការសំយោគគំនិតឱ្យមតិប្រធានខុស ការវាយតម្លៃក៏ត្រូវដាក់បន្ទុកមួយដល់ប្រធានដែរដោយមានបញ្ជាក់ហេតុផលច្បាស់លាស់ផង។

❖ មតិផ្ទាល់ខ្លួន : ធ្វើដូចជាប្រធានពន្យល់ដែរ តែត្រូវផ្អែកលើសំយោគគំនិតនិងវង្វាយតម្លៃប្រធានជាគោល។

***ប្រធាន :*** *គេថា "ការភ្ញាក់រឮករបស់ពូហំចំពោះអំពើបោកប្រាស់របស់ថៅកែ គឺគ្មានតម្លៃអ្វីសម្រាប់សិក្សារៀនសូត្រទេ"។ តើមតិនេះត្រឹមត្រូវដែរឬទេ? ចូរពិភាក្សា។*

## សេចក្តីអធិប្បាយ

នៅក្នុងរឿងថៅកែចិត្តចោរ អ្នកនិពន្ធខំរចនាផ្ទាំងរឿងឡើងប្រកបដោយការយកចិត្តទុកដាក់ ឆ្លុះបញ្ចាំងពីតថភាពសង្គមខ្មែរសម័យមួយដែលពោរពេញទៅដោយការជិះជាន់កេងប្រវញ្ចគ្នា។ តួអង្គដែលបានលើកមកបង្ហាញ គឺក្នុងគោលបំណងបកអាក្រាតពីមុខមាត់អាក្រក់របស់នាយទុនអាណានិគម។ ទន្ទឹមនឹងនេះដែរមានមតិមួយបានលើកឡើងទាក់ទងនឹង **ពូហំ** ថា "ការភ្ញាក់រឮករបស់ **ពូហំ** ចំពោះអំពើបោកប្រាស់របស់ថៅកែ គឺគ្មានតម្លៃអ្វីសម្រាប់សិក្សារៀនសូត្រទេ"។

តើមតិលើកឡើងនេះត្រឹមត្រូវដែរឬទេ?

ប្រធានមានពាក្យគន្លឹះដែលត្រូវពន្យល់។ ពាក្យថា "ភ្ញាក់រឮក" មានន័យថា រឮកឡើងវិញ នឹកឃើញ យល់ឡើងវិញ។ ចំណែកពាក្យថា "បោកប្រាស់" មានន័យថា គឺការបំភាន់គេដោយការប្រើពាក្យសម្ដីឱ្យគេជឿលង់គំនិត។

ប្រធានដែលបានលើកឡើងខាងលើមានន័យថា ការនឹកឃើញឡើងវិញពីគុណធម៌របស់ពូហំពីការបំភាន់ដោយពាក្យសម្ដី ដែលថៅកែបានបោកប្រាស់នោះ គឺជារឮកមួយដែលគ្មានតម្លៃសម្រាប់យកមកសិក្សាវិភាគទេ។

ប្រការដែលមានគំនិតយល់ឃើញដូច្នេះ ក៏ព្រោះតែឃើញថារឿងបានណែនាំមនុស្ស ជាអ្នកសិក្សារៀនសូត្រឱ្យគិតតែប្រយោជន៍

ផ្ទាល់ខ្លួនហើយកុំឱ្យគិតប្រយោជន៍អ្នកដទៃ។ ដូចអ្វីដែលបានឃើញស្រាប់ **ពូហំ** គឺជាមនុស្សម្នាក់បានចាត់ទុកប្រយោជន៍គ្រួសារធំជាងអ្វីៗទាំងអស់ដែលនៅជុំវិញខ្លួន សូម្បីតែជីវិតអ្នកដទៃក៏មិនអាចស្មើដែរ។ ដោយសារការតម្កល់ចិត្តបែបនេះហើយ ទើបពូហំបានសម្រេចចិត្តធ្វើតាមបញ្ជាថៅកែបើកឡានទៅបុកឡានថៅកែ **ហុងលី** ទាំងកំរោល។ គោលបំណងដ៏ស្រួចស្រាវដែលបណ្ដាលចិត្តគាត់ធ្វើបែបនេះ គឺដើម្បីតែប្រាក់មួយម៉ឺនរៀលសម្រាប់យកទៅជាអត្តទត្ថបុគ្គលប៉ុណ្ណោះ។ ប្រពន្ធឈឺក្អក កូនត្រូវការរៀននៅអនុវិទ្យាល័យ ម៉ែត្រូវការលុយសម្រាប់ធ្វើបុណ្យ ពូហំត្រូវប៉ានធ្វើដោយមិនគិតពិចារណារកដំណោះស្រាយផ្សេងដែលល្អជាងនេះទេ។ សកម្មភាពគាត់ហាក់ដូចជាជំរុញអ្នកសិក្សាឱ្យត្រូវធ្វើតាមគាត់ខណៈដែលមានការទាល់ច្រកដូចរូបគាត់។

ចំណុចមួយទៀតដែលគ្មានតម្លៃ ហើយត្រូវបានគេសម្លឹងមើលឃើញនោះគឺ នៅក្នុងអត្ថបទរឿងនេះមានការបញ្ចុះតម្លៃចលនាតស៊ូដោយសាមគ្គីភាព។ ជាក់ស្ដែងអ្នកដែលទាមទាររកយុត្តិធម៌ទាំងឡាយត្រូវបរាជ័យ អ្នកខ្លះត្រូវគេចាប់ដាក់គុក។ ព្រមទាំងមានការវាយបំបាក់ស្មារតីនេះ ជាមេរៀនដ៏ជូរចត់មួយបន្សល់ទុកឱ្យអ្នកសិក្សាបាក់ស្បាតក្នុងការជជែករកខុសត្រូវចំពោះអំពើជិះជាន់។ បញ្ហានេះជាបច្ច័យល្អសម្រាប់អ្នកជិះជាន់យកមកអនុវត្តលើផែនការខ្មៅងងឹត ដល់ប្រជាជនក្រីក្រនិងស្លូតត្រង់។

ដោយយោងទៅលើបញ្ហានេះហើយបានជាគេថា ការភ្ញាក់រឭក

របស់ **ពូហំ** ចំពោះអំពើបោកប្រាស់របស់ថៅកែ គឺគ្មានតម្លៃអ្វីសម្រាប់សិក្សាទេព្រោះហេតុផលដែលបានមក គឺជាដំណោះស្រាយទាល់ច្រកតែប៉ុណ្ណោះ។ នៅក្នុងលក្ខខណ្ឌនេះមិនមែន **ពូហំ** មិនដឹងពីអំពើបោកប្រាស់របស់ថៅកែទេ គាត់បានដឹងចាប់តាំងពីបានមកនៅពីដំបូងម្ល៉េះ តែគាត់ចេះសំងំស្ងៀម។ ទាំងនេះព្រោះតែការគោរពនិងឱ្យតម្លៃតាមសកម្មភាពគាត់ជានិច្ច លុះមកដល់ដំណាក់កាលចុងក្រោយដែលគាត់មិនបានទទួលផលប្រយោជន៍ ទើបគាត់តាំងស្រែកទាមទាររកយុត្តិធម៌ទៅវិញ។ ប្រការដែលគាត់ធ្វើនេះជារឿងអស់សំណើចណាស់ ដូចជាពាក្យគេនិយាយលេងថា "***បើឯងមិនឱ្យអញ អញប្រាប់គេ***"។ សរុបសេចក្តីមកការលើកឡើងដោយមានហេតុផលច្បាស់លាស់ខាងលើ អាចចាត់ទុកថា ការភ្ញាក់រឭករបស់ពូហំនៅក្នុងរឿងបោកប្រាស់របស់ថៅកែ គឺពិតជាគ្មានតម្លៃសម្រាប់យកមកសិក្សារៀនសូត្រ ដូចមតិប្រធានដែលបានលើកឡើងខាងលើប្រាកដមែន។

ប៉ុន្តែផ្ទុយទៅវិញមិនដូចអ្វីដែលមតិប្រធានបានលើកឡើងទេ។ មានមតិមួយទៀតបានលើកឡើងប្រឆាំងតបថា "***ការភ្ញាក់រឭករបស់ ពូហំ ក្នុងអំពើបោកប្រាស់របស់ថៅកែ ពោរពេញទៅដោយតម្លៃអប់រំយ៉ាងត្រចះត្រចង់បំផុតសម្រាប់បំភ្លឺផ្លូវមនុស្សទាំងឡាយនៅខាងក្រោយ ឱ្យមើលឃើញពីក្រយៅកលល្បិចដ៏សាហាវរបស់នាយទុន***"។

ក្នុងការរស់នៅជាសង្គម មនុស្សគ្រប់គ្នាត្រូវចេះប្រុងប្រយត្នខ្លួនប្រាណជានិច្ច ពិសេសជាមួយនាយទុនព្រោះតែពួកនេះ ជាក្រុមមនុស្សដែលមានកលល្បិចខ្ពស់សព្វបែបយ៉ាង នៅក្នុងការអូសទាញមនុស្ស

ស្លូតត្រង់ឱ្យធ្លាក់ក្នុងក្ដីវិនាសអន្តរាយ។ **ពូហាំ** ដែលផុងខ្លួនក្លាយជាមនុស្ស ជាប់ទោសតែម្នាក់ឯង ក៏ព្រោះតែគាត់ជឿពាក្យសម្ដីដ៏ផ្អែមពីរោះរបស់ ថៅកែដែរ។ នៅគ្រាដែលថៅកែត្រូវការ **ពូហាំ** ឱ្យជួយសម្រេចការងារ សម្លាប់មនុស្ស ដូចជាអ្វីដែលគាត់បានគ្រោងទុកនោះ លោកថៅកែ នេះបែរជាចោទគាត់ថា ជាមនុស្សឆ្កួតស្រវឹងទៅបើកឡានបង្កអន្តរាយ ទៅវិញ។ ថៅកែបានទាត់ចោល **ពូហាំ** លែងដឹងឮរឿងអ្វីសព្វបែបយ៉ាង រហូតគេប្រើអំណាចទឹកប្រាក់ទៅសូកប៉ាន់ពួកមន្ត្រីពុករលួយ ដែលជា មនុស្សក្បត់តួនាទីខ្លួន។ ទីបំផុតគេត្រូវងាកមកចាប់ **ពូហាំ** ទៅទទួលទោស តែម្នាក់ឯងវិញ។

ចំណុចមួយទៀត ដែលអ្នកនិពន្ធចង់បង្ហាញប្រាប់អ្នកសិក្សានិង អ្នកអានគ្រប់ស្រទាប់វណ្ណៈនោះ គឺឱ្យចេះប្រឈមមុខនឹងការពិតទាមទារ រកយុត្តិធម៌និងភាពស្មោះត្រង់ ដែលកំពុងតែត្រូវបានគេបំបាត់ចោល យ៉ាងព្រៃផ្សៃបំផុត។ តម្លៃមនុស្សជាតិពិតមិនមែនឃើញអំពើអយុត្តិធម៌ ហើយ ដេកសំងំស្ងៀមឬសុខចិត្តឱនក្បាលឱ្យគេជិះជាន់នោះទេ។ នៅ ពេលដែល **ពូហាំ** ចូលដល់ក្នុងផ្ទះ **ពូហាំ** ដឹងច្បាស់ណាស់ថា ថៅកែមាន ចិត្តប្រែប្រួល ថែមទាំងមិនចង់ប្រគល់ប្រាក់រង្វាន់ឱ្យមកខ្លួន ទើបគាត់ ត្រូវសម្រេចចិត្តនៅទាមទារមិនព្រមទៅណា ទោះបីជាថៅកែគំរាមថា គាត់នឹងត្រូវជាប់គុកក៏ដោយ។ **ពូហាំ** មានស្មារតីរើបម្រះយ៉ាងមុតមាំ ប្រឆាំងអំពើលាមកថៅកែយ៉ាងពិតប្រាកដ មិនមានញញើតឬកោតខ្លាច អ្វីទេ។ ពួកកម្មករ **មាន គង់ សុខ ទ្រី** និង **ផានីត** គឺជាអ្នកដែលគាំទ្រ **ពូហាំ**

ហើយបានកៀកស្មារើបម្រះជាមួយនឹង **ពូចាំ** ប្រឆាំងនឹងថៅកែចិត្តចោរ យ៉ាងអង់អាច។ ជាពិសេសពួកគេមិនព្រមទទួលប្រាក់កខ្វក់ពីថៅកែ ដើម្បីធ្វើជាសាក្សីបញ្ជាក់ថា ថៅកែពិតជាគ្មានទោសកំហុសអ្វីឡើយ គឺមានតែ **ពូចាំ** ខ្លួនឯងតែម្នាក់ប៉ុណ្ណោះដែលជាអ្នកប្រព្រឹត្តកំហុសមួយនេះ។ ពួកគេដឹងច្បាស់ណាស់ថា កាលណាគេបានធ្វើបាបថៅកែ គឺថៅកែត្រូវតែបញ្ឈប់ការងារគេនិងត្រូវទទួលទោសក៏ដោយ តែគេនៅតែធ្វើដោយគ្មានខ្លាចរអាទេ។ ទាំងនេះក៏ព្រោះដើម្បីយុត្តិធម៌។ ចំណុចនៃសកម្មភាពការងារទោះជាមិនបានទទួលលទ្ធផលល្អក៏ដោយ ប៉ុន្តែជាចំណុចមួយ សម្រាប់ជួយបណ្ដុះស្មារតីឈឺចាប់ដល់ជនជំនាន់ក្រោយឱ្យស្អប់ខ្ពើមអំពើពុករលួយរបស់អាជ្ញាធរមានសមត្ថកិច្ច បានសេចក្ដីថា បរាជ័យនៃពួកកម្មករ ជាអ្នករងអំពើអយុត្តិធម៌ពីសំណាក់ពួកនគរបាល និងថៅកែបានបង្កាត់ភ្លើងកំហឹងឈឺចាប់ យ៉ាងមហាសាលដល់មនុស្សទូទៅនៅក្នុងសង្គមឱ្យរឹតតែស្អប់ខ្ពើមអំពើនេះបន្ថែមទៀត ហើយគង់មានថ្ងៃណាមួយ អំពើបះបោរប្រឆាំងទាមទាររកយុត្តិធម៌នឹងទទួលបានជោគជ័យនិងការគាំទ្រពីគ្រប់មជ្ឈដ្ឋានពុំខាន។ សរុបសេចក្ដីមកការភ្ញាក់រឭករបស់ **ពូចាំ** ទោះបីជាមានការយឺតយ៉ាវបន្តិចមែនក៏សេចក្ដីនេះមានអត្ថប្រយោជន៍យ៉ាងធំធេងណាស់ ដល់ការរស់នៅក្នុងសង្គមមនុស្សឱ្យចេះស្វែងយល់ ស្អប់ខ្ពើមអំពើពុករលួយ និងការអាងមាសប្រាក់ធ្វើបាបអ្នកក្រនិងបង្កភាពចលាចលក្នុងសង្គម។

រួមសេចក្ដីមក ការបកស្រាយខាងលើនេះអាចធ្វើការពិភាក្សា

យ៉ាងល្អិតល្អន់ទៅលើមតិទាំងពីរបាន។ មតិទីមួយដែលបាននិយាយថា ការភ្ញាក់រឭករបស់ **ឭចាំ** គឺគ្មានប្រយោជន៍អ្វីសម្រាប់សង្គមនោះ ជាគំនិតមួយដែលធ្វើឱ្យសង្គមមនុស្ស រឹតតែមានភាពអនាធិបតេយ្យថែមទៀត ពិសេសចលនាតស៊ូក្នុងការទាមទាររកយុត្តិធម៌ ត្រូវបានបង្អាក់ដំណើរជាប្រាកដ។ ចំណែកមតិទីពីរដែលបានលើកឡើងថា ការភ្ញាក់រឭកនេះ គឺមានអត្ថប្រយោជន៍ ជាគំនិតមួយសម្រាប់ពិចារណាបំផុសស្មារតីនិងសេចក្តីក្លាហាន ហ៊ានក្រោកឈរប្រឆាំងការជិះជាន់មិនមានញញើតដែលជាការរកផ្លូវផ្តួលរំលំអំពើជិះជាន់ក្នុងសង្គមជាតិ។

ឆ្លងតាមការបកស្រាយខាងលើ សបញ្ជាក់ថាមតិរបស់ប្រធាន គឺមិនមានតម្លៃសម្រាប់ការរស់នៅក្នុងសង្គមទេ មានន័យថាបានបង្អាក់ដំណើរការតស៊ូរបស់អ្នកមានគំនិតឱ្យបែកខ្ញែកគ្នា បាក់ស្បាតចំពោះអំពើជិះជាន់ ហើយនឹងមានគំនិតរស់នៅតាមកម្មដែលពួកវណ្ណៈជិះជាន់បានសាបព្រោះមកលើស្មារតីពួកគេ។ មនុស្សមិនមែនជាសត្វ មនុស្សមានសេចក្តីឈឺចាប់ មនុស្សត្រូវតែមានការតស៊ូ រើបម្រាស់នៅខណៈពេលណាដែលអំពើជិះជាន់បានកើតឡើងចំពោះរូបគេគ្រប់គ្នា។

ក្នុងនាមយើងជាសិស្សានុសិស្ស ត្រូវតែបណ្តុះស្មារតីជាអ្នកដែលរស់នៅក្នុងស្រទាប់អ្នកពិចារណាជានិច្ច ដែលគំនិតនេះបានមកពីការខិតខំស្វាធ្យាយសិក្សារៀនសូត្រសព្វមុខវិជ្ជា។ យើងត្រូវចេះដកស្រង់បទពិសោធល្អៗសម្រាប់ជីវិតរស់នៅក្នុងសង្គមទៅអនាគត។

## ២- ប្រធានពិភាក្សាប្រៀបធៀបឬពិភាក្សាពីរមតិ

ប្រធានពិភាក្សាប្រៀបធៀបឬប្រធានពិភាក្សាមានពីរមតិ គឺជាប្រភេទតែងសេចក្តីមួយប្រភេទ ដែលការលើកឡើងរបស់ប្រធានមានពីរមតិ។ មតិទាំងពីរនេះបានប្រឆាំងគ្នារួចជាស្រេចទៅហើយ។ រាល់ការបកស្រាយមតិនីមួយៗត្រូវឱ្យស្របជានិច្ច និងត្រូវធ្វើជាដំណាក់កាលៗ។ មតិណាដែលបានចោទឡើងមុនគេ ជាមតិស្របនឹងត្រូវបកស្រាយមុនគេ។

លក្ខខណ្ឌដែលត្រូវធ្វើ មិនមានអ្វីខុសពីប្រភេទប្រធានពិភាក្សាមួយមតិឬពិភាក្សាសុទ្ធទេ។ ចូរពិនិត្យមើលគំរូសរសេរខាងក្រោម៖

### គំរូសរសេរប្រធានពិភាក្សាប្រៀបធៀបឬពិភាក្សាពីរមតិ

**ក- សេចក្តីផ្តើម**

❖ លំនាំបញ្ហា : សរសេរបញ្ហានានាឱ្យជាប់ទាក់ទងនឹងប្រធាន។ បើប្រធានចោទពីរមតិដូច្នេះអ្នកត្រូវធ្វើលំនាំឱ្យទាក់ទងទាំងពីរមតិដែរ។

❖ ចំណូលបញ្ហា : លើកទស្សនៈប្រធានមកដាក់ក្នុងសញ្ញា “...”។ នៅចន្លោះមតិមួយទៅមតិមួយទៀត អ្នកត្រូវមានឃ្លាភ្ជាប់សេចក្តីផង និងនៅដើមល្បះនៃចំណូលបញ្ហាក៏ត្រូវមានឃ្លាភ្ជាប់សេចក្តីដែរ។

❖ ចំណោទបញ្ហា : ចោទសួរទាំងពីរមតិជាលក្ខណៈប្រធានពិភាក្សា ដូចជាអាចចោទថា *តើមតិទាំងពីរនេះមួយណាត្រឹមត្រូវជាង?*

**ខ- តួសេចក្តី**

❖ ឃ្លាភ្ជាប់សេចក្តី

❖ ពន្យល់ពាក្យ

❖ ពន្យល់ប្រធាន : អាស្រ័យដោយប្រធានមានពីរមតិដែលឈមគ្នាដូចនេះអ្នកក៏ត្រូវពន្យល់ប្រធានទាំងពីរដែរ។ អ្នកត្រូវចាំជានិច្ចថាពីមតិមួយទៅមតិមួយដាច់ខាតអ្នកត្រូវប្រើឃ្លាភ្ជាប់សេចក្ដីជានិច្ច ដើម្បីឱ្យល្បះយើងមានភាពរលូនពីរោះតាមបែបបទតែងសេចក្ដី។

❖ បកស្រាយប្រធាន

+ *បកស្រាយមតិទី១* : មតិណានៅខាងដើមឬចោទមុនគេត្រូវចាត់ទុកជាមតិទី១ រួចអ្នកធ្វើការបកស្រាយដូចជាប្រធានពន្យល់ដែរពោលគឺមានបកស្រាយន័យប្រធាន លើកឧទាហរណ៍មកបញ្ជាក់ ដូចជាក្នុងប្រវត្តិសាស្ត្រ ក្នុងសង្គម ក្នុងអក្សរសិល្ប៍។ នៅទីបញ្ចប់នៃការបកស្រាយមតិទី១នេះ អ្នកត្រូវមានសំយោគរួមតូចមួយផងដោយមិនចាំបាច់ចុះដើមបន្ទាត់ទេ។ ការបកស្រាយនេះមានកថាខណ្ឌចំនួនពីរ គឺបកស្រាយន័យប្រធាន (មតិទី១) និងចំណុចលើកឧទាហរណ៍ តែត្រូវចាំថា នៅចំណុចលើកឧទាហរណ៍ក្នុងប្រវត្តិសាស្ត្រប្រសិនជាគ្មានសូមកុំព្យាយាមលើកមកបង្ហាញ។

+ *បកស្រាយមតិទី២* : មុនឈានទៅដល់ការបកស្រាយគប្បីត្រូវប្រើឃ្លាបដិសេធជាមុនសិន។ លុះមកដល់ចំណុចបកស្រាយហើយអ្នកត្រូវអនុវត្ត ដូចជាការបកស្រាយមតិទី១ដែរ។ ភាពប៉ិនប្រសប់នៃការបកស្រាយអ្នកត្រូវធ្វើយ៉ាងណាឱ្យការប្រឆាំងនេះ ហាក់ដូចជាមនុស្ស២នាក់កំពុងឈ្លោះគ្នាអ៊ីចឹង។

❖ សំយោគគំនិត : អនុវត្តដូចជាប្រធានពិភាក្សាសុទ្ធដែរ។

**គ- សេចក្តីបញ្ចប់**

❖ វាយតម្លៃប្រធាន : ធ្វើដូចប្រធានពិភាក្សាសុទ្ធដែរ។

❖ មតិផ្ទាល់ខ្លួន : ដូចប្រធានពិភាក្សាសុទ្ធដែរ។

**ប្រធាន** : *មានមតិមួយបានពោលថា "មាសប្រាក់មានតម្លៃជាងចំណេះវិជ្ជា" រីឯមតិមួយទៀតបានលើកឡើងថា "ចំណេះវិជ្ជាមានតម្លៃជាងមាសប្រាក់"។ តើមតិទាំងពីរនេះមួយណាត្រឹមត្រូវជាង។ ចូរវែកញែកឱ្យបានច្បាស់លាស់។*

**សេចក្តីអធិប្បាយ**

ធម្មតាការរស់នៅក្នុងសង្គមមនុស្ស តែងតែមានតម្រូវការជាចាំបាច់នូវចំណេះវិជ្ជានិងទ្រព្យសម្បត្តិ ដើម្បីចិញ្ចឹមជីវិតក្នុងភាពសមរម្យនិងសេចក្តីថ្លៃថ្នូររបស់បុគ្គលម្នាក់ៗ។ យ៉ាងណាមិញចំណុចនេះក៏លេចចេញជាបញ្ហាចម្រូងចម្រាសរវាងមតិពីរ ដែលម្ខាងៗយល់ទៅលើហេតុផលផ្សេងៗគ្នា។ ហេតុនេះហើយមានមតិពីរលើកឡើងថា "មាសប្រាក់មានតម្លៃជាងចំណេះវិជ្ជា" រីឯមតិមួយទៀតបានលើកឡើងថា "ចំណេះវិជ្ជាមានតម្លៃជាងមាសប្រាក់"។

តើមតិទាំងពីរនេះមួយណាត្រឹមត្រូវជាង?

ប្រធានមានពាក្យដែលត្រូវពន្យល់។ ពាក្យថា "ចំណេះវិជ្ជា" មានសេចក្តីថា សេចក្តីដឹងច្បាស់ ការយល់ឃើញច្បាស់។ ចំណែក

ពាក្យថា “ទ្រព្យសម្បត្តិ” មានសេចក្តីថា ធនធានឬវត្ថុដែលមានតម្លៃ ដូចជា មាស ប្រាក់ ជាដើម។

យោងតាមប្រធានខាងលើដែលមានមតិពីរ ឃើញថាមតិទីមួយចង់បញ្ជាក់ថា លើលោកនេះមានតែមាសប្រាក់ទេដែលមានតម្លៃធំជាងគេ ទោះបីចំណេះវិជ្ជាក៏ពុំស្មើដែរ។ ដោយឡែកមតិទីពីរយល់ថាមានតែចំណេះវិជ្ជាទេដែលមានតម្លៃធំជាងគេ ទោះបីជាមាសប្រាក់ក៏កើតពីចំណេះវិជ្ជាដែរ។

ជាការពិតណាស់ បើយោងតាមមតិទីមួយដែលបានអះអាងខាងលើមានសេចក្តីថា មនុស្សរាល់រូប គឺត្រូវការមាសប្រាក់ទាំងចាស់ទាំងក្មេង ទាំងប្រុស ទាំងស្រី ដើម្បីយកទៅដោះស្រាយក្នុងជីវភាពរស់នៅរៀងៗខ្លួន។ ក្រៅពីនេះឱ្យគេទទួលបានសេចក្តីថ្លៃថ្នូរនិងមានតម្លៃសក្តិសមប្រសើរក្នុងបរិបទសង្គមរបស់គេដែរ។ មានពេលខ្លះទៀតដើម្បីតែប្រាក់មនុស្សសុខចិត្តលក់កិត្តិយស ឧត្តមគតិ អាយុជីវិតដោយឥតស្តាយស្រណោះអ្វីឡើយ។

ក្នុងសង្គម មនុស្សធ្វើការ កម្មករ លួចកេងប្រវញ្ច ពុករលួយគ្រប់រូបភាពក៏ព្រោះតែមាសប្រាក់ទាំងអស់។ ខ្លះទៀតដើម្បីមាសប្រាក់សុខចិត្តលក់ខ្លួនគ្មានភាពអៀនខ្មាស់ ទ្រាំទ្រការគាបសង្កត់គ្រប់រូបភាពឱ្យតែបានប្រាក់កាក់ជារង្វាន់លួងចិត្ត។ នៅក្នុងអក្សរសិល្ប៍ រឿងថៅកែចិត្តចោរ ពូហាំ ដើម្បីតែប្រាក់មួយម៉ឺនរៀលក៏សម្រេចចិត្តបើកឡានបុកឡានថៅកែ ហុងលី បណ្តាលឱ្យមានអ្នករបួសជាច្រើននាក់និងស្លាប់

មនុស្សផងដែរ ចំណែកប៉ូលិសដើម្បីបានប្រាក់ពីថៅកែចិត្តចោរ ក៏បានក្បត់មនសិការវិជ្ជាជីវៈជាមន្ត្រីយុត្តិធម៌របស់រាស្ត្រនោះ បានងាកមកចាប់ ពូហាំ ជាជនរងគ្រោះទៅវិញ។ ក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់តួអង្គ សៅ ដែលអ្នកនិពន្ធលោក សួន សុរិន្ទ បានឆ្លុះយកបញ្ហាមកចោទ ដោយមានលើកតួអង្គ សៅ ជាមេចោរលួចឆក់ប្លន់ហើយបានហៅ សម ឱ្យចូលដៃជើងជាមួយខ្លួន។ តាមរយៈការលើកមកបង្ហាញរបស់អ្នកនិពន្ធឃើញថា សៅ បានឱ្យតម្លៃលើមាសប្រាក់ជាងតម្លៃសីលធម៌។ គេបានប្រព្រឹត្តអំពើអសកម្មក្នុងសង្គមដូចជាលួច ឆក់ ប្លន់ជាដើម។ ដំណើរជីវិតរបស់ សៅ ដែលជាជនទុច្ចរិតនោះ គឺមានជីវភាពធូរធារ ស្លៀកពាក់សង្ហា មិនខ្វល់ខ្វះចាយ និងហូបចុកឡើយ។ ដោយឡែក សម ដែលឱ្យតម្លៃលើចំណេះវិជ្ជានិងសីលធម៌ជាសំខាន់នោះ ទីបំផុតសមក៏ត្រូវងាកមកឱ្យតម្លៃមាសជាធំដែរ ដោយនៅទីបញ្ចប់គេក៏សម្រេចចិត្តឆក់កាបូបដៃរបស់អ្នកស្រី សំបូរ សម្បត្តិ ដើម្បីបានប្រាក់កាក់ចិញ្ចឹមជីវិតបន្តទៀត។ សរុបសេចក្តីមក មាសប្រាក់ពិតជាមានតម្លៃជាងអ្វីៗទាំងអស់នៅក្នុងលោក ព្រោះមនុស្សរាល់រូបពិតជាត្រូវការជាចាំបាច់បំផុតដើម្បីចិញ្ចឹមជីវិតរបស់ខ្លួន។

មិនដូច្នេះនោះទេ មាសប្រាក់មានតម្លៃក៏ពិតមែន តែកាលណាមនុស្សអត់មានចំណេះវិជ្ជា នោះពិតជាជួបប្រទះនឹងសេចក្តីអន្តរាយក្នុងជីវិតជាពុំខាន។ កាលណាមនុស្សឱ្យតម្លៃមាសប្រាក់ជាធំនោះ សង្គម

មុខជាពោរពេញដោយភាពអយុត្តិធម៌ មានការជិះជាន់ កេងប្រវ័ញ្ច និងអំពើហិង្សា ជាដើម។ ទីបញ្ចប់បដិវត្តហិង្សាក៏មុខជាផ្ទុះឡើងយ៉ាងពិតប្រាកដ ហើយសេចក្តីសុខរបស់មនុស្សក៏អន្តរាយទៅតាមនោះដែរ។ មុននឹងមានមាសប្រាក់មកផ្គត់ផ្គង់ជីវភាព មនុស្សត្រូវតែគិតលើសេចក្តីថ្លៃថ្នូរ សីលធម៌ គុណធម៌ និងចំណេះវិជ្ជាស្នូលសិន ទើបសង្គមរួចផុតពីមហន្តរាយ។ តាមសត្យានុម័តមនុស្សមុននឹងមានមាសប្រាក់ត្រូវមានចំណេះវិជ្ជាជាមុនសិន ព្រោះចំណេះជាអ្នកបង្រៀនមនុស្សឱ្យចេះរកលុយនិងទ្រព្យសម្បត្តិដទៃទៀត។

នៅក្នុងបរិបទសង្គម ដើម្បីបានចំណេះប្រសើរ សិស្សបានយកលុយទៅបង់ថ្លៃសាលា។ ដើម្បីចេះជួសជុលរថយន្តមនុស្សយកលុយទៅរៀននៅសាលាជួសជុលរថយន្ត។ ដោយឡែកនៅក្នុងអក្សរសិល្ប៍រឿងកុលាបប៉ៃលិន ចៅចិត្រ មានអនាគតល្អព្រោះបានរៀនសូត្រចេះដឹងជ្រៅជ្រះដែរទើប យុន នារី ព្រមស្មគ្រទទួលយកជាគូគ្រងជីវិត។ ឯរឿងគូលីកំដែន ម៉ឺង មានការងារធ្វើក្នុងរាជការព្រោះបានរៀនសូត្រចេះដឹងដែរ ហើយអ្នកគ្រូ គូ រស់ សង្វារ ម៉ឹង មុនក្លាយជាគ្រូបង្រៀនគាត់ត្រូវការចាយលុយ ដើម្បីរៀនសូត្រមានចំណេះដឹងដែរ។ ដោយឡែករឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ អ្នកនិពន្ធបានឱ្យ សម ដែលយកតម្លៃចំណេះវិជ្ជាសំខាន់នោះ បានទទួលផលល្អនៃជីវិតនៅគ្រាចុងក្រោយ ពោលគឺ សម បានក្លាយជាកសិករគំរូនិងជាប្រធានក្រុមប្រឹក្សាឃុំទៀតផង។ ទាំង

នេះព្រោះតែ សម ជាអ្នកដែលមានចំណេះវិជ្ជាជ្រៅជ្រះដែរ។ ដូចទស្សនៈមួយគេនិយាយថា អ្នកមានចំណេះជ្រៅជ្រះ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយក៏មិនសាបសូន្យដែរ។ ជារួមយើងឃើញថា ចំណេះវិជ្ជាពិតជាមានតម្លៃខ្លាំងណាស់ ដើម្បីចិញ្ចឹមជីវិតរស់នៅក្នុងសង្គមប្រកបដោយភាពថ្លៃថ្នូរ។

សរុបសេចក្ដីមកឃើញថា មតិទីមួយមិនទាន់ត្រឹមត្រូវគ្រប់ជ្រុងជ្រោយនោះទេ ព្រោះមើលឃើញតែមួយចំណុចខ្វះការពិចារណាបានវែងឆ្ងាយ។ ចំណែកមតិទីពីរ ការបកស្រាយ គឺមានតម្លៃសម្រាប់អប់រំជាសកល ព្រោះការដឹកនាំមនុស្សក្នុងសង្គមត្រូវឱ្យតម្លៃលើចំណេះវិជ្ជាដែលជាឃ្លាំងទ្រព្យមិនចេះរីងស្ងួត។ ចំណេះវិជ្ជាមិនមែនសំដៅតែទៅលើវិជ្ជាដែលរៀននៅសាលានោះទេ សូម្បីតែការរៀនសូត្រនៅក្នុងសង្គមឬការរៀនយកជំនាញឯកទេសផ្សេងៗ ដើម្បីប្រកបរបរចិញ្ចឹមជីវិតនោះក៏ឈ្មោះថា ចំណេះវិជ្ជាដែរ។ ដូច្នេះ ដើម្បីទទួលបានអនាគតល្អនិងវែងឆ្ងាយនោះ មនុស្សរាល់រូបត្រូវឱ្យតម្លៃលើចំណេះវិជ្ជាទើបជាការប្រសើរ។

ឆ្លងតាមការពិភាក្សាបកស្រាយខាងលើឃើញថា រាល់មតិរបស់ប្រធានដែលបានលើកឡើង គឺមានភ្ជាប់ជាមួយនឹងការបកស្រាយប្រកបដោយអំណះអំណាងច្បាស់លាស់រៀងៗខ្លួន ហើយមានហេតុផលដោយឡែកពីគ្នា។ កត្តាដែលសំខាន់សម្រាប់ជីវិត គឺត្រូវចេះសំយោគចូលគ្នារវាងចំណេះវិជ្ជានិងទ្រព្យសម្បត្តិ ទើបអាចកសាង

ជីវិតបានថ្លៃថ្នូរសមតាមបំណងប្រាថ្នារៀងៗខ្លួន ព្រោះមនុស្សរាល់រូបសុទ្ធតែស្រមៃថា ខ្លួននឹងមានវាសនាល្អ មានទ្រព្យសម្បត្តិច្រើន និងមានអ្នកដទៃស្រលាញ់ពេញចិត្ត តែមិនមាននរណាម្នាក់នឹងចង់បានភាពក្រលំបាកមកដាក់ក្នុងជីវិតឡើយ។

ដើម្បីមានកិត្តិយសថ្លៃថ្នូរប្រសើរក្នុងជីវិត មនុស្សត្រូវតែចេះសំយោគចូលគ្នារវាងចំណេះវិជ្ជានិងទ្រព្យសម្បត្តិ ទើបការរស់នៅមិនជួបប្រទះនឹងសេចក្ដីអន្តរាយ។ ចំណេះវិជ្ជាជាទុនសម្រាប់រកទ្រព្យសម្បត្តិ ឯទ្រព្យសម្បត្តិជាទុនសម្រាប់ស្វែងរកចំណេះវិជ្ជា។ កត្តាទាំងពីរនេះគួបផ្សំគ្នាទើបញ៉ាំងជីវិតមនុស្សមានអនាគតល្អ សមតាមបំណងប្រាថ្នារបស់គេ។

# ប្រធាននិទស្សន៍

ការសិក្សាពីប្រធាននិទស្សន៍ គឺមានលក្ខណៈដូចគ្នានឹងប្រធានពន្យល់ឬប្រធានពិភាក្សាដែរ តែខុសត្រង់ពាក្យបង្គាប់បញ្ហាប៉ុណ្ណោះ។ ប្រធានប្រភេទនេះ គេអាចហៅថា ប្រធានសារណាឬនិក្ខេបបទ ព្រោះការបកស្រាយមានការលម្អិតជាចំណុចតូចៗជាច្រើនទៀត ហើយទាមទារការបកស្រាយមានការស្រាវជ្រាវវែងឆ្ងាយទៅនឹងប្រធានបទដែលពាក់ព័ន្ធ។

គម្រោងសរសេរប្រធាននិទស្សន៍

**ក- សេចក្តីផ្តើម**

❖ លំនាំបញ្ហា

❖ ចំណូលបញ្ហា

❖ ចំណោទបញ្ហា

**ខ- តួសេចក្តី**

❖ ឃ្លាភ្ជាប់សេចក្តី

❖ ពន្យល់ប្រធាន

❖ បកស្រាយប្រធាន

❖ បកស្រាយន័យចំរបស់ប្រធាន

❖ លើកឧទាហរណ៍ក្នុងសង្គម រួចភ្ជាប់ន័យប្រធានជាលក្ខណៈសំយោគ។

❖ លើកឧទារហាណ៍ក្នុងអក្សរសិល្ប៍ រួចភ្ជាប់ន័យប្រធានជាលក្ខណៈសំយោគ។

❖ លើកឧទាហរណ៍ក្នុងសាសនា រួចភ្ជាប់ន័យប្រធានជាលក្ខណៈសំយោគ។

❖ សំយោគគំនិត (ប្រសិនណាប្រធានចោទមកមានលក្ខណៈមិនត្រឹមត្រូវខ្វះចន្លោះនោះ អ្នកបកស្រាយត្រូវតែបំពេញបន្ថែមនៅចំណុចខ្វះចន្លោះនោះដោយភ្ជាប់ឧទាហរណ៍បន្ថែម ទាំងបីគោលការណ៍ខាងលើរួចនៅចុងបញ្ចប់ ធ្វើសំយោគទាំងពីរគំនិតចូលគ្នា គឺមតិប្រធាននិងមតិដែលបានលើកបន្ថែម)។

**គ- សេចក្តីបញ្ចប់**

❖ វាយតម្លៃប្រធាន : ត្រូវសំយោគចូលគ្នារវាងមតិប្រធាននិងមតិដែលបានលើកបន្ថែម (ប្រសិនបើមាន)។

❖ មតិផ្ទាល់ខ្លួន : មានលំនាំដូចប្រធានពន្យល់ដែរ។

ឧទាហរណ៍(១):

☞ **ប្រធាន** : គេថា "មនុស្សជាតិស្អប់សង្គ្រាម តែស្រលាញ់សន្តិភាព" តើទស្សនៈនេះមានន័យយ៉ាងណាដែរ? ចូរអ្នកធ្វើនិទស្សន៍។

ការបង្គាប់បញ្ជាយ៉ាងនេះ គឺមានន័យថាជាប្រភេទប្រធានពន្យល់សុទ្ធហើយអ្នកចាំបាច់ត្រូវសរសេរជាលំនាំប្រធានពន្យល់សុទ្ធដែរ តែត្រូវលម្អិតឱ្យបានល្អបំផុត និងពិស្តារជាងការបកស្រាយក្នុងប្រធានពន្យល់សុទ្ធ។ គំនិតអ្នកដែលសរសេរនៅក្នុងប្រធាននេះ គឺជាគំនិត

ទូលំទូលាយណាស់ មិនចង្អៀតចង្អល់ទេហើយរាល់ការបកស្រាយនីមួយៗត្រូវឈរលើអំណះអំណាងច្បាស់លាស់ មានន័យថា បើលើកពីសង្គមតើសង្គមណា? បុរាណឬបច្ចុប្បន្ន? បើពីអក្សរសិល្ប៍តើរឿងណាមួយ? ស្នាដៃរបស់នរណា? សរសេរឆ្នាំណា?

ឧទាហរណ៍(២) :

☞ **ប្រធាន** : នៅក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ **សៅ** មានមុខរបរជាចោរ ដើរលួចឆក់គេទើបគេមានជីវភាពធូរធារ។ ចំណែកសង្គមសព្វថ្ងៃ អ្នកដែលជួញដូរគ្រឿងញៀនមានជីវភាពធូរធារដែរ។ តើបញ្ហាដែលបានចោទឡើងនេះមានអត្ថន័យយ៉ាងណា? មានដំណោះស្រាយដូចម្ដេច? ចូរធ្វើនិទស្សន៍។

នៅពេលចោទយ៉ាងដូច្នេះ អ្នកបកស្រាយត្រូវបកស្រាយម្ដងមួយដំណាក់ៗ ដូចប្រធានពន្យល់សុទ្ធដែរ។ នៅពេលការបកស្រាយចប់ត្រូវចាប់កថាខណ្ឌថ្មីមួយទៀត ទើបលើកទស្សនៈថ្មីមួយទៀតឡើង ហើយជាទស្សនៈដែលមិនឱ្យតម្លៃទៅលើមុខរបរទាំងពីរនេះ រួចបញ្ជាក់ពីមូលហេតុ។ បន្ទាប់ពីអ្នកលើកហេតុផលច្បាស់លាស់ហើយ អ្នកត្រូវពន្យល់ទស្សនៈថ្មីរបស់អ្នក ដោយមានអំណះអំណាងច្បាស់លាស់ដូចប្រធានពន្យល់សុទ្ធម្ដងទៀត។

នៅចុងបញ្ចប់ អ្នកធ្វើសំយោគសេចក្ដីមួយដោយបដិសេធមតិប្រធាននិងលើកពីតម្លៃមតិរបស់អ្នក។ ចំណែកសេចក្ដីបញ្ចប់ត្រូវអនុវត្តដូចប្រធានពន្យល់សុទ្ធដដែល គ្រាន់តែចំណុចវាយតម្លៃប្រធានត្រូវលើក

គុណសម្បត្តិទស្សនៈថ្មីរបស់អ្នកផង និងធ្វើមតិផ្ទាល់ខ្លួនក៏ត្រូវបញ្ចូលពីទស្សនៈថ្មីរបស់អ្នកដែរ។

សរុបសេចក្តីមកប្រធាននិទស្សន៍ គឺជាប្រធានដែលសំយោគចេញពីប្រធានពន្យល់ និងមានលំនាំអធិប្បាយប្រហាក់ប្រហែលគ្នាគ្រាន់តែប្រធានប្រភេទនេះការបកស្រាយពិស្តារជាង ហើយទាមទារភាពច្បាស់លាស់ជាង ចំណែករចនាបថគឺរក្សាដូចប្រធានពន្យល់ដដែល។

# ឯកសារយោង

១- សម្តេចព្រះសង្ឃរាជ **ជួន-ណាត** ជោតញ្ញាណោ វចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ

២- ក្រសួងអប់រំ ភាសាខ្មែរថ្នាក់ទី១២ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឆ្នាំ២០០១

៣- ក្រសួងអប់រំ ភាសាខ្មែរថ្នាក់ទី១១ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឆ្នាំ២០០២

៤- ក្រសួងអប់រំ ភាសាខ្មែរថ្នាក់ទី១០ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឆ្នាំ២០០០

៥- ក្រសួងអប់រំ ភាសាខ្មែរថ្នាក់ទី៩ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឆ្នាំ២០០៦

៦- ក្រសួងអប់រំ ភាសាខ្មែរថ្នាក់ទី៨ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឆ្នាំ២០០៦

៧- ក្រសួងអប់រំ ភាសាខ្មែរថ្នាក់ទី៧ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឆ្នាំ២០០៣

៨- ក្រសួងអប់រំ ភាសាខ្មែរថ្នាក់ទី៦ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឆ្នាំ២០០៤

៩- លោក **ជួរ តារី** ការតែងនិពន្ធ បណ្ណាគារអង្គរ ឆ្នាំ២០០៦

១០- លោក **ម៉ិញ លីហ៊ាន** ប្រជុំវិញ្ញាសាតែងសេចក្តីខ្មែរ ដោយ**តឹន ប៊ុនថន**

១១- សៀវភៅតែងសេចក្តីខ្មែរ សម័យរដ្ឋកម្ពុជា។

# សៀវភៅដែលបានចេញផ្សាយរួចហើយ
# ដោយសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ



















ISBN-13:978-999-63-879-1.3
9 789996 387913 >